ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី

## ករណីសិក្សា ខេត្តកំពង់ចាម

## EFFECTIVENESS IN IMPLEMENTING NEW GENERATION SCHOOLS

Case Study: Kampong Cham

**ដោយ**/By

**លី កុសល**

**LY KOSAL**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**ឧបត្ថមដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation (CIESF)

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី

## ករណីសិក្សា ខេត្តកំពង់ចាម

## EFFECTIVENESS IN IMPLEMENTING NEW GENERATION SCHOOLS

Case Study: Kampong Cham

**ដោយ**/By

**លី កុសល**

**LY KOSAL**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

| | |
|---|---|
| **សាស្ត្រាចារ្យដឹកនាំ** | **ឯកឧត្តមបណ្ឌិត ឌី ខាំបូលី** |
| **សាស្ត្រាចារ្យដឹកនាំរង** | **លោក ឌី បុណ្ណា** |

**ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation (CIESF)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៩៦២៩ អយក. ខ.ល

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទធាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹត្យការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ 

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី**" សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ ស្នាដៃនេះពុំទាន់បានប្រើដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើ ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។
និក្ខេបបទស្រាវជ្រាវនេះគឺពិតជាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩
ហត្ថលេខាបេក្ខជន

លី កុសល

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** ជាសាស្ត្រាចារ្យដឹកនាំ

លោក **ឌី ប៊ុណ្ណា** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់និងទទួលស្គាល់ថា

លោក លី កុសល ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី**" ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

.......................................... ..............................................

**ឯកឧត្តមបណ្ឌិត ឌី ខាំបូលី** **លោក ឌី ប៊ុណ្ណា**

អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ នាយករងវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់វិទ្យាស្ថានជាតិអប់រំ និងក្រសួងអប់រំយុវជន និងកីឡា ដែលបានរៀបចំបើកថ្នាក់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមកនេះ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះគណៈកម្មកាគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាមកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការលំបាក និងការនឿយហត់។

ជាពិសេសសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីមកពន្យល់ណែនាំដល់រូបខ្ញុំបាទគ្រប់ជំហាន ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទក្នុងពេលនេះអាចទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកគ្រូ **ឌី មុណ្ណា** ដែលបានជួយកែសម្រួល និងចែករំលែកនូវបទពិសោធន៍ដល់រូបខ្ញុំសម្រាប់ដំណើរការសិក្សាស្រាវជ្រាវនេះ។ ជាមួយគ្នានេះដែរ សូមថ្លែងអំណរគុណចំពោះគ្រួសាររបស់ខ្ញុំជាពិសេសភរិយាខ្ញុំដែលតែងតែជួយផ្តល់នូវកម្លាំងចិត្ត ភាពកក់ក្តៅដល់រូបខ្ញុំគ្រប់ពេលវេលា ហើយក៏សូមថ្លែងអំណរគុណដល់មិត្តរួមថ្នាក់នៅជំនាន់ទី៦ទាំងអស់គ្នាដែលតែងតែចែករំលែកចំណេះដឹងបទពិសោធន៍ល្អៗ និងព័ត៌មានផ្សេងៗជាពិសេសគឺជួយផ្តល់ឯកសារផ្សេងៗនៅក្នុងក្រុម។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅតាមសាលាគោលដៅទាំងពីរដែលបានចូលរួមជួយសហការណ៍គ្នា ក្នុងអំឡុងពេលដំណើរការនៃការប្រមូលទិន្នន័យដែលជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើការសិក្សាស្រាវជ្រាវនេះទទួលលទ្ធផលជោគជ័យ។

ជាទីអវសាន្ត ខ្ញុំសូមជូនពរចំពោះអ្នកទាំងអស់គ្នាសូមឱ្យមានសុខភាពល្អ កម្លាំងមាំមួន ប្រកបការងារផ្សេងៗសូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច ជាពិសេសជូនពរដល់និស្សិតបរញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ឱ្យទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ការសិក្សាទាំងអស់គ្នា និងទទួលបាននូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

សូមអរគុណ!

# មូលបទសង្ខេប

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងរកប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីដែលផ្តោតអារម្មណ៍សំខាន់លើលទ្ធផលសិក្សារបស់សិស្សនិងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះមានបំណងស្វែងរកព័ត៌មានបន្ថែមដែលទាក់ទងទៅនឹងការអនុវត្តនៅតាមសាលាជំនាន់ថ្មីស្ថិតនៅក្នុងខេត្តកំពង់ចាមនូវការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជះឥទ្ធិពលកម្រិតណាដល់លទ្ធផលសិក្សារៀនសូត្ររបស់សិស្សានុសិស្ស ។

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំរុះរួមមានសំណួរពហុជ្រើសរើសនិងសំណួរបើកសម្រាប់បំពេញដើម្បីប្រមូលទិន្នន័យ។ ទំហំនៃសំណាកដែលត្រូវឆ្លើយតបនឹងគោលដៅរួមមាននាយកចំនួន២នាក់ គ្រូចំនួន២០ និងសិស្សចំនួន៧០នាក់។ ការសិក្សាស្រាវជ្រាវនេះទទួលបានទិន្នន័យដែលត្រូវប្រើទាំងការវិភាគបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យត្រូវបានវិភាគដោយប្រើកម្មវិធីកុំព្យូទ័រ Excel និង SPSS និងសំណួរបើកដោយសរសេរសង្ខេបរួម។ ចំណែកការធ្វើបទបង្ហាញវិញគឺត្រូវធ្វើឡើងដោយប្រើតារាងនិងដ្យាក្រាមដោយមានតម្លៃភាគរយ និងតម្លៃមធ្យម។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថាប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីនៅក្នុងខេត្តកំពង់ចាមនៅមានកម្រិតនៅឡើយចំពោះលទ្ធផលសិក្សារបស់សិស្សទោះបីមានចំណុចល្អប្រសើរច្រើនដូចជាការដឹកនាំគ្រប់គ្រង សម្ភាររូបវន្ត ការបង្ហាត់បង្រៀន លោកគ្រូអ្នកគ្រូមានទំនាក់ទំនងល្អជាមួយគណៈគ្រប់គ្រង សហគមន៍ និងមាតាបិតាសិស្សក៏ដោយ។ តាមរយៈបញ្ហាមួយចំនួនដូចជាលទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតនៅឡើយតាមរយៈលទ្ធផលតេស្តប្រចាំឆមាសទី១ សិស្សចំនួន ៨៨.៥៧%មិនសូវបានធ្វើពិសោធន៍ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ សិស្សចំនួន ៨០.០០% យល់ឃើញថាមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាគណិតវិទ្យាក្នុងចំណោមមុខវិជ្ជាស្នែមដែលជាមុខវិជ្ជាគោលនៅសាលាជំនាន់ថ្មីពិបាកយល់ សិស្សជិត៥០%មានការស្វ័យសិក្សាតិចតួច និងសិស្សជិត៥០%បានចូលក្លឹបសិក្សាតិចតួច។ លើសពីនេះសិស្សភាគច្រើនមានចំណេះដឹងភាសាអង់គ្លេស និងចំណេះដឹង ICT នៅមានកម្រិតនិងទៀតសោតលោកគ្រូអ្នកគ្រូមួយភាគធំមានចំណេះដឹងផ្នែកភាសាអង់គ្លេស បច្ចេកវិទ្យាព័ត៌មាន វិធីសាស្ត្របង្រៀនតាមបែបសតវត្សរ៍ទី២១នៅមានកម្រិតនៅឡើយ និងលោកគ្រូអ្នកគ្រូចំនួន ២៦.៣១%បង្រៀនខុសឯកទេស។

# Abstract

This research was conducted in order to explore the effectiveness in implementing new generation schools that focus on student learning outcomes and the factors that influence student learning outcomes. Specifically, this study aims to find out further information related to the new generation school implementation in Kampong Cham province such as leading and managing, teaching and learning and physical infrastructure and how much this impacts on students' learning outcomes.

In this study, the researcher used mixed method questionnaires such as multiple-choice questionaires and open-ended questions for data collection. The sample size was suitable for this research target including 2 principals, 20 teachers and 70 students.

In addition, the research tools used to collect data included questionnaires for principals,teachers, and students. This study received data that was used in both quantitative and qualitative analysis, quantitative data were computed by using Excel and SPSS and for open-ended questionaires by summarizing answers and observation. Whereas doing a presentation, it is done by using charts and percentage tables and tables with mean.

Findings from this study show that the effectiveness in implementing new generation schools in Kampong Cham is leveled for students' study outcome although they are good for leadership and management, physical materials, teaching, teachers having good relationship with directors, other teachers, stuedents, parents, and community. But there are still some problems such as students' learning outcomes with limitation based on first semester results, 88.57% of the students did little experiments on science subject and 80.00% of students found that science subject and Math among STEM, the core of the new generation school curriculum, were difficult to understand, nearly 50 % of students selfstudy and nearly 50 % did not join club study too. English and ICT knowledge were limited too. Also most teachers have limited knowledge about the language, technology, and teaching methods in the 21st Century and 26.32% of teachers have taught with wrong specialised subjects.

# មាតិកា


**សេចក្តីប្រកាសរបស់បេក្ខជន** ....................................................................................................I
**ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ**..........................................................................................II
**សេចក្តីថ្លែងអំណរគុណ**........................................................................................................III
**មូលបទសង្ខេប** ..................................................................................................................III
**មាតិកា**................................................................................................................................VI
**បញ្ជីអក្សរកាត់** .................................................................................................................. IX
**បញ្ជីតារាង**........................................................................................................................ X
**បញ្ជីក្រាហ្វិក**....................................................................................................................... XI


## ជំពូកទី១
## សេចក្តីផ្តើម


១.សារវតារ ................................................................................................ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................................................ ៤

៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ........................................................................៥

៤.សំណួរស្រាវជ្រាវ...........................................................................................៥

៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ........................................................................៥

៦.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........................................................................៦

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.................................................................................៦


## ជំពូកទី២
## ការរំលឹកទ្រឹស្តី


២.១ ពន្យល់ន័យនៃពាក្យគន្លឹះ.................................................................................. ៨

២.២ ប្រវត្តិនៃសាលាជំនាន់ថ្មី ................................................................................... ៨

២.៣ ស្ថានភាពសាលារៀនជំនាន់ថ្មីបច្ចុប្បន្ន ............................................................... ១៣

២.៤ គោលបំណងនៃការបង្កើតសាលាជំនាន់ថ្មី ...........................................................២១

២.៥ បេសកកម្មរបស់សាលារៀនជំនាន់ថ្មី .............................................................. ២២

២.៦ ចក្ខុវិស័យសាលារៀនជំនាន់ថ្មី..................................................................... ២៣

២.៧ គោលដៅសាលារៀនជំនាន់ថ្មី ....................................................................... ២៣

២.៨ យុទ្ធសាស្រ្ត..............................................................................................២៤

២.៩ លក្ខណៈវិនិច្ឆ័យស្នើសុំដើម្បីទទួលបានមូលនិធិសមធមិសង្គម.........................២៥

២.១០ ចំណុចខ្លាំង និងចំណុចខ្សោយនៃសាលារៀនជំនាន់ថ្មី ................................២៧

## ជំពូកទី៣

## វិធីសាស្ត្រនៃការស្រាវជ្រាវ

៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ................................ ២៨
៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ................................ ២៨
៣.៣ ក្រុមគោលដៅ ................................ ២៨
៣.៤ ទំហំសំណាក ................................ ២៩
៣.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ................................ ២៩
៣.៦ ការជ្រើសរើសសំណាក ................................ ២៩
៣.៧ ឧបករណ៍សម្រាប់ស្រាវជ្រាវ................................៣០
៣.៨ ដំណើរការប្រមូលទិន្នន័យ ................................ ៣១
៣.៩ ការវិភាគទិន្នន័យ................................ ៣២
៣.១០ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ................................៣៣
៣.១១ ព្រំដែននៃការសិក្សាស្រាវជ្រាវ ................................ ៣៤

## ជំពូកទី៤

## លទ្ធផលនៃការសិក្សាស្រាវជ្រាវ

៤.១- លទ្ធផលនៃការសិក្សាស្រាវជ្រាវ ................................៣៥
៤.១.១- ព័ត៌មានផ្ទាល់ខ្លួន................................៣៥
៤.២- កម្រងសំណួរសម្រាប់នាយក................................ ៤០
៤.២.១៖ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិតរបស់នាយក................................ ៤១
៤.២.២៖ ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន ................................ ៤២
៤.២.៣៖ ការដឹកនាំការបង្រៀន និងរៀន ................................ ៤៣
៤.២.៤៖ បំណិនប្រាស្រ័យទាក់ទង ................................ ៤៤
៤.២.៥៖ ក្រមសីលធម៌វិជ្ជាជីវៈនាយក................................ ៤៥
៤.៣ កម្រងសំណួរសម្រាប់គ្រូ................................ ៤៦
៤.៣.១ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិត................................ ៤៧
៤.៣.២ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ................................ ៤៨

៩.៣.៣ បំណិនប្រាស្រ័យទាក់ទង ........................................................ ៤៨
៩.៣.៤ លទ្ធផលសិក្សារបស់សិស្ស ........................................................ ៤៩
៩.៣.៥ សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង ........................................................ ៤៩
៩.៣.៦ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន........................................................ ៥០
៩.៤ ការសិក្សារបស់សិស្សានុសិស្ស........................................................ ៥១
៩.៥ លទ្ធផលនៃការសិក្សារបស់សិស្សប្រចាំខែ និងប្រចាំឆមាសទី១........................ ៦១

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១- សេចក្តីសន្និដ្ឋាន ........................................................ ៦៣
៥.២- សំណូមពរ ........................................................ ៦៤
៥.៣- ការសិក្សាស្រាវជ្រាវបន្ត........................................................ ៦៥
**ឯកសារយោង** ........................................................ ៦៧
**ឧបសម្ព័ន**........................................................ ៦៨

# បញ្ជីអក្សរកាត់

| | |
|---|---|
| KAPE | : Kampuchea Action for Primary Education |
| NGS | : New Generation School |
| NGSNS | : New Generation School National Survey |
| IBEC | : Improved Basic Education in Cambodia |
| BSI | : Beacon School Initiatives |
| MDG | : Mellinuim Development Goal |
| CIDP | : Cambodian Industrial Development Policy |
| MoEYS | : Ministry of Education, Youth and Sports |
| RGC | : Royal Government of Cambodia |
| TTD | : Teacher Training Department |
| SDG | : Sustainable Development Goal |
| EFA | : Education for All |
| IBL | : Inquiry Based Learning |
| PBL | : Project Based Learning |
| ICT | : Information and Communications Technology |

# បញ្ជីតារាង

តារាង ៣.៣.១ ៖ ក្រុមគោលដៅ និងអ្នកចូលរួម ........................................................ ២៩

តារាងទី១៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ .................... ៣៧

តារាងទី២ ៖ កម្រិតវប្បធម៌ នាយក និងគ្រូបង្រៀន ................................................ ៣៧

តារាងទី៣ ៖ កម្រិតវិជ្ជាជីវៈ នាយក និងគ្រូបង្រៀន................................................ ៣៨

តារាងទី៤៖ សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត .................................................. ៤២

តារាងទី៥៖ ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន................................................ ៤៣

តារាងទី៦៖ ការដឹកនាំការរៀន និងបង្រៀន.......................................................... ៤៤

តារាងទី៧៖ បំណិនប្រាស្រ័យទាក់ទង ................................................................. ៤៥

តារាងទី៨៖ ក្រមសីលធម៌វិជ្ជាជីវៈនាយក ............................................................. ៤៦

តារាងទី៩៖ កត្តាកំណត់ពីប្រសិទ្ធិភាពរបស់នាយកក្នុងការដឹកនាំ ............................ ៤៦

តារាងទី១០៖ សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត................................................ ៤៨

តារាងទី១១៖ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ........................................................ ៤៩

តារាងទី១២៖ បំណិនប្រាស្រ័យទាក់ទង................................................................ ៤៩

តារាងទី១៣៖ លទ្ធផលសិក្សារបស់សិស្ស ............................................................ ៥០

តារាងទី១៤៖ សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង.............................................. ៥០

តារាងទី១៥៖ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ..................................................... ៥១

# បញ្ជីក្រាហ្វិក

ដ្យាក្រាមទី១ ៖ អតីតភាពការងារមុខតំណែងរបស់ នាយក និងគ្រូបង្រៀន(%) .......... ៣៩
ដ្យាក្រាមទី២ ៖ ចំនួនសិស្សតាមកម្រិតថ្នាក់ (នាក់)........................................ ៣៩
ដ្យាក្រាមទី៣៖ លោកគ្រូអ្នកគ្រូបង្រៀនត្រូវឯកទេស និងខុសឯកទេស .................... ៤០
ដ្យាក្រាមទី៤៖ ការធ្វើតេស្តសិស្ស ការប្រឡងប្រជែងជ្រើសរើសនាយក .................... ៤១
ដ្យាក្រាមទី៥៖ តើប្អូនៗចូលបណ្ណាល័យញឹកញាប់ទេ?........................................ ៥២
ដ្យាក្រាមទី៦៖ តើប្អូនៗធ្វើពិសោធ៍ចំពោះមុខវិជ្ជាវិទ្យាសាស្ត្រញឹកញាប់ទេ?............... ៥៣
ដ្យាក្រាមទី៧៖ តើប្អូនៗធ្វើពិសោធ៍ក្នុងថ្នាក់ ឬក្រៅថ្នាក់រៀន........................................ ៥៣
ដ្យាក្រាមទី៨៖ ចំពោះមុខវិជ្ជា STEM តើមុខវិជ្ជាណា ........................................ ៥៤
ដ្យាក្រាមទី៩៖ តើប្អូនយល់យ៉ាងណាដែរចំពោះមុខវិជ្ជា STEM?................................ ៥៥
ដ្យាក្រាមទី១០៖ តើប្អូនប្រើប្រាស់កុំព្យូទ័រញឹកញាប់ទេ?........................................ ៥៥
ដ្យាក្រាមទី១១៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការប្រើប្រាស់កុំព្យូទ័រ............ ៥៦
ដ្យាក្រាមទី១២៖ តើការសិក្សារបស់ប្អូនមានការរីកចំរើនច្រើនដែរឬទេបន្ទាប់.............. ៥៦
ដ្យាក្រាមទី១៣៖ តើប្អូនៗពេញចិត្តនឹងលទ្ធផលនៃការសិក្សាដែលប្អូន ...................... ៥៧
ដ្យាក្រាមទី១៤៖ តើប្អូនមានស្វ័យសិក្សាញឹកញាប់ដែរឬទេ? ........................................ ៥៨
ដ្យាក្រាមទី១៥៖ តើប្អូនចូលរួមក្នុងក្លឹបសិក្សាញឹកញាប់ដែរឬទេ?................................ ៥៨
ដ្យាក្រាមទី១៦៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការបង្រៀន .......................... ៥៩
ដ្យាក្រាមទី១៧៖ តើប្អូនយល់ឃើញយ៉ាងដូចម្ដេចចំពោះខ្លឹមសារ ................................ ៦០
ដ្យាក្រាមទី១៨៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការផ្ទេរចំណេះដឹ .................. ៦០
ដ្យាក្រាមទី១៩៖ តើប្អូនៗពេញចិត្តនឹងលទ្ធផលនៃការសិក្សាដែលប្អូន...................... ៦១
ដ្យាក្រាមទី២០ លទ្ធផលការសិក្សាប្រចាំខែ និងប្រចាំឆមាសលើកទី១ ...................... ៦២

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.សារសំខាន់

គ្រប់ប្រទេសនៅលើសកលលោក តែងតែស្វះស្វែង ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការផលិតធនធានមនុស្សដែលជាអ្នកបន្តវេនក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបទៅដោយនិរន្តរភាព ភាពសុខដុមរមនា និងចិរភាពនៅពេលអនាគត។ វិស័យមួយក្នុងចំណោមវិស័យជាច្រើនដែលមានតួនាទីបង្កើតធនធានមនុស្សគឺ វិស័យអប់រំដែលជាវិស័យមួយមានកាតព្វកិច្ច និងតួនាទីយ៉ាងសំខាន់ ក្នុងការបណ្តុះបណ្តាល និងបង្កើតធនធានមនុស្ស ប្រកបដោយសក្តានុពល និងជំនាញច្បាស់លាស់ សម្រាប់ចូលរួមជួយធ្វើឱ្យប្រទេសជាតិមានការរីកលូតលាស់លើគ្រប់វិស័យ។ ទន្ទឹមនិងគ្នានេះផងដែរ ការអប់រំគឺជាកាតាលីករដ៏សំខាន់បំផុតក្នុងការបណ្តុះបណ្តាលធនធានមនុស្សពេញលេញរួមមានចំណេះដឹង ជំនាញឯកទេស ឥរិយាបទ និងក្រមសីលធម៌ដែលសាកសមជាធនធានដ៏មានសក្តានុពល និងជាតម្រូវការរបស់ប្រទេសជាតិ។ ដើម្បីធ្វើឱ្យការអប់រំមួយដំណើរការទៅបានល្អប្រសើរ និងមានគុណភាព គេចាំបាច់ត្រូវគិតទៅលើកត្តាចាំបាច់មួយចំនួនដូចជា នាយកសាលា លោកគ្រូ អ្នកគ្រូ កម្មវិធីសិក្សា សម្ភារៈឧបទេស និងសិស្សានុសិស្ស។

ជាការពិតណាស់ គុណភាពគឺជាបេះដូងនៃការអប់រំ។ វាមានឥទ្ធិពលលើអ្វីដែលសិស្សរៀន របៀបដែលពួកគេរៀន និងអ្វីដែលពួកគេទទួលបានពីការអប់រំ. (EFA)

ការពង្រឹងវិស័យអប់រំប្រទេសកម្ពុជាដើម្បីធ្វើឱ្យមានគុណភាព ប្រសិទ្ធភាព និងភាពឆ្លើយតបទៅនឹងការរីកចម្រើនក្នុងតំបន់ និងពិភពលោក រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការអប់រំ ដើម្បីលើកទឹកចិត្ត និងជំរុញប្រជាពលរដ្ឋគ្រប់រូប ឱ្យទទួលបានការអប់រំយ៉ាងតិចនៅត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិថ្នាក់ទី៩ និងផ្តល់ឱកាសឱ្យពួកគេទទួលបាននូវការសិក្សាពេញមួយជីវិតដែលអាចពង្រឹង និងបង្កើននូវចំណេះដឹងបំណិនវិជ្ជាជីវៈ សមត្ថភាព ភាពថ្លៃថ្នូរ និងឥរិយាបថសមរម្យក្នុងសង្គម **(ច្បាប់ស្តីពីការអប់រំ, ២០០៧)**

មិនតែប៉ុណ្ណោះ ដើម្បីបណ្តុះបានធនធានមនុស្សដែលឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងបច្ចេកវិទ្យាសកល វិធីសាស្ត្របង្រៀននិងរៀនតាមបែបទំនើបជាច្រើនត្រូវ

បានបង្កើតឡើងដូចជា ការបង្រៀននិងរៀនតាមបែបរិះរក (IBL) ការបង្រៀននិងរៀនតាមបែបសហការ ការបង្រៀននិងរៀនតាមបែបស្រាវជ្រាវ (Research) ការបង្រៀននិងរៀនដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃតាមបែបប្លូម (Bloom's Taxonomy) ការបង្រៀននិងរៀនតាមបែបផ្អែកលើគម្រោង (PBL)....។

បន្ថែមពីលើនេះទៀត នៅក្នុងផែនការអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ក៏ដូចជាផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តោតការយកចិត្តទុកដាក់សំខាន់លើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សរួមមាន ការកែទម្រង់វិស័យអប់រំ បង្កើតបាននូវបរិយាកាស និងក្តីសង្ឃឹមថ្មីក្នុងការបង្កើនធនធានមនុស្ស និងជំនាញសម្រាប់ផ្គត់ផ្គង់ទីផ្សារការងារ តាមរយៈការបង្កើតសាលាជំនាន់ថ្មី ការពង្រឹងគុណភាពនៃការបង្រៀន ការលើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងសាលារៀន ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងការរៀបចំបរិយាកាសល្អសម្រាប់ការរៀនសូត្រ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ហើយក៏បានចាត់ទុកវិស័យអប់រំជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀតដែលអាចកសាងធនធានមនុស្សមួយដែលពោរពេញដោយសមត្ថភាព និងជំនាញវិជ្ជាជីវៈច្បាស់លាស់ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយចីរភាព និងជឿនលឿនកាន់តែឆាប់រហ័សនាពេលអនាគតយ៉ាងខ្លី **(RGC, 2014-2018)**

នៅនីតិការទី៦នេះផងដែរ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤នឹងនៅតែបន្តយកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ដែលដោយផ្តោតទៅលើ ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រនិងបច្ចេកទេស ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ (យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, 2019-2023)

បន្ថែមពីនេះទៅទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣)ត្រូវធ្វើឡើងសម្រាប់អនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដោយកំណត់នូវសូចនាករនានា និងពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងត្រួតពិនិត្យវាយតម្លៃផ្អែកលើក្របខណ្ឌលទ្ធផល ជាពិសេសកំណត់ពីការទទួលខុសត្រូវរបស់ក្រសួងសម្រាប់មុំនីមួយៗដើម្បីទទួលផលចំណេញខ្ពស់ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងឈានឡើងពីប្រទេសដែលមានចំនូលមធ្យមកម្រិតទាបបន្តឆ្ពោះទៅសម្រេចឱ្យបាន ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងរួមចំណែកសម្រេចឱ្យបានក្របខណ្ឌគោល

ដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣)

ចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជាគឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅរកឧស្សាហកម្មផ្អែកលើជំនាញឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ខ្សែសង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងការប្រកួតប្រជែង និងការលើកកម្ពស់ផលិតផលឧស្សាកម្មក្នុងស្រុក ហើយឈានបន្តអភិវឌ្ឍទៅជាឧស្សាហកម្មទំនើបដែលផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា និងចំណេះដឹង (CIDP, 2015) និងកំណត់ទិសដៅរបស់ខ្លួន ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងបន្តប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០, (TTD, 2015) ។

បន្ថែមពីនេះទៀតបន្តពីគោលដៅអភិវឌ្ឍសហវត្ស គោលដៅអភិវឌ្ឍប្រកបដោយចីរភាពក៏បានចាប់ផ្តើមដែលរួមមាន១៧គោលដៅសំខាន់ៗ ហើយក្នុងនោះគោលដៅទី៤ ការអបរំប្រកបដោយគុណភាព SDG4 គឺសង្កត់ធ្ងន់លើការអប់រំប្រកបដោយគុណភាពដែលធានាឱ្យបាននូវគុណភាពអប់រំប្រកបដោយសមភាពនិងបរិយាប័ន្ន និងជំរុញឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា(status of data for children in the SDGs, UNICEF)

ទាំងនេះសបញ្ជាក់ឱ្យឃើញថាការអប់រំពិតជាមានសារសំខាន់ ហើយនៅក្នុង**មាត្រទី៦៦** នៃរដ្ឋធម្មនុញ្ញកម្ពុជា រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត **និងមាត្រទី៦៧** រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។

ឆ្លើយតបទៅនឹងគោលដៅទាំងនេះ ព្រមទាំងដើម្បីអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសកម្ពុជាឱ្យក្លាយជាពលរដ្ឋពេញលេញដែលទទួលបាននូវចំណេះដឹង បំណិន និងឥរិយាបថប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេសដើម្បីប្រកួតប្រជែង និងឆ្លើយតបទៅនឹងទីផ្សារការងារទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត និងដើរឱ្យទាន់និន្នាការនៃការអភិវឌ្ឍ និងការរីកចម្រើនរបស់ពិភពលោក ក្រសួងអប់រំ យុវជន និង

កីឡា បានកំណត់ជាអទិភាព និងកំពុងអនុវត្តនូវផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា (២០១៨ - ២០២៣) គោលនយោបាយអប់រំជាតិ និងអន្តរជាតិ ព្រមទាំងដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រការពង្រឹងនិងលើកកម្ពស់វិស័យអប់រំនៅកម្ពុជាឱ្យមានភាពល្អប្រសើរជាបន្តបន្ទាប់ ជាពិសេសការបន្ស៊ីកំណែទម្រង់វិស័យអប់រំលើ ១៥ ចំណុចក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រោមការដឹកនាំរបស់បណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធ្វើកំណែទម្រង់រហូតដល់ទៅ១៥នៅក្នុងវិស័យអប់រំនៅកម្ពុជាដើម្បីចង់ឱ្យលទ្ធផលសិក្សារបស់សិស្សដែលទទួលបានគឺឆ្លើយតបទៅនឹងសមត្ថភាព ចំណេះដឹងនៅសតវត្សរ៍ទី២១។ លើសពីនេះទៅទៀតក្នុងកំណែទម្រង់ទាំង១៥នេះ មានកំណែទម្រង់មួយគឺកំណែទម្រង់នៃការបង្កើតសាលារៀនជំនាន់ថ្មីដើម្បីឆ្លើយតបទៅនឹងបរិបទអប់រំនៅសតវត្សរ៍ទី២១។

អាស្រ័យហេតុនេះហើយបានជាអ្នកស្រាវជ្រាវមានបំណងស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តសាលារៀនជំនាន់ថ្មីនេះដោយផ្តោតអារម្មណ៍សំខាន់ទៅលើលទ្ធផលសិក្សារបស់សិស្សានុសិស្ស។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ទៅលើចំណុចអាទិភាពទាំង១៥ និងសរសេសស្តម្ភទាំង៥ ជាពិសេសទៅលើការបង្រៀន ការរៀន ការគ្រប់គ្រងគុណវុឌ្ឍិគ្រូ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដើម្បីធ្វើឱ្យគុណភាពអប់រំបានល្អប្រសើរឡើងរួចមក យើងសង្កេតឃើញថាសិស្សភាគច្រើនបានកែប្រែឥរិយាបថដោយខិតខំប្រឹងប្រែងរៀនសូត្រគួរឱ្យកត់សម្គាល់។

ជាពិសេសដោយសារតែពិភពលោកសព្វថ្ងៃមានការរីចចំរើនខ្លាំងខាងបច្ចេកវិទ្យា និងការបង្កើតទីផ្សារសេរី ទើបធ្វើឱ្យការប្រកួតប្រជែងខាងទីផ្សារការងារក៏មានការប្រកួតប្រជែងផងដែរ។ ដើម្បីឆ្លើយតបទៅនឹងការរីកចំរើនទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកំណែទម្រង់ចម្បងមួយចំណុចក្នុងកំណែទម្រង់វិស័យអប់រំមានចំនួន១៥ ចំណុចគឺកំណែទម្រង់ទី១៤ "**ការបង្កើតសាលាជំនាន់ថ្មី**" ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្សក្នុងវិស័យអប់រំដែលអាចឆ្លើយតបទៅនឹងបរិបទអប់រំយុគសម័យបច្ចេកវិទ្យានេះ។ ហេតុនេះបានជាអ្នកស្រាវជ្រាវចង់ស្វែងរកថាតើការអនុវត្តនៅក្នុង

សាលារៀនជំនាន់ថ្មីមានប្រសិទ្ធភាពដល់កម្រិតណាហើយ។

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង

១.ស្វែងយល់ពីលទ្ធផលសិក្សារបស់សិស្សានុសិស្សបន្ទាប់ពីបានចូលរៀននៅក្នុងវិទ្យាល័យជំនាន់ថ្មីខេត្តកំពង់ចាម។

២.រកឱ្យឃើញអំពីបញ្ហានានាដែលជះឥទ្ធិផលដល់លទ្ធផលសិក្សារបស់សិស្ស។

## ៤.សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវនៃប្រធានបទខាងលើគឺ៖

តើលទ្ធផលសិក្សារបស់សិស្សនៅក្នុងសាលាវិទ្យាល័យជំនាន់ថ្មីក្នុងខេត្តកំពង់ចាមមានការកើនឡើង និងមានប្រសិទ្ធភាពកម្រិតណា?

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវនេះ នឹងបង្ហាញអំពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តសាលាវិទ្យាល័យ ជំនាន់ថ្មីនិងទៅលើលទ្ធផលសិក្សាសម្រេចបានរបស់សិស្ស។

- ការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជាព័ត៌មានដ៏មានប្រយោជន៍សម្រាប់ជាជំនួយដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងការអនុវត្តនៅតាមសាលាវិទ្យាល័យជំនាន់ថ្មីប្រកបដោយប្រសិទ្ធភាពផ្អែកទៅលើការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

- ការសិក្សាស្រាវជ្រាវនេះគឺជាទុនសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗអាចសិក្សាបន្ត ឱ្យបានកាន់តែមានលក្ខណៈលម្អិតនូវរាល់បញ្ហាប្រឈម និងដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី។

ទិន្នន័យដែលត្រូវបានប្រមូលពីការសិក្សាស្រាវជ្រាវនេះអាចផ្តល់ជាចំណុចសំអាងដ៏មានប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ថែមចំពោះខេត្តផ្សេងៗទៀតនៅពេលខាងមុខ។

## ៦.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវអាចនឹងជួបនូវបញ្ហាតិចតួចរួមមាន ភាពមិនពេញចិត្តទៅនឹងចម្លើយដែលឆ្លើយចំពោះសំណួរស្រាវជ្រាវ ឬចម្លើយដែលឆ្លើយតបមិនមែនចេញពីចិត្តស្មោះ។ បន្ថែមពីនេះទៀត អ្នកស្រាវជ្រាវអាចនឹងប្រឈមមុខទៅនឹងបញ្ហាខ្លះដោយសារតែនាយកសាលាដែលបានជ្រើសរើសមួយចំនួនមិនបានផ្តល់នូវលទ្ធផលនៃការប្រឡងប្រចាំខែចាស់ៗ។ ទាំងនេះគឺជាការកំណត់នូវដែនកំណត់ចំបងៗមួយចំនួនចំពោះការសិក្សាស្រាវជ្រាវនេះ។ អ្នកសិក្សាស្រាវជ្រាវសម្រាលបញ្ហាទាំងនេះដោយធានានូវភាពជឿជាក់នូវអត្តសញ្ញាណ និងការប្រើប្រាស់ចម្លើយដែលពួកគេបានជ្រើសរើសសម្រាប់ជាការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវផ្តោតអារម្មណ៍ទៅលើតែសាលាវិទ្យាល័យជំនាន់ថ្មីស្ថិតនៅក្នុងខេត្តកំពង់ចាមតែប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវនេះនឹងផ្តោតអារម្មណ៍ទៅលើលទ្ធផលសិក្សារបស់សិស្សានុសិស្សតាមរយៈ ការដឹកនាំ និងគ្រប់គ្រង គ្រូ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ក្រុមគោលដៅដែលត្រូវជ្រើសរើសយកមកសិក្សានៅក្នុងការស្រាវជ្រាវនេះគឺរួមមាននាយកសាលា លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៅសាលាវិទ្យាល័យជំនាន់ថ្មីទាំងពីរដែលបានជ្រើសរើស។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូកដូចខាងក្រោម

**ជំពូកទី១៖** ***សេចក្តីផ្តើម*** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ និងដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ "ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី" នៅក្នុងទីរួមខេត្តកំពង់ចាម។

**ជំពូកទី២៖** ***រំលឹកទ្រឹស្តី*** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីចាស់ៗពាក់ព័ន្ធនឹងប្រធានបទពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិនិងអន្តរជាតិ រដ្ឋធម្មនុញ្ញ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ និង

ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិតនិងជាទុនសម្រាប់ស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មី។

**ជំពូកទី៣៖** ***វិធីសាស្ត្រនៃការស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាក ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យរកតម្លៃមធ្យម និងភាគរយតាមរយៈកម្មវិធី SPSS និងកម្មវិធី Ms. Excel សម្រាប់សង់ក្រាហ្វិក និងផ្តុំទិន្នន័យបញ្ចូលគ្នា។

**ជំពូកទី៤៖** ***លទ្ធផលនៃការស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ ចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែងនៃលទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សដែលរួមមាននាយក គ្រូ និងសិស្សខ្លួនឯងដែលបម្រើឱ្យការបង្រៀន និងរៀននៅសាលាជំនាន់ថ្មីទទួលបានលទ្ធផលល្អប្រសើរ។

**ជំពូកទី៥៖** ***សេចក្តីសន្និដ្ឋាន និងសំណូមពរ*** ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនដល់ភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការបង្រៀន និងរៀនរបស់សិស្ស និងគ្រូនៅសាលាជំនាន់ថ្មីមានភាពល្អប្រសើរនិងទទួលបានប្រសិទ្ធភាពខ្ពស់ចំពោះលទ្ធផលសិក្សារបស់សិស្ស។

# ជំពូកទី២

# រំឭកទ្រឹស្តី

# ជំពូកទី២

# ការរំលឹកទ្រឹស្ដី

## ២.១ ពន្យល់ន័យនៃពាក្យគន្លឹះ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញថាអ្វីទៅជាប្រសិទ្ធភាព និងការអនុវត្ត

ប្រសិទ្ធភាពគឺភាពដែលធ្វើឱ្យសម្រេច ភាពដែលធ្វើឱ្យពូកែ ភាពដែលតាក់តែងហើយ (វចនានុក្រមសម្ដេចសង្ឃរាជជួន ណាត)

យោងទៅតាមវចនានុក្រម (Webster's New Riverside University Dictionary) បានឱ្យនិយមន័យប្រសិទ្ធភាពថាជានាមសព្ទដែលសំដៅទៅលើការផលិតបានផលិតផលដែលជាទីគាប់ចិត្តឬសមតាមបំណងពោលគឺជាលទ្ធផលដែលជាក់លាក់ហើយនិងពិតប្រាកដពាក្យប្រសិទ្ធភាពនិយាយសំដៅទៅស្ថាប័នមួយដែលទទួលសម្រេចបាននូវវត្ថុបំណងជាក់លាក់របស់ខ្លួន (Beare, Caldwell &Millikan, 1989:11)។

យោងទៅតាមអ្នកស្រាវជ្រាវភាគច្រើនបានឱ្យនិយមន័យនៃពាក្យប្រសិទ្ធភាពថាគឺជាការវាស់វែងនូវលទ្ធផលសិក្សារបស់សិស្ស។ ហេតុផលនេះគឺជាការពិតដោយសារតែគុណភាពនៃផលិតផលនៅសាលារៀនគឺសិស្សដែលជាធាតុដ៏សំខាន់បំផុតចំពោះប្រសិទ្ធភាពនៅសាលា(Westbrook, 1982, p.7។

អនុវត្ត មានន័យថាប្រព្រឹត្តតាម ធ្វើតាម យល់ស្របតាម បណ្ដោយតាម (វចនានុក្រមសម្ដេចសង្ឃរាជជួន ណាត)

## ២.២ ប្រវត្តិនៃសាលាជំនាន់ថ្មី

តាមរយៈការខិតខំប្រឹងប្រែងរបស់អង្គការខេប និងក្រសួងអប់រំ យុវជន និងកីឡារួមដៃ និងសហការគ្នាក្នុងការធ្វើឱ្យវិស័យអប់រំទទួលបានធនធានមនុស្សដែលមានជំនាញច្បាស់លាស់ និងមានសមត្ថភាពពេញលេញតាមរយៈគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) មានសមាសភាគបច្ចេកទេសចំនួន៤ គឺ (១)កសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងការស្វែងរកការគាំទ្រដើម្បីនិរន្តភាព (២)បង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ (៣)កែលម្អគ្រប់គ្រងសាលា

រៀន និងការចូលរួមពីសហគមន៍ (៤)កែលម្អបរិបទទំនាក់ទំនងអប់រំ (បង្កើតឡើងនៅខែតុលា ឆ្នាំ២០០៩ និងបញ្ចប់គម្រោងនៅខែកញ្ញាឆ្នាំ២០១៤) ដោយផ្តល់នូវសេវាគាំទ្រដើម្បីអភិវឌ្ឍសាលារៀន ដូចជាកម្មវិធីអាហារូបករណ៍ដល់កុមារក្រីក្រ ការអភិវឌ្ឍបណ្ណាល័យ ការបណ្តុះបណ្តាលគ្រូ និងការអប់រំបំណិនជីវិត។ (KAPE, Annual Report 2009) ព្រមជាមួយគ្នានេះផងដែរ អង្គការខេបក៏បានខិតខំប្រឹងប្រែងបង្កើតឡើងនូវគម្រោងសាលាដៃគូ(BSI)[1]មួយទៀត (ចាប់ផ្តើមនៅខែមករា ឆ្នាំ២០១១ និងបញ្ចប់គម្រោងនៅខែធ្នូ ឆ្នាំ២០១៦)ដែលមានការផ្ទេរប្រឌិតថ្មីសំដៅប្រែក្លាយសាលារៀនរដ្ឋទាំងបីរួមមានអនុវិទ្យាល័យអនុវត្តទីតាំងនៅសាលាវិក្រឹតការខេត្តកំពង់ចាម វិទ្យាល័យហ៊ុន សែន សួគ៌ ស្ថិតនៅស្រុកជើងព្រៃខេត្តកំពង់ចាម និងមួយទៀតគឺវិទ្យាល័យ សម្តេចម៉ែ ស្រុកត្បូងឃ្មុំ ទៅជាសាលាជំនាន់ថ្មីដែលអាចផ្តល់គំរូស្តង់ដាសិក្សាខ្ពស់ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ លើសពីនេះទៅទៀត គម្រោងនេះដោះស្រាយបញ្ហាកង្វះការទទួលខុសត្រូវរបស់គ្រូ និងគណៈគ្រប់គ្រងសាលាដែលជាជំងឺដ៏រាំរ៉ៃធ្វើឱ្យគុណភាពអប់រំធ្លាក់ចុះទន់ខ្សោយនៅតាមសាលារៀនជាច្រើននៅក្នុងប្រទេសកម្ពុជាតាមរយៈការជ្រើសរើសគ្រូបង្រៀនមានឆន្ទៈមោះមុត ដើម្បីបណ្តុះបណ្តាលគម្រូវិធីសាស្ត្រល្អៗក្នុងការបង្រៀន។ គម្រោង (BSI) មានបំណងកសាងសាលាជំនាន់ថ្មីសម្រាប់សិស្សានុសិស្សជំនាន់ថ្មី។ (BSI) បានសហការជាមួយមន្ទីរ លោកគ្រូអ្នកគ្រូ ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀនរួមគ្នាធ្វើឱ្យបរិស្ថានសិក្សា និងស្តង់ដានៃការសិក្សាមានគុណភាពប្រសើរឡើង។(KAPE, Annual Report 2011)

ជាលទ្ធផលសាលាទាំងបីក្រោយពីបានអនុវត្តគម្រោង (BSI) បានអនុវត្តនូវសកម្មភាពជាច្រើនដូចជាការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសិក្សា ការអនុវត្តកម្មវិធីសិក្សាបែបសហប្រត្តិការ ការបណ្តុះបណ្តាលគ្រូបង្រៀន ការអភិវឌ្ឍមាគ៌ាអាជីពគ្រូបង្រៀន ការតំឡើងនិងប្រើប្រាស់បន្ទប់កុំព្យូទ័រ និងបន្ទប់ពិសោធន៍ ការអនុវត្តសកម្មភាពកម្មវិធីបំណិនជីវិត(ដូចជាការដាំបន្លែ ការចិញ្ចឹមត្រី ការចិញ្ចឹមកង្កែបនិងសួនជីវៈចំរុះ) និងការបង្កើតក្រុមប្រឹក្សាតាមដានសាលារៀនគោលដៅ។(KAPE, Annual Report 2012)

[1] a public-private partnership between Kampuchean Action for Primary Education (KAPE) and the provincial government of Kampong Cham

គម្រោងសាលារៀនដៃគូ (BSI) បានស្វែងរកគន្លងអភិវឌ្ឍជាច្រើនសម្រាប់សាលារដ្ឋដោយផ្អែកលើលក្ខណៈអំណោយផលរបស់សាលាក្នុងការប្រើប្រាស់ជំនួយបច្ចេកទេស និងសង្កត់ធ្ងន់ទៅលើរចនាសម្ព័ន្ធអភិបាលកិច្ចពិសេសដែលធានាឱ្យការប្រើប្រាស់ធនធានទាំងអស់ និងការឧបត្ថម្ភគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវដោយផ្អែកលើភារកិច្ចបន្ថែមដែលគ្រូបង្រៀនបានបំពេញ។ ក្រោយមកអង្គការខេបបានចរចារប្រកបដោយភាពជោគជ័យជាមួយក្រសួងអប់រំ យុវជន និងកីឡា សំដៅបង្កើតនូវគំរូការគ្រប់គ្រងពាក់កណ្តាលឯកជន និងពាក់កណ្តាលរដ្ឋនៅសាលារដ្ឋទាំងបីនេះដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តដោយធ្វើយ៉ាងណាធានាថាមានការទទួលខុសត្រូវខ្ពស់ទៅលើការប្រើប្រាស់ធនធាន។ គំរូថ្មីៗនៃសាលារៀនទាំងបីនេះត្រូវយកលំនាំតាមសាលារៀន Charter Schools[2] ប៉ុន្តែតម្រូវនឹងបរិបទពិសេសដោយឡែករបស់កម្ពុជា។គំរូថ្មីនៃការអប់រំនេះផ្តោតការយកចិត្តទុកដាក់ទៅលើបច្ចេកទេសសិក្សាទំនើបតាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា (ICT)។

ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានទៅចូលរួមទស្សនាការអនុវត្តសាកល្បងនៃគម្រោងសាលារៀនដៃគូរបស់អង្គការ(ខេប)ក្នុងសាលាបឋមសិក្សាអនុវិទ្យាល័យ ហ៊ុន សែន អនុវត្តខេត្តកំពង់ចាម និងជាបុព្វហេតុបណ្តាលឱ្យកើតមានសិក្ខាសាលាថ្នាក់ជាតិដ៏ធំមួយស្តីពីការបង្កើត **សាលារៀនជំនាន់ថ្មី** ដែលគាំទ្រថវិកាដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងក្រសួងអប់រំ យុវជន និងកីឡា។ គួរឱ្យកត់សម្គាល់ផងដែរថា អង្គការ(ខេប)បន្តនាំមុខគេក្នុងវិស័យអប់រំផ្នែកបច្ចេកវិទ្យា និងការអភិវឌ្ឍគំរូសាលាធម្មនុញ Charter Schools នៅក្នុងបរិបទប្រទេសកម្ពុជា។ រហូតមកដល់ពេលនេះ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលយកអង្គការ(ខេប)ធ្វើជា

[2] សាលាធម្មនុញ្ញត្រូវបានដាក់ឱ្យអនុម័តនៅឆ្នាំ១៩៩១ នៅរដ្ឋមីនីសូតាសហរដ្ឋអាមេរិក (en.wikipedia.org) វាជាសាលារដ្ឋដំណើរការដោយឯករាជដោយត្រូវបានផ្តល់ការបត់បែនទៅតាមការប្រតិបត្តិការណ៍របស់ខ្លួនប្រកបដោយគណនេយ្យភាព (uncommonschools)។ លោកបណ្ឌិត ហង់ ជួនណារ៉ុន បានពន្យល់ថា៖ «សាលាធម្មនុញ្ញគឺជាសាលារៀនសាធារណៈ ប៉ុន្តែសហគមន៍អាចចូលរួមជួយអ្នកក្រីក្របាន។ ឪពុកម្តាយអាចផ្តល់ថវិកាបន្ថែម។

ដៃគូកំណែទម្រង់ការអប់រំថ្មីតាមរយៈគម្រោងសាលារៀនជំនាន់ថ្មី ឬហៅកាត់ថា(NGS)។ ការផ្តួចផ្តើមគម្រោងថ្មីនេះមានសក្តានុពលចំពោះការផ្លាស់ប្តូរប្រព័ន្ធអប់រំទូលំទូលាយ ដែលផ្តោតលើស្វ័យភាពសាលា អភិបាលកិច្ចល្អ និងគុណភាពខ្ពស់។គម្រោងនេះផ្អែកលើគំរូសាលាធម្មនុញ Charter Schools នៅអាមេរិកខាងជើងនិង Academies នៅចក្រភពអង់គ្លេសដែលបានអភិវឌ្ឍចេញពីគម្រោងសាលារៀនដៃគូ (BSI) ឧបត្ថម្ភដោយមូលនិធិ (OAK TREE)។ បន្ថែមលើនេះទៀត អង្គការ(ខេប)បានធ្វើកិច្ចចរចារព្រមព្រៀងដោយជោគជ័យជាមួយក្រសួងអប់រំ យុវជន និងកីឡាលើកំណែទម្រង់គម្រោងសាលារៀនជំនាន់ថ្មី (NGS) ហើយក្រសួងបានប្តេជ្ញាផ្តល់មូលនិធិផ្ទាល់ដល់អង្គការ(ខេប)ជាង ៧០០ ០០០ ដុល្លាអាមេរិកសម្រាប់ដំណើរការគម្រោងនេះនៅឆ្នាំ២០១៦ - ២០១៧ រួមទាំងធ្វើការសិក្សាស្រាវជ្រាវទូទាំងប្រទេសដើម្បីកំណត់សក្តានុពលបន្ថែមសម្រាប់គម្រោង (NGS) និងការបង្កើតគោលនយោបាយ។ (KAPE, Annual Report 2015)

ក្រសួងអប់រំ យុវជន និងកីឡា បានជ្រើសរើសអង្គការ(ខេប)ឱ្យធ្វើការស្ទង់មតិដើម្បីធ្វើការកំណត់ទីកន្លែងដែលមានសក្តានុពលសម្រាប់ពង្រីកសាលារៀនជំនាន់ថ្មីនៅក្នុងខេត្តដែលបានជ្រើសរើស។ លក្ខខណ្ឌនៃការជ្រើសរើសទីកន្លែងសម្រាប់ការពង្រីកសាលារៀនជំនាន់ថ្មីរួមមានបីចំណុច **១. សាលារៀនថ្មីដែលមិនទាន់មាន** (គឺជាសាលាដែលមិនទាន់បង្កើតប៉ុន្តែប្រហែលជាមាននៅក្នុងគម្រោង) **២. សាលារៀនដែលមានស្រាប់**(គឺជាសាលាដែលមានការចុះឈ្មោះថេរ) **៣. សាលាដែលជិតដាច់ខ្យល់ដែលបាត់បង់សិស្សនិងរួមតូចទៅៗ** (គឺជាសាលាដែលបាត់បង់សិស្សតាមរយៈការទាក់ទាញរបស់សាលាឯកជន ឬការផ្លាស់ប្តូរសាលាថ្មីដោយសាលាមានស្តង់ដា និងការគ្រប់គ្រងធ្លាក់ចុះ)។ ទីកន្លែងដែលមានសក្តានុពលសម្រាប់ពង្រីកសាលារៀនជំនាន់ថ្មីមានតែ១០ខេត្តក្រុងទេតាមការផ្តល់របស់ក្រសួងរួមមាន ១. ខេត្តបាត់ដំបង ២. ខេត្តកំពង់ស្ពឺ ៣. ខេត្តកំពត់ ៤. ខេត្តកណ្តាល ៥. រាជធានីភ្នំពេញ ៦. ខេត្តព្រៃវែង ៧. ខេត្តសៀម រាប ៨. ខេត្តស្ទឹង ត្រែង ៩. ខេត្ត តាកែវ ១០. ខេត្តកំពង់ចាម។ តាមការស្ទង់មតិ និងធ្វើការស្រាវជ្រាវរបស់អង្គការ (ខេប) មានខេត្តចំនួន៥ដែលមានសក្តានុពលខ្ពស់ក្នុងការពង្រីកសាលារៀនជំនាន់ថ្មីរួមមាន ខេត្តបាត់ដំបង ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្ត

ស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ ខេត្តចំនួន២ដែលមានសក្តានុពលល្អបង្គួរក្នុងការពង្រីកសាលារៀនជំនាន់ថ្មីរួមមានខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប និងខេត្តចំនួន៣ដែលមិនមានសក្តានុពលក្នុងការពង្រីកសាលារៀនជំនាន់ថ្មីគឺខេត្តកំពត ខេត្តតាកែវ និងខេត្តកំពង់ចាម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក្រសួងអប់រំ យុវជន និងកីឡាខ្លួនឯងតម្រូវឱ្យមានយ៉ាងហោចណាស់មួយខេត្តមានមួយសាលា។ (NGSNS, Sep 2016)

នៅទីបំផុតសមិទ្ធផលកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តល់ហិរញ្ញប្បទានដល់អង្គការ(ខេប)បានធ្វើឱ្យអង្គការនេះកាន់តែរឹងមាំ និងជួយជំរុញការឧបត្ថម្ភគាំទ្រដល់ដំណើរការសាលារៀនធម្មនុញទៅមុខនៅក្នុងប្រព័ន្ធអប់រំសា-ធារណៈនៅកម្ពុជា។ មិនតែប៉ុណ្ណោះគម្រោងសាលារៀនជំនាន់ថ្មីបានក្លាយទៅជាកម្មវិធីសំខាន់បំផុត មានសក្តានុពលធ្វើឱ្យមានការផ្លាស់ប្តូររបៀបគិតរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយអំពីអភិបាលកិច្ចរបស់សាលារៀនសាធារណៈ។ ជាពិសេសនៅខែមករា ឆ្នាំ២០១៦ អង្គការ (ខេប) មានមហាកិត្តិយសបានទទួលស្វាគមន៍ដំណើរទស្សនកិច្ចសិក្សាពីសមាជិករដ្ឋសភាជាតិមកពីគណៈកម្មការទី៧ដែលដឹកនាំដោយឯកឧត្តម ញ៉ែម បុញ្ញឫទ្ធិ ប្រធានគណៈកម្មការទី៧នៃរដ្ឋសភានៅសាលាគំរូ ដែលជាសាលាធម្មនុញទី១នៅកម្ពុជា ដើម្បីស្វែងយល់ពីកំណែទម្រង់អប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងគម្រោងសាលារៀនជំនាន់ថ្មី។ លោក សឿង វ៉ាន់ ជានាយកសាលា ហ៊ុន សែន អនុវត្តបានធ្វើបទបង្ហាញជូនគណៈប្រតិភូអំពីចក្ខុវិស័យរបស់អង្គការ (ខេប) ក្នុងការបង្កើតសាលារៀនរដ្ឋស្វ័យតដែលយើងហៅថា សាលារៀនជំនាន់ថ្មី។ ដោយសារការខិតខំប្រឹងប្រែង និងទទួលបានហិរញ្ញប្បទានពីក្រសួង អង្គការ (ខេប) នៅទីបំផុតបានបើកសម្ពោធគម្រោងសាលារៀនជំនាន់ថ្មីជាផ្លូវការនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ដោយត្រូវបានអញ្ជើញចូលរួមពីភ្ញៀវកិត្តិយសសំខាន់ៗដូចជា ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន (ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន (រដ្ឋមងន្ត្រីក្រសួងអប់រំ យុវជន និងកីឡា) និងឯកឧត្តម ហ៊ុន ម៉ាណែត (ប្រធានសមាគនអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ)។

បន្តមកទៀតអង្គការ (ខេប) និងក្រសួងអប់រំ យុវជន និងកីឡាបានខិតខំបង្កើតគោល

នយោបាយស្តីពីសាលារៀនជំនាន់ថ្មី ក្រោយពេលបញ្ចប់ការបង្កើតគោលនយោបាយសាលារៀនជំនាន់ថ្មី ឯកសារនេះត្រូវបានដាក់ឱ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាចុះហត្ថលេខាអនុម័តនៅអំឡុងកាលពីខែសីហាឆ្នាំ២០១៦។ នៅទីបំផុតការអនុវត្តសាកល្បងលំនាំកម្មវិធីសាលារៀនធម្មនុញ្ញនៅកម្ពុជាបានប្តូរមកហៅថា សាលារៀនជំនាន់ថ្មី។ (KAPE, Annual Report 2016)

លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា «សាលារៀនជំនាន់ថ្មីផ្តល់នូវគំរូវិធីសាស្ត្រគ្រប់គ្រងចម្រុះដែលអនុញ្ញាតឱ្យសហគមន៍មានឱកាសចូលរួមក្នុងការគ្រប់គ្រងសាលារដ្ឋ ហើយសាលារៀនអាចមានការបត់បែនក្នុងការអនុវត្តកម្មវិធីសិក្សាផងដែរ» ហើយលោកក៏បានបន្តថា «ខ្ញុំគិតថានេះហើយជាហេតុផលដែលយើងសម្រេចចិត្តប្រគល់កម្មវិធីសាលារៀនជំនាន់ថ្មីទៅក្នុងដៃ -របស់ KAPE ព្រោះពួកគេបង្រៀនសិស្សអំពីជំនាញដែលត្រូវការចាំបាច់នៅក្នុងសតវត្សរ៍ទី២១ មិនមែនតែចំណេះដឹងទូទៅ និងអក្ខរកម្មនោះទេ ប៉ុន្តែក៏មានជំនាញ ICT និងជំនាញភាសាបរទេសផងដែរ។ ពួកគេក៏ត្រូវមានការយល់ដឹងពីជីវិតពិត ជំនាញក្នុងការប្រាស្រ័យទាក់ទង ការគិតស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការទំនាក់ទំនង»។ (postkhmer.com, 10 October 2017)

## ២.៣ ស្ថានភាពសាលារៀនជំនាន់ថ្មីបច្ចុប្បន្ន

បើតាមការបញ្ជាក់របស់ លោក សម្ប កំសាន្ត សាលារៀនជំនាន់ថ្មីសព្វថ្ងៃនេះនិងប្រសាសន៍ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាថាក្រសួងបង្កើតសាលារៀនជំនាន់ថ្មីបានចំនួន១១សាលាហើយនៅទូទាំងប្រទេសរហូតមកដល់ឆ្នាំសិក្សា២០១៨-២០១៩នេះដែលរួមមាន

| ល.រ | ឈ្មោះសាលា | ភូមិ | ឃុំ | ស្រុក/ខ័ណ្ឌ | ខេត្ត/ក្រុង | ចំនួនម៉ោង | ប្រាក់ឧបត្ថម្ភក្នុង១ឆ្នាំ |
|---|---|---|---|---|---|---|---|
| ១ | វិទ្យាល័យព្រះស៊ីសុវត្ថិ | ភូមិ២ | ផ្សារថ្មី៣ | ដូនពេញ | ភ្នំពេញ | ៤០ ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ២ | វិទ្យាល័យហ៊ុនសែនកំពង់ចាម | វាល៥ | វាលវង់ | កំពង់ចាម | កំពង់ចាម | ៤០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៣ | វិទ្យាល័យព្រែកលៀប | ព្រែកលាប | ព្រែកលាប | ឫស្សីកែវ | ភ្នំពេញ | ៤០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៤ | វិទ្យាល័យសម្តេចជាស៊ីព្រែកអញ្ចាញ | ភូមិកណ្តាល | ព្រែកអញ្ចាញ | មុខកំពូល | កណ្តាល | ៤០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៥ | វិទ្យាល័យហ៊ុនសែនពាមជីកង | ពាមជីកង | ពាមជីកង | កងមាស | កំពង់ចាម | ៤០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | អនុវិទ្យាល័យគោកព្រីង | ស្វាយព្រហូត | គោកព្រីង | ស្វាយជ្រុំ | ស្វាយរៀង | ៥០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៧ | សាលាបឋមសិក្សាហ៊ុនសែនកំពង់ចាម | វាល៦ | វាលវង់ | កំពង់ចាម | កំពង់ចាម | ៣៥ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៨ | សាលាបឋមសិក្សាព្រះរាជអគ្គមហេសីនរោត្តមមុនីនាថ សីហនុ | ឧត្តុង | វាំងចាស់ | ឧត្តុង | កំពង់ស្ពឺ | ៣៥ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ៩ | សាលាបឋមសិក្សាអង្គរបាន | អង្គរបាន៦ | អង្គរបាន | កងមាស | កំពង់ចាម | ៣៥ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ១០ | សាលាបឋមសិក្សាស្វាយព្រហូត | ស្វាយព្រហូត | គោកព្រីង | ស្វាយជ្រុំ | ស្វាយរៀង | ៣៥ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |
| ១១ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវន្តជំនី | ស្វាយដំណាក់ | ជំនីក | ក្រូចឆ្មារ | ត្បូងឃ្មុំ | ៥០ម៉ | ៣០០ $ (ការស្ម័គ្រចិត្ត) |

ប៉ុន្តែសាលាដែលដំណើរការពេញលេញមានតែ៤សាលាប៉ុណ្ណោះ គឺសាលាព្រះស៊ីសុវត្ថិនៅភ្នំពេញ វិទ្យាល័យព្រែកលាភនៅភ្នំពេញ វិទ្យាល័យជាស៊ីមព្រែកអញ្ចាញនៅខេត្តកណ្ដាល និងវិទ្យាល័យ ហ៊ុន សែន អនុវត្ត នៅកំពង់ចាមសម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨។

លើសពីនេះទៀត សាលារៀនជំនាន់ថ្មីគឺជាកម្មវិធីកំណែទម្រង់ប្រព័ន្ធអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាមាគ៌ាអភិវឌ្ឍន៍ថ្មីមួយ នៅក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្នដែលជួយបង្កើតសាលារៀនសាធារណៈស្វយ័ត។

សាលាជំនាន់ថ្មីត្រូវបានបង្រៀនសិស្សផ្ដោតសំខាន់មុខវិជ្ជាស្ទែម (STEM) និងបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ជាពិសេសគឺការអប់រំបែបសតវត្សរ៍ទី២១មិនមែនចំណេះដឹងទូទៅ និងអក្ខរកម្មនោះទេ ប៉ុន្តែជាចំណេះដឹងខាងជំនាញ និងជំនាញភាសាអង់គ្លេសដែលជាតម្រូវការទីផ្សារដ៏ចាំបាច់សម្រាប់ពេលបច្ចុប្បន្ន និងអនាគត។

ការអប់រំបែបសតវត្សរ៍ទី២១រួមមាន ការបង្កើតថ្មី ការយល់ដឹងពីវប្បធម៌ ការដោះស្រាយបញ្ហា នវានុវត្តន៍ ការចូលរួមសកម្មភាពក្នុងសង្គម ការប្រាស្រ័យទំនាក់ទំនង ការសហប្រតិបត្តិការ គណនេយ្យភាពការរុករក និងស្រាវជ្រាវ ការផ្ដើមគំនិតការទទួលខុសត្រូវ និងភាពជាអ្នកដឹកនាំ។

ហេតុនេះហើយបានជានៅសាលារៀនជំនាន់ថ្មីតម្រូវឱ្យធ្វើការជ្រើសរើសនាយក លោកគ្រូអ្នកគ្រូតាមរយៈការប្រឡងប្រកួតប្រជែង និងសិស្សដែលត្រូវមកចូលរៀននៅសាលារៀននេះក៏ត្រូវធ្វើតេស្តជាមុនដែរមុននឹងដាក់ពាក្យចូលរៀននៅទីនេះ។ ពោលគឺយើងត្រូវ

ការនាយកបែបនាយកសតវត្សរ៍ទី២១ និងលោកគ្រូអ្នកគ្រូបែបសតវត្សរ៍ទី២១ដើម្បីមកដឹកនាំ និងបង្រៀនសិស្សានុសិស្សឱ្យត្រូវទៅនឹងចំណេះដឹងសតវត្សរ៍ទី២១ដែរ។ (**គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី**)

លើសពីនេះទៅទៀតចំពោះនាយកសាលាសតវត្សរ៍ទី២១ចាំបាច់ត្រូវមានបំណិនវិជ្ជាជីវៈដែលលើសពីការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ ឬបំណិនគ្រប់គ្រងបែបប្រពៃណីដែលធ្លាប់ត្រូវបានគេអនុវត្តកន្លងមក។ បំណិនទាំងនេះត្រូវបានគេហៅថាជាបំណិនសតវត្សរ៍ទី២១រួមមានការបង្កើតថ្មី (ប្រឌិតញ្ញាណ) ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការទំនាក់ទំនង និងការសម្របសម្រួល។

សំខាន់ជាងនេះ បំណិននាយកសាលាសតវត្សទី២១នេះជួយនាយកសាលាក្នុងការ

- អនុវត្តនូវភារកិច្ចនៃការដឹកនាំ និងគ្រប់គ្រងនិងការទទួលខុសត្រូវនានា
- ប្រើប្រាស់ស្វ័យភាពសាលារៀន និងគណនេយ្យភាព
- អនុវត្តនូវឱកាសនៃការកែលម្អសាលារៀន
- បង្កើតទំនុកចិត្តនៃភាពអ្នកដឹកនាំអង្គការចាត់តាំងនានានៅកម្រិតសាលារៀន

(**ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ,២០១៦**)

គ្រូល្អអាចជម្រុញក្តីសង្ឃឹម អាចបញ្ឆេះការស្រមើស្រមៃ និងបង្កើតឱ្យមានសេចក្តីស្រឡាញ់ក្នុងការរៀនសូត្រ។ **ម៉ាកហេនរី**

គ្រូបង្រៀននៅសតវត្សរ៍ទី២១ ត្រូវគិតគូរពីតំរូវការរបស់សិស្ស និងរៀបចំឱ្យពួកគេឆ្លើយតបនឹងបញ្ហាប្រឈមនៃអនាគត។ ចំពោះគ្រូ ការបង្កើតកម្លាំងបង្រៀនជំនាញវិជ្ជាជីវៈដែលមានគុណភាពខ្ពស់ វាមានសារៈសំខាន់ណាស់ ដើម្បីជួយសិស្សឱ្យអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈដែលមានគុណភាពខ្ពស់បាន។ ទៀតសោតកម្មវិធីអភិវឌ្ឍត្រូវតែរួមបញ្ចូលការប្រើប្រាស់សមាហរណកម្មបច្ចេកវិទ្យាក្នុងការបង្រៀន។ សមត្ថភាពគ្រូបង្រៀនបែបសតវត្សរ៍ទី២១រួមមាន

- **រៀបចំថ្នាក់រៀនជាថ្នាក់សិស្សមជ្ឈមណ្ឌល និងការណែនាំជាលក្ខណៈផ្ទាល់ខ្លួន** វិធីបញ្ចុក ឬបញ្ច្រកបាយក្នុងមាត់ត្រូវបានបញ្ចប់ហើយនៅយុគ្គសម័យបច្ចេកវិទ្យានេះ។ គឺជាការចង់បានដើម្បីផ្តល់ការណែនាំជាលក្ខណៈផ្ទាល់ខ្លួនដល់សិស្សម្នា-

ក់ៗពីព្រោះពួកគេមានបុគ្គលិកលក្ខណៈ គោលដៅ គោលបំណង តម្រូវការខុសគ្នាៗ និងគួរអនុញ្ញាតឱ្យសិស្សជ្រើសរើសដោយខ្លួនឯងនូវការលើកទឹកចិត្តក្នុងការបង្កើនការខិតខំប្រឹងប្រែងរៀនសូត្រ។

- **សិស្សជាអ្នកផលិត៖** សព្វថ្ងៃនេះសិស្សត្រូវបានគេចាត់ទុកថាជាជនជាតិដើមឌីជីថល និងជាអ្នកផលិតមាតិកាឌីជីថលណាមួយ។ សិស្សត្រូវបានភ្ជាប់ជាមួយឧបករណ៍ថ្មីៗ និងល្អបំផុត ទោះបីជាពួកគេកម្រប្រើវាលើសពីការប្រាស្រ័យទាក់ទងជាមួយគ្រួសារ និងមិត្តភក្តិក៏ដោយ។ សិស្សគ្រប់រូបមានឧបករណ៍ថ្លៃៗដែលមានសមត្ថភាពក្នុងការបង្កើតប្លុក (blogs) បង្ហាញព័ត៌មានច្បាស់ៗ និងការបង្រៀន។ តែពេលខ្លះសិស្សនៅតែត្រូវបានគេសុំឱ្យបិទឧបករណ៍ទាំងនេះហើយងាកមករៀនតាមរយៈឯកសារដែលលោកគ្រូអ្នកគ្រូចែកឱ្យទៅវិញ។ ផ្ទុយទៅវិញនៅពេលយើងផ្តល់ឱកាសដល់ពួកគេ ពួកគេអាចបង្កើតគំនិតច្នៃប្រឌិតប្លុកបានរឿងរ៉ាវផ្សេងៗ និងមានមោទនភាពក្នុងការចែករំលែកជាមួយអ្នកដទៃទៀតផង។
- **ការសិក្សាផ្អែកលើគំរោង** (PBL) ៖ជាវិធីសាស្ត្របង្រៀនមួយដែលជំរុញនិងលើកទឹកចិត្តឱ្យសិស្សរៀននិងប្រើប្រាស់ចំណេះដឹង ជំនាញតាមរយៈការផ្សារភ្ជាប់បទពិសោធន៍របស់ពួកគេ។ ជាពិសេសកម្មវិធីសិក្សានេះផ្តោតអារម្មណ៍លើការភ្ជាប់ទំនាក់ទំនងសិស្សទៅ នឹងបញ្ហាពិភពលោកជាក់ស្តែង ពីព្រោះបញ្ហាទាំងនេះមិនអាចយកព័ត៌មាន ឬចំណេះដឹងតែមួយជ្រុងទៅដោះស្រាយបានទេ គឺតម្រូវឱ្យសិស្សចេះប្រើប្រាស់ចំណេះដឹង និងជំនាញផ្សេងៗមកដាក់បញ្ចូលគ្នាដើម្បីស្វែងរកដំណោះស្រាយ។
- **រៀនបច្ចេកវិទ្យាថ្មី៖** តម្រូវការសំខាន់សម្រាប់ការផ្តល់ការអប់រំប្រកបដោយគុណភាពគឺបច្ចេកវិទ្យារួមបញ្ចូលជាមួយនឹងការបង្រៀនដើម្បីបង្កើតបរិយាកាសសិក្សាសម្រាប់បំពេញសេចក្តីត្រូវការរបស់សិស្សានុសិស្សក្នុងការសិក្សា។ បច្ចេកវិទ្យាថ្មីគឺថ្មីសម្រាប់អ្នកចាប់ផ្តើមដំបូង។
- **ជាមនុស្សដែលចង់ដឹងចង់ចេះពីសកលលោក៖** សព្វថ្ងៃនេះគឺមានលក្ខណៈងាយស្រួលជាងបើយើងចង់ដឹងពីប្រទេសផ្សេងៗនៅលើសកលលោក តាមរយៈការ

បង្រៀនសិស្សប្រើឧបករណ៍ឌីជីថលដែលពួកគេមាន ដើម្បីស្វែងរកជ្រុងណាមួយនៃពិភពលោកនេះ និងជួយជំរុញឱ្យខ្លួនឯងកាន់តែមានចំណេះដឹងប្រសើរឡើង ។

- **ឈ្លាសវៃ និងចេះប្រើប្រាស់ទូរស័ព្ទវៃឆ្លាត៖** សិស្សគួរតែត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ឧបករណ៍របស់ពួកគេជាឧបករណ៍មានតម្លៃដែលជួយផ្តល់ចំណេះដឹងដល់ពួកគេ។ បង្រៀនសិស្សពីរបៀបស្វែងរកចម្លើយដែលពួកគេត្រូវការ និងប្រាប់សិស្សពីវេបសាយល្អសម្រាប់សិស្សសិក្សារៀនសូត្រ និងស្រាវជ្រាវ។ ទាំងនេះជាការលើកទឹកចិត្តដល់សិស្សម្នាក់ៗក្នុងការរៀនសូត្រ និងអនុញ្ញាតឱ្យសិស្សជ្រើសរើសអ្វីដែលជាវិធីសាស្ត្រសមស្របក្នុងការសិក្សារៀនសូត្រ។
- **ប្លុក** (blogs)៖ ប្លុកគឺជាសកម្មភាពអាជីពមួយ។ ការប្រើប្រាស់ប្លុកក្នុងការអប់រំបង្កើតផលប្រយោជន៍ជាច្រើន ពីព្រោះយើងអាចប្រើជាវេទិកាមួយក្នុងការដាក់កិច្ចការផ្ទះ កិច្ចការស្រាវជ្រាវ គម្រោងនានា សុំជំនួយ និងចែករំលែកធនធានផ្សេងៗ។ ប្លុកជួយបង្កើតការគិតត្រិះរិះពិចារណា និងគិតបែបវិភាគ និងជួយបង្កើតទំនាក់ទំនងសង្គមជាមួយអ្នកដទៃបានច្រើន។
- **សហការ៖** បច្ចេកវិទ្យាផ្តល់នូវឧបករណ៍ថ្មីៗដ៏មានឥទ្ធិពលដើម្បីជួយដល់ការប្រាស្រ័យទាក់ទងគ្នានៅថ្នាក់រៀន។ វាជួយឱ្យមានការសហការគ្នារវាងសិស្សនិងគ្រូដើម្បីធ្វើឱ្យសកម្មភាពថ្នាក់រៀនស្រដៀងទៅនឹងពិភពលោកពិតៗតាមរយៈការបង្កើតធនធានឌីជីថល ការបង្រៀន ការធ្វើបទបង្ហាញ និងគម្រោងរួមគ្នា ។
- **កសាងប្លង់ឌីជីថលវិជ្ជមាន៖** គ្រូណែនាំសិស្សពីរបៀបប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមរបៀបផលិត ផ្សព្វផ្សាយមាតិកាសំខាន់ៗ និងបង្កើតធនធានដែលអាចចែករំលែកបាន។ អក្ខរកម្មឌីជីថលគឺជាញឹកញាប់ត្រូវបានគេកំណត់ថាជា" អក្ខរកម្មក្នុងសតវត្សរ៍ទី២១"។
- **ច្នៃប្រឌិត៖** គោលបំណងសំខាន់នៅពីក្រោយការច្នៃប្រឌិតថ្មីណាមួយនៅក្នុងប-ច្ចេកវិទ្យាគឺដើម្បីផ្តល់នូវផាសុកភាព ផលិតភាព និងធ្វើឱ្យជីវិតកាន់តែប្រសើរ។ គ្រូត្រូវពង្រីកការបង្រៀន និងសាកល្បងកម្មវិធីថ្មីៗជំនួសសៀវភៅគោលដោយប្រើធនធានគេហទំព័របង្រៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គមវិញ។

- **បន្តការរៀនសូត្រៈ** ពីមួយថ្ងៃទៅមួយថ្ងៃវិធីសាស្ត្របង្រៀនថ្មីៗ និងបច្ចេកវិជ្ជាថ្មីៗ កំពុងរីកចម្រើនទៅមុខឥតឈប់ឈរ។ មនុស្សយើងត្រូវតែសម្របខ្លួនជាមួយបច្ចេកវិទ្យាដែលកំពុងរីកចម្រើនថ្មីៗ និងរៀនពីវា។ គ្រូបង្រៀនមានតួនាទីសំខាន់ណាស់។ គ្រូបង្រៀនមានការទទួលខុសត្រូវដ៏ធំធេងក្នុងការផ្លាស់ប្តូរជីវិតរបស់សិស្សម្នាក់ៗ។ គ្រូគឺជាឆ្អឹងខ្នងនៃសង្គម។ គ្រូបង្រៀនដើរតួជាអ្នកធ្វើកំណែទម្រង់សង្គម។ គ្រូបង្រៀនមានគុណភាពសម្រាប់ការអប់រំប្រកបដោយគុណភាពគឺពិតជាសំខាន់ណាស់។ (Teacher of 21st century: Characteristics and Development, research paper on 9, 2017)

ទៀតសោតក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធ្វើកំណែទម្រង់អប់រំដែលមានទាំងអស់ចំនួន១៥ ដើម្បីលើកកំពស់វិស័យអប់រំ និងសាងសមត្ថភាពសមស្របដល់សិស្សានុសិស្សដើម្បីចាប់យកជំនាញដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅ-ពេលបច្ចុប្បន្ន និងអនាគតដែលក្នុងកំណែទម្រង់ទាំងអស់មានកំណែទម្រង់មួយគឺកំណែទម្រង់ទី១៤ គឺការបង្កើតសាលារៀនជំនាន់ថ្មីនេះដើម្បីបណ្តុះបណ្តាលធនធានមនុស្សឱ្យត្រូវទៅតាមបដិវត្តឧស្សាហកម្មទី៤.០ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ២០៣០។

សាលាជំនាន់ថ្មីនេះពិតជាសាលាមួយដែលនឹងបណ្តុះបណ្តាលធនធានមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីឈានជើងចូលក្នុងបណ្តាញការងារក្នុងសម័យបដិវត្តឧស្សាហកម្មទី៤.០ដែលផ្តោតសំខាន់ទៅតាមប្រភេទរូបសាស្ត្រ (ការបោះពុម្ព3D បច្ចេកវិទ្យារ៉ូបូត រថយន្តដំណើរការស្វ័យប្រវត្តិ ) ប្រភេទឌីជីថល (ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត Internet of Things ឬ LoTនិងឧបករណ៍កំណត់សញ្ញា Sensor) និងប្រភេទជីវសាស្ត្រ (បច្ចេកវិទ្យា Gene Sequencing និង Gene Editing)។ (ឧស្សាហកម្មទី៤.០)

សាលានេះខុសប្លែកពីសាលាដទៃដូចជាប្រតិបត្តិប្រកបដោយស្វ័ភាព បង្ហាញស្តង់ដាវិជ្ជាជីវៈខ្ពស់ តម្រូវការគណនេយ្យភាពតឹងរឹង និងប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាព ជា

ពិសេសនៅសាលារៀននេះមានសេវាពិសេសដល់សិស្សានុសិស្សផងដែរ ដូចជាប-ណ្ណាល័យអេឡិចត្រូនិក សាលាសតវត្សរ៍ទី២១ សេវាប្រឹក្សា ខ្លឹបមុខវិជ្ជា ការអប់រំបំណិ-នជីវិត និងវាយតម្លៃ រៀនតាមកម្មវិធីកុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិក។

មិនតែប៉ុណ្ណោះ ប្រព័ន្ធអប់រំនៅសាលាជំនាន់ថ្មីកំពុងតែផ្តល់នូវផ្លូវដើរមួយដែលច្បាស់លាស់សម្រាប់មេដឹកនាំជំនាន់ក្រោយដើម្បីតម្រង់ទិសប្រទេសកម្ពុជាឱ្យឈាន - ដើងចូលក្នុងសតវត្សរ៍ទី២១ និងបង្កើតធនធានមនុស្សដែលត្រូវការក្នុងការធានានូវអនាគតដែលពោពេញដោយស្ថិរភាព និងវិបុលភាពនៅគ្រប់ស្រទាប់នៃសង្គម។

យោងទៅតាមឯកឧត្តម ឡោ ឆវណ្ណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ និងជាប្រធានក្រុមប្រឹក្សាភិបាលកម្មវិធីសាលាជំនាន់ថ្មី បានមានប្រសាសន៍ថា៖ សាលាជំនាន់ថ្មីនេះត្រូវរៀបចំឱ្យមានស្តង់ដារល្អដោយគិតគូរទាំងសិស្ស និងសាស្ត្រាចារ្យ ព្រោះយើងក៏បានរៀបចំបន្ទប់សម្រាប់សាស្ត្រាចារ្យ ដែលក្រោយពីបង្រៀនចប់ គាត់អាចមកសម្រាកនៅបន្ទប់សាស្ត្រាចារ្យ ពិភាក្សា ដោះស្រាយលើបញ្ហាដែលគាត់ជួបប្រទះផងដែរ និងបន្ថែមទៀតសាលានេះបំពាក់ឧបករណ៍បង្រៀនអេឡិចត្រូនិក ប្រើ LCD តុ កៅអីសម្រាប់រៀនស្អាត និងបានរៀបចំឱ្យមានបណ្ណាល័យទំនើប ដែលគេតែងនាំគ្នានិយាយថា បណ្ណាល័យសតវត្សរ៍ទី២១ ដោយយើងបំពាក់ដោយសៀវភៅច្រើនមុខ។ ក្រៅពីនោះក៏មានបំពាក់ទៅដោយ Internet ដើម្បីឱ្យសិស្សស្រាវជ្រាវបាន ហើយយើងក៏មាន Tablet សម្រាប់ឱ្យសិស្សប្រើប្រាស់បានទៀតផង។ លើសពីនេះទៅទៀតយើងក៏បានរៀបចំឱ្យមានក្លិបសិក្សារបស់សិស្ស និងនិស្សិត ដែលចូលរៀននៅក្នុងសាលារៀនជំនាន់ថ្មី ដែលក្រោយពីគាត់រៀនចប់ម៉ោងរៀនរបស់គាត់ គាត់នឹងអាចចូលទៅក្នុងក្លិបសិក្សាបាន។ កន្លងមកក្លិបសិក្សានេះត្រូវបានគេបង្កើតឡើងមានដូចជា ក្លិបឌីហ្សាញ កាត់តរូបភាព កាត់តវីដេអូ ក្លិបអ្នកនិពន្ធ ក្លិបគណិតវិទ្យា ក្លិបគីមីវិទ្យា និងមានក្លិបខ្លះឈានទៅដល់ការបង្កើតរូប៉ូត (Robot) ថែមទៀតផង។ ក្រៅពីនេះសាលារៀនជំនាន់ថ្មីក៏បានរៀបចំឱ្យមានការប្រឹក្សាអាជីព ដើម្បីតម្រង់ទិសរបស់សិស្សចាប់ពីក្មេងរហូតដល់ចូលឧត្តមសិក្សាផងដែរ។(lareine.com.kh, ១៩ មេសា ២០១៩)

នាយករងសាលាវិទ្យាល័យព្រះស៊ីសុវត្ថិសាលារៀនជំនាន់ថ្មី លោក សម្ប កំសាន្ត បានលើកឡើងថា សាលានេះមានគោលការណ៍គ្រឹះធំៗចំនួន៥ដើម្បីរក្សាឱ្យបានគុណភាពអប់រំខ្ពស់។

**គោលការណ៍ ទី១** សាលាមានឯករាជភាពលើកម្មវិធីសិក្សារបស់ខ្លួន។ មានន័យថា សាលារៀនជំនាន់ថ្មី មានសិទ្ធរៀបចំវិធីសាស្ត្របង្រៀនដោយខ្លួនឯង ឱ្យស្រពតាមទីផ្សារការងារក្នុងសតវត្សរ៍ទី២១។

**គោលការណ៍ទី២** គ្រូត្រូវមានស្តង់ដាបង្រៀនខ្ពស់៖ មានន័យថា គ្រូមិនបង្រៀនគួរក្រៅម៉ោង មិនលក់ក្រដាសសិក្សា គោរពម៉ោងពេលបង្រៀន គ្រូជាអ្នកផ្ទេរចំណេះដឹង និងយកចិត្តទុកដាក់លើសិស្សគ្រប់កាលៈទេសៈទាំងសិស្សពូកែ និងរៀនខ្សោយ។

**គោលការណ៍ទី៣** ការរៀបចំគណនីយភាពតឹងរ៉ឹង៖ មានន័យថា រាល់ប្រាក់ចំណូលឬចំណាយត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ រួមទាំងការផ្តល់ផលប្រយោជន៍ និងធនធានផ្សេងៗច្បាស់លាស់។

**គោលការណ៍ទី៤** សាលាមានការទទួលស្គាល់ជាផ្លូវច្បាប់នូវគ្រប់ការងារ៖ ដូចជាការស្រាវជ្រាវផ្សេងៗនៅក្នុងសាលា។ ត្រង់ចំណុចនេះ សាលាទទួលស្គាល់ស្នាដៃផ្សេងៗរបស់គ្រូដូចជា បច្ចេកទេសបង្រៀនសិស្សឱ្យឆាប់ចេះ ស្នាដៃនិពន្ធផ្សេងៗ ជួយជម្រុញបន្ថែមឱ្យគ្រូក្លាយជាអ្នកស្រាវជ្រាវជានិច្ច និងជាអ្នកផ្ទេរចំណេះដឹងដ៏មានប្រសិទ្ធភាព។

**គោលការណ៍ទី៥** ការបែងចែកធនធាន៖ មានន័យថា បែងចែកទៅតាមទំហំការងាររបស់គ្រូ បើគ្រូនោះធ្វើការងារច្រើន មានសក្តានុពលជាងគេ និងពូកែជាងគេ នោះគាត់ក៏ទទួលបានប្រាក់ឧបត្ថម្ភច្រើនលើសគេដែរ។ (thmeythmey, 29, Apr 2018)

ការសិក្សាលើប្រធានបទ ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីនេះ អ្នកស្រាវជ្រាវសិក្សាតែលើលទ្ធផលសិក្សារបស់សិស្សានុសិស្ស និងកត្តាដែលជះឥទ្ធិពលលើលទ្ធផលសិក្សានេះដែលរួមមានការគ្រប់គ្រងនិងដឹកនាំ ការបង្រៀន និងរៀន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតែប៉ុណ្ណោះ។

## ២.៤ គោលបំណងនៃការបង្កើតសាលាជំនាន់ថ្មី

គោលបំណងរបស់សាលារៀនជំនាន់ថ្មី គឺការបង្កើតសាលារដ្ឋដែលរក្សាបានស្តង់ដារនៃការអប់រំបានខ្ពង់ខ្ពស់បំផុតតាមរយៈការវិនិយោគថវិកាច្រើន និងផ្តោតទៅលើការពង្រឹងតម្លាភាព និងទទួលខុសត្រូវដោយការផ្លាស់ប្តូរវិធីគ្រប់គ្រងសាលា។

សាលារៀនជំនាន់ថ្មីព្យាយាមដោះស្រាយបញ្ហាជាច្រើនដូចជាការលុបបំបាត់ការអនុវត្តបង្ខំសិស្សរៀនគួរ ទិញនំ ឬចំណីក្នុងសាលា ដណ្តើមថ្នាក់គ្នាបង្រៀន មានការរើសអើងសិស្សចំពោះសិស្សរៀនគួរ និងមិនរៀនគួរ។ ហេតុនេះហើយបានជាគ្រូបង្រៀនត្រូវបានជ្រើសរើសយ៉ាងល្អិតល្អន់ និងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជាការផ្តល់អាហារូបករណ៍ដើម្បីពង្រឹងគុណធម៌ក្នុងការបង្រៀន និងសុចរិតភាព។ គេបានសង្កេតឃើញថា នៅក្នុងបរិយាកាសថ្មីនេះគ្រូបង្រៀនលែងមានការប្រកួតប្រជែងជាមួយគ្នាដើម្បីទាក់ទាញអតិថិជនដែលជាសិស្សនោះទេ ហើយវាធ្វើឲ្យការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការបង្រៀននិងរៀនប្រព្រឹត្តទៅដោយរលូន។ ដូចគ្នាដែរអ្វីដែលនាំឲ្យមានការចាប់អារម្មណ៍ខ្ពស់នោះ គឺកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មី បានយកចិត្តទុកដាក់ខ្ពស់លើការលុបបំបាត់ការរៀនក្រៅម៉ោង ឬហៅថារៀនគួរ និងការលក់ឯកសារផ្សេងៗដែលនាំឲ្យសិស្សចំណាយក្រៅផ្លូវការលើការសិក្សារបស់ពួកគេ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថាមូលហេតុនៃការបង្កើតសាលាជំនាន់ថ្មីនេះគឺឆ្លើយតបទៅនឹងនិន្នាការសំខាន់ចំនួន៣គឺ

**និន្នាការទី១** ប្រទេសកម្ពុជាជាប្រទេសដែលកើតចេញពីប្រទេសដែលមានប្រាក់ចំណូលទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយគោលដៅនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល គឺចង់ឱ្យប្រទេសកម្ពុជាឈានទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ2030 និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ2050។

**និន្នាការទី២** គឺប្រជាជនកម្ពុជាជាង50% គឺជាប្រជាជនដែលមានអាយុក្រោម 30 ឆ្នាំ ហេតុនេះ យុវជនត្រូវការជំនាញត្រូវការចំណេះដឹងដើម្បីក្លាយខ្លួនទៅជាពលករមួយ

ដែលមានគុណភាពអាចចូលរួមនៅក្នុងការអភិវឌ្ឍសង្គមបាន។

**និន្នាការទី៣** គឺបច្ចេកវិទ្យាបច្ចុប្បន្ននេះកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយយើងក៏កំពុងស្ថិតក្នុងបដិវត្តន៍ឧស្សាហកម្មទី4 (Industry revolution 4.0) ដែលទាមទារឱ្យប្រព័ន្ធអប់រំត្រូវតែដើរឱ្យទាន់សភាពការណ៍ និងមានប្រព័ន្ធអប់រំវៃឆ្លាតទៀតផង។ ហេតុនេះការបង្កើតសាលារៀនជំនាន់ថ្មីនេះជាដំណោះស្រាយយ៉ាងសំខាន់ដើម្បីឱ្យកម្ពុជាសម្រេចបាននូវគោលដៅសំខាន់ៗ និងស្របទៅតាមបរិបទសង្គមដែលកំពុងត្រូវការការអប់រំបែបទំនើប។ (lareine.com , April 19, 2019)

បន្ថែមពីនេះទៀត អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា លោក ឌី ខាំបូលី បានលើកឡើងថា សាលារៀនជំនាន់ថ្មីគឺជាកម្មវិធីសិក្សាថ្មីមួយដែលក្រសួងអប់រំបានដាក់ឲ្យអនុវត្តន៍ក្នុងដំណាក់កាលសាកល្បងនៅឆ្នាំ២០១៥។ ការអនុវត្តន៍នេះ គឺធ្វើទាំងថ្នាក់បឋម និងថ្នាក់មធ្យមសិក្សាផងដែរក្នុងបំណងធ្វើឲ្យការអប់រំនៅកម្ពុជាកាន់តែល្អប្រសើរ ដូចទៅនឹងប្រទេសមួយចំនួននៅក្នុងតំបន់ និងលើពិភពលោក។

លោកក៏បានអះអាងបន្ថែមទៀតថាកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មី ត្រូវបានយកចិត្តទុកដាក់ខ្ពស់លើការបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាទៅក្នុងការអប់រំទាំងអ្នករៀន និងអ្នកបង្រៀន ព្រមទាំងបំពាក់ឧបករណ៍សិក្សាសម្បូរបែបផងដែរ។ ជាពិសេសម៉ោងសិក្សាមានច្រើនជាងកម្មវិធីសិក្សាចាស់។(ព័ត៌មាន Fresh News នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៨)

## ២.៥ បេសកកម្មរបស់សាលារៀនជំនាន់ថ្មី

សាលារៀនជំនាន់ថ្មីមានបេសកកម្មកែលម្អបរិស្ថាន ពង្រឹងគុណភាពអប់រំ អនុវត្តន៍ឱ្យបានពេញលេញក្រមសីលធម៌វិជ្ជាជីវៈ រិះរកគំនិតផ្តួចផ្តើមថ្មីៗដើម្បីកែលម្អគុណភាពសេ-វាអប់រំ កៀរគរការចូលរួមគាំទ្រហិរញ្ញវត្ថុគ្រប់មជ្ឈដ្ឋាន និងដៃគូអភិវឌ្ឍ បង្កើនការស្រាវជ្រាវនិងអភិវឌ្ឍគ្រប់កម្មវិធីសិក្សា ជាមជ្ឈមណ្ឌលនៃការអភិបាលកិច្ចល្អលើសេវារដ្ឋបាលសាលារៀន និងជាមជ្ឈមណ្ឌលប្រឹក្សាអាជីពសម្រាប់តម្រង់ទិសវិជ្ជាជីវៈដល់សិស្សនៅពេលអនាគត។ (សៀវភៅគោលនយោបាយស្តីពីសាលាជំនាន់ថ្មី)

## ២.៦ ចក្ខុវិស័យសាលារៀនជំនាន់ថ្មី

សាលាជំនាន់ថ្មីនឹងនាំមកនូវគ្រប់ខណ្ឌរដ្ឋបាលថ្មីដែលអាចធានាលក្ខខណ្ឌចាំ-បាច់ជាសារវន្ត និងមានប្រសិទ្ធភាពក្នុងការធ្វើវិនិយោគប្រព័ន្ធអប់រំដោយជោគជ័យ។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះស៊ីសុវត្ថិ មាន ចក្ខុវិស័យ "ប្រែក្លាយសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ ជាវិទ្យាល័យមានឧត្តមភាពឈានមុខគេ របស់កម្ពុជាលើការបង្រៀន និងរៀន(ទាំងឥរិយាបថ ចំណេះដឹង និងជំនាញ) ការស្រាវជ្រាវនៅមធ្យមសិក្សា និងការផ្តល់សេវាសហគមន៍"។

ប្រែក្លាយសាលាបឋមសិក្សាអនុវត្ត និងវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ជាសាលារៀនជំនាន់ថ្មីឈានមុខគេក្នុងការផ្តល់សេវាអប់រំនិងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពធានាឱ្យសិស្សសម្រេចបាននូវសក្តានុពលអតិបរមា ឆ្លើយតបនឹងបរិបទថ្មីនៃសតវត្សទី២១។

## ២.៧ គោលដៅសាលារៀនជំនាន់ថ្មី

- បង្កើតសាលារៀនសាធារណៈស្វយ័តគ្រប់គ្រងដោយតឹងរឹងក្នុងការបំពេញភារកិច្ច និងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់។
- បង្កើតក្រុមប្រឹក្សាភិបាលដែលនឹងធ្វើឱ្យសាលាទទួលខុសត្រូវសម្រាប់ការបំពេញភារកិច្ច។
- បង្កើតប្រព័ន្ធទទួលស្គាល់ដែលនឹងសម្របសម្រួលដល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលដោយប្រកាន់ភ្ជាប់ទៅនឹងគោលការណ៍ស្នូលរបស់សាលារៀនជំនាន់ថ្មី។
- ផ្តល់សេរីភាពស្ថាប័នថ្មី (ឧ. ស្វ័យភាពប្រតិបត្តិការ)ដើម្បីធ្វើឱ្យមានការច្នៃប្រឌិតក្នុងវិធីរៀបចំបង្កើត និងផ្តល់សេវាអប់រំ។
- ធ្វើឱ្យប្រព័ន្ធអប់រំមានប្រសិទ្ធភាព និងសមធម៌សង្គមក្នុងដំណើរការបង្រៀននិងរៀនដោយមានប្រព័ន្ធបែងចែកធនធានឱ្យសមស្របសំដៅលើកម្ពស់សេវាអប់រំ។

- កែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗដែលរួមបញ្ចូលការជ្រើសរើសគ្រូដោយការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ច ការបំប៉នសមត្ថភាពគ្រូបង្រៀនបន្ថែមលើផ្នែកបច្ចេកវិទ្យាអប់រំ វិធីសាស្ត្រ STEM និងការសិក្សាឱ្យស្គាល់បញ្ហានិងការរកដំណោះស្រាយព្រមទាំងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន(ឧ. អាហារូបករណ៍គ្រូដើម្បីបន្តការសិក្សាពេលអនាគត)។
- ពង្រីកសេវាអប់រំសម្រាប់យុវជនកម្ពុជាដែលនឹងរួមបញ្ចូលទាំងសេវាប្រឹក្សាអាជីពសកម្មភាពសិក្សាប្លែកៗតាមរយៈ ការងារគម្រោង ក្លិបអ្នកសិក្សាតាមមុខវិជ្ជា ការសិក្សាតាមឧបករណ៍ចល័ត និងកម្មវិធីសិក្សាបំណិនជីវិត។

## ២.៨ យុទ្ធសាស្ត្រ

១. ជ្រើសរើសសាលាយ៉ាងម៉ត់ចត់: ជ្រើសរើសសាលារៀនដែលមានសក្តានុពលពេលលេញ

២. ភាពជាដៃគូ: កសាងភាពជាដៃគូជិតស្និទ្ធជាមួយតួអង្គមិនមែនរដ្ឋ និងវិស័យឯកជន

៣. ប្រាក់លើកទឹកចិត្តគ្រូ:

៤. ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការផ្ទេរប្រឌិតថ្មី

៥. ការប្រើប្រាស់បច្ចេកវិទ្យា

៦. ការពង្រឹងសិទ្ធិអំណាចយុវជន: អនុវត្តតួនាទីដ៏សំខាន់លើការគ្រប់គ្រងសម្ភារៈ និងសេវាថ្មីៗ

៧. ការបង្កើនម៉ោងបង្រៀន និងរៀន: ពី៣៥ម៉ ទៅ៤០ម៉ក្នុង១សប្តាហ៍ (មធ្យមសិក្សា)

៨. ការដាក់ឱ្យអនុវត្តប្រភេទមុខវិជ្ជា: STEM និងភាសាបរទេស

៩.មូលនិធិសមធម៌សង្គមដើម្បីទទួលបានមូលនិធិបន្ថែមសម្រាប់ជួយសិស្សក្រីក្រ

១០. គំរូសាលាក្នុងសាលា: សម្រាប់ដោះស្រាយបញ្ហាប្រឈម

១១. ការកាត់បន្ថយផលធៀបគ្រូ សិស្ស: ដើម្បីបង្កើនគុណភាពសិក្សាជាបុគ្គល

១២. ការផ្លាស់ប្តូរផ្នត់គំនិតបុគ្គលៈ ប្តូរឥរិយាបទគ្រប់អ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងការសិក្សាក្នុងសតវត្សរ៍ទី២១។

១៣. ការធ្វើទំនើបកម្មបរិស្ថានសិក្សាៈ កែប្រែបន្ទប់រៀន និងបន្ទប់ផ្សេងៗទៀតនៅក្នុងសាលារៀនឱ្យសមស្របទៅនឹងស្តង់ដាសាលារៀនាសតវត្សរ៍ទី២១

## ២.៩ លក្ខណៈវិនិច្ឆ័យស្នើសុំដើម្បីទទួលបានមូលនិធិសមធម៌សង្គម

សាលារៀនដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម និងមានសិទ្ធទទួលបានមូលនិធិសមធម៌សង្គមដើម្បីលើកកម្ពស់ជនក្រីក្រឱ្យទទួលបានការអប់រំមានស្តង់ដាអន្តរជាតិ។ សាលារៀនត្រូវមានលក្ខណៈវិនិច្ឆ័យចាំបាច់១០០%នៃលក្ខណៈវិនិច្ឆ័យជម្រើស៥០%។ ការបំពេញតាមលក្ខណៈវិនិច្ឆ័យដូចបានបញ្ជាក់នឹងត្រូវបញ្ជាក់ដោយគណៈកម្មការត្រួតពិនិត្យការគ្រប់គ្រងសាលារៀនរបស់ក្រសួងអប់រំយុវជន និងកីឡាដែលបានបង្កើតឡើងនាពេលថ្មីនេះដឹកនាំដោយឯឧត្តម ណាត ប៊ុនរឿន។

| លក្ខណវិនិច្ឆ័យសេវាអប់រំ | | ស្ថានភាពលក្ខណៈវិនិច្ឆ័យ | | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ចាំបាច់ | ជម្រើស | |
| ១ | លុបបំបាត់ការរៀនគួរ | ✓ | | |
| ២ | លុបបំបាត់ការអនុវត្តទិញទំនិញរបស់គ្រូនៅក្នុងថ្នាក់ (ឧ.នំក្រដាស) | ✓ | | |
| ៣ | ម៉ោងសិក្សា៦ម៉ោង/ថ្ងៃតាមស្តង់ដាអន្តរជាតិ | ✓ | | សម្រាប់បឋមសិក្សា |
| ៤ | ភស្តុតាងបង្ហាញថាក្រុមប្រឹក្សាកុមារ និងចូលរួមក្នុងការគ្រប់គ្រងសាលា | ✓ | | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ៥ | ភស្តុតាងបង្ហាញថាគណៈកម្មការទ្រទ្រង់សាលាសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលា | ✓ | | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ៦ | ភស្តុតាងបង្ហាញថាមានការប្រជុំជាទៀងទាត់ជាមួយមាតាបិតាសិស្ស(តិចបំផុត២ដងក្នុងមួយឆ្នាំ) | ✓ | | |
| ៧ | ភស្តុតាងបង្ហាញថាគ្រូប្រើវិធីសាស្រ្តសិស្សមជ្ឈមណ្ឌលយ៉ាងហោចណាស់ឱ្យបាន៥០%នៃថ្នាក់ | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ៨ | សម្ភារៈឧបទេសមានគ្រប់គ្រាន់និងមានភស្តុតាងបង្ហាញថាមានការប្រើប្រាស់កម្រិតខ្ពស់ | ✓ | | |

| | | | | |
|---|---|---|---|---|
| ៩ | មានសៀវភៅពុម្ពគ្រប់គ្រាន់(មួយច្បាប់សម្រាប់សិស្សម្នាក់គ្រប់មុខវិជ្ជាសំខាន់ៗទាំងអស់) | | ✓ | |
| ១០ | ផលធៀបរវាងសិស្ស និងគ្រូត្រឹម ឬតិចជាង ៥០ៈ១ | | ✓ | |
| ១១ | ភស្តុតាងបង្ហាញថាមានការបង្រៀនបច្ចេកវិជ្ជាព័ត៌មាន (ឧ. អក្ខរកម្មឬ ការរៀនដោយប្រើ ។ល។ | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ១២ | ភស្តុតាងបង្ហាញពីកម្មវិធីបំនិនជីវិតដោយប្រើប្រាស់កម្មវិធីសិក្សាថ្មីដែលក្រសួងបានអុម័ត | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ១៣ | ភស្តុតាងបង្ហាញពីការផ្តល់សេវាប្រឹក្សាអាជីព | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ១៤ | ភស្តុតាងបង្ហាញការផ្តល់សេវាប្រឹក្សាកុមារី | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ១៥ | ភស្តុតាងបង្ហាញថាមានឧបករណ៍វាស់អំណានដែលបានអនុម័តឱ្យប្រើប្រាស់នាពេលថ្មីៗនេះសម្រាប់ថ្នាក់ទី១ និង២ | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ១៦ | សកម្មភាពបន្ថែមលើកម្មវិធីសិក្សា (ឧ.ក្លិបមុខវិជ្ជា កីឡា សិល្បៈ។ល។ | | ✓ | |
| ១៧ | មានស្តង់ដាខ្ពស់ក្នុងការថែរក្សានិងអនាម័យអគារ | ✓ | | |
| ១៨ | ស្តង់ដាខ្ពស់ចំពោះអនាម័យបង្គន់ | ✓ | | |
| ១៩ | ភស្តុតាងបង្ហាញថាមានការគាំទ្រសិស្សក្រីក្រ (ឧ.គូរផែនទីសិក្សាផ្តល់អាហារូបករណ៍។ល។) | | ✓ | |
| ២០ | បន្ទប់ពិសោធន៍វិទ្យាសាស្ត្រដែលមានអត្រាប្រើប្រាស់ខ្ពស់ (សម្រាប់សិស្សមធ្យមសិក្សាតែប៉ុណ្ណោះ) | | ✓ | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ២១ | បណ្ណាល័យដែលមានអាត្រាប្រើប្រាស់ខ្ពស់ | ✓ | | លក្ខណៈវិនិច្ឆ័យតម្រូវតាមស្តង់ដា |
| ២២ | មានសួនកុមារនិងទីធ្លាលេងកីឡា | | ✓ | |
| ២៣ | មានថ្នាក់បំប៉នសិស្សរៀនយឺតដែលមានតម្រូវការជំនួយពិសេស | | ✓ | |
| ២៤ | មានអាហារដ្ឋានសម្រាប់សិស្សដែលផ្តល់ជីជាតិមានស្តង់ដាខ្ពស់និងតម្លៃសមរម្យ | | ✓ | |
| | សរុប | ១០ | ១៤ | |

(ការបង្កើតសាលារៀនជំនាន់ថ្មីនៅក្នុងប្រទេសកម្ពុជា, សេចក្តីព្រាងចុងក្រោ ខែតុលា ឆ្នាំ ២០១៤)

## ២.១០ ចំណុចខ្លាំង និងចំណុចខ្សោយនៃសាលារៀនជំនាន់ថ្មី

### ចំណុចខ្លាំង

មានសេវាកម្មជួយសិស្សដូចជា

- បណ្ណាល័យអេឡិចត្រូនិកសតវត្សរ៍ទី២១ (បំពាក់ដោយឧបករណ៍អេឡិចត្រូនិក ដូចជា Tablets, Smart TVs, Internet រួមជាមួយសៀវភៅសិក្សាគ្រប់មុខវិជ្ជា និង សៀវភៅចំណេះដឹងទូទៅជាច្រើនទុកសម្រាប់សិស្សានុសិស្សស្រាវជ្រាវ និង ស្វែងរកព័ត៌មានផ្សេងៗ)
- សេវាប្រឹក្សា
- ក្លឹបមុខវិជ្ជា
- ការអប់រំបំណិនជីវិត
- ការវាយតម្លៃ
- រៀនតាមកម្មវិធីកុំព្យូទ័រ
- និងរៀនតាមឧបករណ៍អេឡិចត្រូនិក

### ចំណុចខ្សោយ

- សាលារៀនជំនាន់ថ្មីត្រូវបានបង្កើតឡើងក្នុងគោលដៅជួយសិស្សដែលមាន ជីវភាពក្រីក្រ និងមធ្យម តែតម្រូវឱ្យសិស្សមានបដិភាគ៣០០ដុល្លាក្នុងមួយឆ្នាំ ចំពោះអ្នកមានលទ្ធភាព។
- សិស្សមានជីវភាពក្រីក្រភាគច្រើនមិនសូវបានរៀនសូត្រពេញលេញទេ ហេតុនេះ ការប្រឡងចូលមុនចូលរៀននៅសាលានេះពិតជាលំបាកសម្រាប់ពួកគេ។
- ចំពោះសិស្សដែលរៀនធ្លាក់មធ្យមភាគប្រចាំឆ្នាំតម្រូវឱ្យទៅរៀននៅសាលាផ្សេង វិញ
- មានការកំណត់ចំនួនសិស្សដាក់ពាក្យចូលរៀន
- ឱ្យគ្រួសារសិស្សធ្វើការចាប់ឆ្នោតដើម្បីបានចូលរៀនពីព្រោះចំនួនសិស្សមាន កំណត់

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និង គុណវិស័យដែលបានយកមកវិភាគ ដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីដែលជាគោលដៅនៃការស្រាវជ្រាវ លើប្រធានបទនេះ។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

ជាទូទៅនៅគ្រប់គ្រឹះស្ថានសិក្សារដ្ឋទាំងអស់ សុទ្ធតែចង់ឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តនៅតាមគ្រឹះស្ថាននោះជាពិសេសគឺផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ប៉ុន្តែកន្លងមកមិនទាន់មានសាលាណាមួយ ដែលទទួលបានរបាយការណ៍មកមួយបង្ហាញពីការគ្រប់គ្រងបានល្អឥតខ្ចោះ និងមានប្រសិទ្ធភាពនេះឡើយ។ ភាគច្រើនមានតែលទ្ធផលនៃការគ្រប់គ្រងថាបានល្អ តាមរយៈការបូក សរុបសន្និបាតប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសយកទីតាំងនៅខេត្តកំពង់ចាម ហើយក្នុងនោះរួមមានសាលាជំនាន់ថ្មីចំនួន៤ដែលមានបឋមសិក្សាចំនួន២ និងវិទ្យាល័យចំនួន២។ ការសិក្សាស្រាវជ្រាវដែលយកតែវិទ្យាល័យចំនួន២នៅក្នុងខេត្តកំពង់ចាម មកសិក្សានេះ ត្រូវបានជ្រើសរើសដោយការកំណត់របស់អ្នកសិក្សាស្រាវជ្រាវចេញពីក្នុងចំណោមសាលាជំនាន់ថ្មីទាំង៤ ដោយផ្អែកលើកត្តាពេលវេលា និងធនធានមានកំណត់។

## ៣.៣ ក្រុមគោលដៅ

ការសិក្សានេះផ្តោតទៅលើលទ្ធផលសិក្សារបស់សិស្សនៅក្នុងសាលាវិទ្យាល័យជំនាន់ថ្មីទាំងពីរ(ចាប់ពីថ្នាក់ទី ៧ ដល់ ថ្នាក់ទី ១១ )។ ចំពោះក្រុមគោលដៅគឺ សិស្ស (ចាប់ពីថ្នាក់ទី៧ដល់ទី១១)ចំនួន៧០នាក់ លោកគ្រូអ្នកគ្រូ បង្រៀនចាប់ពីថ្នាក់ទី(៧ ដល់ ថ្នាក់ទី ១១)មានចំនួន (២០នាក់) និងគណៈគ្រងសាលាចំនួន (២នាក់ ) ។

តារាង ៣.៣.១ ៖ ក្រុមគោលដៅ និងអ្នកចូលរួម

| ល-រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ០១ | គណៈគ្រប់គ្រងសាលារៀន | ២នាក់ |
| ០២ | គ្រូបង្រៀន | ២០នាក់ |

| | | |
|---|---|---|
| ០៣ | សិស្សានុសិស្ស | ៧០នាក់ |
| សរុបរួម | | ៩២នាក់ |

## ៣.៤ ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន សិស្សានុសិស្សដែលកំពុងសិក្សានៅសាលាជំនាន់ថ្មីទាំងពីរ មានចំនួន ៧០ នាក់ គ្រូបង្រៀនដែលកំពុងបង្រៀននៅកម្រិតវិទ្យាល័យ (ចាប់ពីថ្នាក់ទី៧ ដល់ ថ្នាក់ទី១១) ចំនួន ២០ នាក់ នាយក/នាយិកាចំនួន ២នាក់ ដែលមានទីតាំងស្ថិតក្នុងខេត្តកំពង់ចាមនៅសាលាជំនាន់ថ្មីដែលបានជ្រើសរើសចំណោមសាលាជំនាន់ថ្មីទាំង៩តែប៉ុណ្ណោះ។

ការស្រាវជ្រាវនេះត្រូវបានចែកជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទីមួយគឺជាការពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធ និងមានស្រាប់។ នៅជំណាក់កាលទីមួយនេះដែរ អ្នកស្រាវជ្រាវព្យាយាមសិក្សាស្វែងរកឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទហើយយកវាមកសិក្សាបន្ថែម និងយកវាជាឯកសារយោងផងដែរ។ ដំណាក់កាលទីពីរគឺជាការចុះប្រមូលព័ត៌មាន ពីអ្នកពាក់ព័ន្ធ ដោយផ្ទាល់។ នៅក្នុងដំណាក់កាលនេះ កម្រងសំណួរត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋានក្នុងការប្រមូលព័ត៌មាន។ ការយកកម្រងសំណួរទៅប្រមូលព័ត៌មាន មានគោលបំណងស្វែងរកព័ត៌មានផ្សេងៗពីភាគីដែលពាក់ព័ន្ធគឺចង់បានព័ត៌មានពីពួកគាត់ទាំងអស់គ្នាដើម្បីយកមកសិក្សា។

## ៣.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវមានពីរបែបគឺការស្រាវជ្រាវតាមបែបបរិមាណវិស័យ និងការស្រាវជ្រាវតាមបែបគុណវិស័យ។ ចំពោះប្រធានបទ "ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី" ករណីសិក្សាក្នុងខេត្តកំពង់ចាមគឺ អ្នកស្រាវជ្រាវសម្រេចជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យមកធ្វើជាវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើសំណួរស្រាវជ្រាវនៃប្រធានបទនេះ ។

## ៣.៦ ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះបានកំណត់ជ្រើសរើសយកសាលាជំនាន់ថ្មីចំនួនពីរដែលរួមមាន ទី១-សាលាវិទ្យាល័យ ហ៊ុន សែន ពាមជីកង និងទី២-សាលាវិទ្យាល័យ ហ៊ុន សែន អនុវត្ត ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយកធាតុសំណាកទៅលើសិស្សចំនួន

៧០នាក់ លោកគ្រូ អ្នកគ្រូចំនួន២០នាក់ក្នុងវិទ្យាល័យទាំងពីរ។ ការសិក្សាស្រាវជ្រាវនេះជ្រើសរើសតែវិទ្យាល័យចំនួនពីរទេ ពីព្រោះមានភាពងាយស្រួលក្នុងការប្រមូលទិន្នន័យហើយ និងវិភាគស្វែងរកពីកម្រិតប្រសិទ្ធភាពនៃការអនុវត្តនៅក្នុងសាលារៀនជំនាន់ថ្មីផង ហេតុនេះបានជាអ្នកស្រាវជ្រាវជ្រើសរើសយកប្រធានបទ "ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី" នៅក្នុងខេត្តកំពង់ចាម។

## ***៣.៧ ឧបករណ៍សម្រាប់ស្រាវជ្រាវ***

ការស្រាវជ្រាវមានឧបករណ៍ច្រើនយ៉ាងសម្រាប់យកទៅប្រមូលព័ត៌មាន។ ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវសម្រេចចិត្តប្រើប្រាស់ កម្រងសំណួរសម្រាប់ប្រមូលទិន្នន័យបែបចំរុះ។ អ្នកសិក្សាស្រាវជ្រាវបានបង្កើតកម្រងសំណួរស្រាវជ្រាវចំនួន៣ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណង និងសំណួរស្រាវជ្រាវដែលរួមមាន៖ កម្រងសំណួរសម្រាប់នាយក និងនាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសសិស្ស។

កម្រងសំណួរដែលបានរៀបចំឡើងនេះទទួលបានការណែនាំ ពិភាក្សា និងផ្តល់យោបល់ជាប្រចាំពីសាស្ត្រាចារ្យណែនាំទាំងពីរ។ ក្រោយពីមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ទទួលការណែនាំ និងកែតម្រូវរបស់សាស្ត្រាចារ្យណែនាំរួចមក កម្រងសំណួរនេះត្រូវបានពិនិត្យ និងកែលម្អជាចុងក្រោយ។ ខ្លឹមសារនៃឧបករណ៍នេះរៀបចំឡើងយោងទៅលើឯកសារនានាដែលធ្លាប់ត្រូវបានសិក្សាស្រាវជ្រាវកន្លងមកដែលពាក់ព័ន្ធនិងប្រសិទ្ធភាពនៃការអនុវត្តសាលារៀន ហើយក៏ផ្អែកទៅលើសូចនាករវាយតម្លៃនាយកសាលាល្អ និងគ្រូល្អផងដែរ។

**កម្រងសំណួរទី១ សម្រាប់នាយកសាលារួមមាន៧ចំណុច**

ចំណុចទី១៖ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ

ចំណុចទី២៖ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិត

ចំណុចទី៣៖ ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន

ចំណុចទី៤៖ ការដឹកនាំការរៀន និងបង្រៀន

ចំណុចទី៥៖ បំណិនប្រាស្រ័យទាក់ទង

ចំណុចទី៦៖ ក្រមសីលធម៌វិជ្ជាជីវៈនាយក

ចំណុចទី៧៖ កត្តាប៉ះពាល់ក្នុងការកំណត់ប្រសិទ្ធភាពរបស់នាយក

**កម្រងសំណួរទី២ សម្រាប់លោកគ្រូ អ្នកគ្រូ រួមមាន៧ចំណុច**

ចំណុចទី១៖ កម្រិតវប្បធម៌និងបទពិសោធន៍ការងារ

ចំណុចទី២៖ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិត

ចំណុចទី៣៖ ភាពដឹកនាំ និងគ្រប់គ្រង

ចំណុចទី៤៖ បំណិនប្រាស្រ័យទាក់ទង

ចំណុចទី៥៖ លទ្ធផលសិក្សារបស់សិស្ស

ចំណុចទី៦៖ សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង

ចំណុចទី៧៖ ក្រមសីលធម៌វិជ្ជាជីវៈ

**កម្រងសំណួរទី៣ សម្រាប់សិស្សានុសិស្ស**

ចំណុចទី១៖ ព័ត៌មានទូទៅ

ចំណុចទី២៖ ការអនុវត្តរបស់សិស្ស

តារាងចំណាត់ថ្នាក់ប្រចាំខែ និងប្រចាំឆមាសទី១របស់សិស្ស

## ៣.៨ ដំណើរការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការណែនាំ និងឯកភាពពីគ្រូដឹកនាំ ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពី វិទ្យាស្ថានជាតិអប់រំ លេខ : ១១៩ វជអផក. ចុះថ្ងៃ សុក្រ ១៤ កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦នៃវិទ្យាស្ថានជាតិអប់រំឲ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅតាមរាជធានី ខេត្តនានា និងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ : ១៨៨៥ អយក.វជអ ចុះថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី. ១៨ ខែ មេសា ឆ្នាំ២០១៩ ស្តីពីការស្នើទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តនានា សុំជួយសម្រួលដល់ការចុះប្រមូលទិន្នន័យដែលទាក់ទងនឹងប្រធានបទស្រាវជ្រាវសម្រាប់និស្សិត នៅតាមរាជធានីខេត្តនានា។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាមនេះដោយសារតែសាលាគោលដៅដែលត្រូវយកមកធ្វើការស្រាវជ្រាវទាំងនេះ ស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម តាមរយៈលិខិត

ឧទ្ទេសនាមលេខ : ៨៧៥.១៩ ឧទន/រប ចុះថ្ងៃ អង្គារ ១០ រោច ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី. ២៨ ខែ ឧសភា ឆ្នាំ២០១៩ ស្ដីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុកគោលដៅនានាក្នុងខេត្តកំពង់ចាមមក អ្នកស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទាក់ទងទៅសាលាគោលដៅទាំងពីរដោយផ្ទាល់ ដើម្បីជួបពិភាក្សាជាមួយនាយកសាលាក្នុងគោលបំណងកំណត់កាលបរិច្ឆេទជួបសិស្ស និងលោកគ្រូអ្នកគ្រូដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុនរួចស្រេច ធ្វើយ៉ាងណាមិនឱ្យប៉ះពាក់ដល់ការបង្រៀន និងការរៀនរបស់សិស្ស។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលា អំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សាស្រាវជ្រាវ។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតឧទេសនាមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយ គាត់ក៏បានអនុញ្ញាតឲ្យរៀបចំការប្រមូលទិន្នន័យទៅតាមផែនការដែលបានឯកភាពគ្នា។

បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំដើម្បីទទួលបានយោបល់ត្រឡប់ក្នុងការកែលម្អកម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្ដើមចុះប្រមូលទិន្នន័យតែម្ដង។

## ៣.៩ ការវិភាគទិន្នន័យ

ចំពោះកិច្ចការស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្ន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានវិភាគដាច់ដោយឡែកពីគ្នាទៅតាមប្រភេទនៃសំណាកនីមួយៗ (នាយកសាលា គ្រូបង្រៀន និងសិស្ស)។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ បានសំយោគបញ្ចូលគ្នាដោយផ្ដោតលើចំណុចសំខាន់ៗដូចជា ការគ្រប់គ្រងនិងដឹកនាំ ការរៀននិងបង្រៀន គ្រូបង្រៀន និងសិស្សានុសិស្ស និងតម្រូវការដែលបម្រើឱ្យការសិក្សាទទួលបានលទ្ធផលល្អ។ ដើម្បីឆ្លើយតបទៅនឹងចំណុចទាំងនេះ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធី SPSS សម្រាប់ស្វែងរកតម្លៃមធ្យម ភាគរយ ប្រេកង់ និងកម្មវិធី Ms. Excel សម្រាប់សង់ក្រាប ធ្វើតារាង និងបកស្រាយព័ត៌មានរបស់ធាតុសំណាកនីមួយៗ។ ចំណែកកម្រងសំណួរបំពេញ គឺអ្នកសិក្សាស្រាវជ្រាវបានប្រមូល

ផ្ដុំចម្លើយរបស់ភាគីពាក់ព័ន្ធដែលទទួលបានតាមរយៈការបំពេញ និងសង្កេតក្នុងគោលបំណងស្វែងរកចំពោះនាយកសាលាឱ្យឃើញពីចំណុចខ្លាំង និយចំណុចខ្សោយក្នុងការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន ចំណុចខ្លាំងចំណុចខ្សោយក្នុងការដឹកនាំការរៀននិងបង្រៀន ចំណុចខ្លាំងនិងចំណុចខ្សោយក្នុងការប្រាស្រ័យទាក់ទង ចំណុចខ្លាំងនិងចំណុចដែលត្រូវកែលម្អចំពោះហេដ្ឋារចនាសម្ព័ន្ធ ការយល់ឃើញចំពោះសម្ភារៈរូបវ័ន្ត ចំពោះលោកគ្រូអ្នកគ្រូស្វែងរកពីការប្រើប្រាស់វិធីសាស្ត្របង្រៀនញឹកញាប់ជាងគេ ការប្រើប្រាស់វិធីបង្រៀនតាមបែប រិះរក តាមបែបបង្រៀនផ្អែកលើគម្រោង តាមបែបប្រើប្រាស់វិធីសាស្ត្រវាយតម្លៃតាមប្លូមដើម្បីកំណត់វត្ថុបំណងមេរៀន និងចំពោះសិស្សឱ្យឃើញពីចំណុចខ្លាំង និងចំណុចដែលត្រូវបន្ថែមចំពោះការសិក្សា និងលទ្ធផលសិក្សា ចំណុចខ្លាំងនិងចំណុចដែលត្រូវកែលម្អចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការយល់ឃើញចំពោះសម្ភារៈរូបវ័ន្តដែលលោកគ្រូអ្នកគ្រូប្រើប្រាស់ក្នុងការបង្រៀន នៅវិទ្យាល័យទាំងពីរក្នុងខេត្តកំពង់ចាម និងផ្ដុំមតិ និងសំណូមពររបស់សិស្ស គ្រូ និងនាយកដាក់ទៅតាមចំណុចដែលដូចគ្នាក្នុងគោលបំណងលើកជាអនុសាសន៍ និងសំណូមពរចំពោះក្រសួងអប់រំ មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក សាលា និងលោកគ្រូ/អ្នកគ្រូដើម្បីជ្រាបជាព័ត៌មាន ការកែទម្រង់និងចាត់ជាវិធានការចំពោះបញ្ហាប្រឈមដែលកើតមានឡើង។

## ៣.១០ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវបានធ្វើការណែនាំខ្លួននិងប្រាប់ពីគោលបំណង សុំឱ្យបំពេញកម្រងសំណួរ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជារក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងៗឡើយ ហើយរាល់ការសម្ភាសត្រូវបានសុំការអនុញ្ញាត និងមានការឯកភាពពីអ្នកត្រូវសម្ភាសផងដែរ។ ក្នុងដំណើរការបំពេញកម្រងសំណួរគឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នកសម្ភាស បានរៀបចំខ្លួនដោយមានសម្លៀកបំពាក់សមរម្យ ទឹកមុខញញឹមរួសរាយ និងបង្ហាញនូវភាពស្និទ្ធស្នាលប្រើកាយវិកាទន់ភ្លន់ និងអង្គុយតាមបែបបទគោលការណ៍អ្នកសម្ភាសជាពិសេស អ្នកសិក្សាស្រាវជ្រាវមិនធ្វើការផ្ដល់យោបល់ ឬអនុសាសន៍ផ្សេងៗដល់អ្នកត្រូវសម្ភាសជាដាច់ខាត ។

### ៣.១១ ព្រំដែននៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីនៅក្នុងខេត្តកំពង់ចាមតែប៉ុណ្ណោះ។ រាល់កម្រងសំណួរនិងខ្លឹមសារសម្ភាសគឺមិនសំដៅទៅលើអ្វីដែលមិនពាក់ព័ន្ធនឹងខ្លឹមសារប្រធានបទនៃការសិក្សាស្រាវជ្រាវនោះទេ។ ព័ត៌មានដែលទទួលបានត្រូវបានរក្សាដោយសម្ងាត់ និងមិនបានយកឈ្មោះឬអ្វីបញ្ជាក់អត្តសញ្ញាណរបស់ពួកគាត់ទេ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើង ដោយចង់ដឹងពីលទ្ធផលសិក្សារបស់សិស្សានុសិស្សនៅសាលាជំនាន់ថ្មី ដោយផ្តោតតែលើវិទ្យាល័យតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតចំពោះតំបន់ដែលបានធ្វើការសិក្សាស្រាវជ្រាវនេះ មានលក្ខណៈតូចនៅឡើយដូច្នេះមិនអាចតំណាងឱ្យក្នុងប្រទេសបានទេ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤

# លទ្ធផលនៃការសិក្សាស្រាវជ្រាវ

នៅក្នុងជំពូកទី៤នេះនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការសម្ភាសរបស់ធាតុសំណាកដែលរួមមានលោកនាយក លោកគ្រូ/អ្នកគ្រូបង្រៀន និងសិស្សានុសិស្សថ្នាក់ទី៧,៨,៩,១០ និងទី១១។ រាល់ចំណុចសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងប្រធានបទត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា។ កម្មវិធី SPSS ត្រូវបានប្រើសម្រាប់បញ្ចូលទិន្នន័យ និងវិភាគ ចំណែកឯកម្មវិធី Ms. Excel ត្រូវបានប្រើប្រាស់សម្រាប់សង់ក្រាហ្វិក និងបកប្រែជាភាសាខ្មែរដោយយកទិន្នន័យពីកម្មវិធី SPSS ស្វែងរកលទ្ធផលសិក្សារបស់សិស្សានុសិស្សនៅសាលារៀនជំនាន់ថ្មីនៅក្នុងខេត្តកំពង់ចាម។ នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួររបស់អ្នកចូលរួម។ ការវិភាគលើកម្រងសំណួរ មានគោលបំណង ស្វែងរកពីការដឹកនាំនិងគ្រប់គ្រង ការបង្រៀននិងរៀន និងលទ្ធផលសិក្សារបស់សិស្ស។ ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធនានាដូចជា៖ នាយក លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ត្រូវបានវិភាគដាច់ដោយឡែកពីគ្នាដើម្បីស្វែងរកលក្ខណៈសម្បត្តិរបស់គ្រូបង្រៀន និងការដឹកនាំ គ្រប់គ្រងរបស់នាយកសាលា ការសិក្សារបស់សិស្សានុសិស្ស ហើយនិងលទ្ធផលនៃការសិក្សារបស់សិស្សត្រូវបានយកមកវិភាគ គឺធ្វើឡើងតំណាងឱ្យទិដ្ឋភាពរួមនៃការសិក្សារបស់សិស្សដែលកំពុងសិក្សានៅសាលាជំនាន់ថ្មីនៅក្នុងខេត្តកំពង់ចាម។

## *៤.១- លទ្ធផលនៃការសិក្សាស្រាវជ្រាវ*

### *៤.១.១- ព័ត៌មានផ្ទាល់ខ្លួន*

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសក្រុមគោលដៅដែលត្រូវទៅតាមលក្ខខណ្ឌកំណត់នៅក្នុងគម្រូជ្រើសរើសដូចជា ថ្នាក់ដឹកនាំសាលារៀន

(នាយក/នាយិកា និងនាយករង/នាយិការង) គ្រូបង្រៀន (ថ្នាក់ទី៧, ទី៨, ទី៩, ទី១០ និងទី១១) និងសិស្សានុសិស្សតាមវិទ្យាល័យគោលដៅទាំងពីរចាប់ពីថ្នាក់ទី៧, ទី៨, ទី៩, ទី១០ ដល់ថ្នាក់ទី១១នឹងត្រូវជ្រើសរើសជាគំរូសម្រាប់ធ្វើការសិក្សាស្រាវជ្រាវនេះ។ ដូច្នេះភាគរយនៃផលធៀបភេទ និងអាយុរបស់អ្នកចូលរួមមិនត្រូវបានធ្វើការកំណត់ទុកជាមុនឡើយ។ ជាលទ្ធផល អ្នកស្រាវជ្រាវទទួលបានអ្នកចូលរួមសរុបចំនួន ៩១ នាក់ដែលរួមមាន៖ គណៈគ្រប់គ្រងសាលារៀនចំនួន ០២ នាក់ គ្រូបង្រៀនថ្នាក់ទី៧ដល់ថ្នាក់ទី១១មានចំនួន ១៩ នាក់ និងសិស្សនៅវិទ្យាល័យទាំងពីរមានចំនួន ៧០ នាក់។ កម្រងសំណួរទាំងអស់ដែលបានចែកជូនដល់អ្នកពាក់ព័ន្ធមានចំនួន ៩២ច្បាប់ តែបានប្រគល់ត្រឡប់មកវិញចំនួនតែ ៩១ ច្បាប់ប៉ុណ្ណោះ និងខកខានមិនបានប្រគល់កម្រងសំណួរត្រឡប់មកវិញមានចំនួន ០១ ច្បាប់សម្រាប់សាលាវិទ្យាល័យជំនាន់ថ្មីចំនួន ០២ ក្នុងចំណោមសាលារៀនជំនាន់ថ្មីទូទាំងខេត្តកំពង់ចាម។

**តារាងទី១៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ**

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ២ នាក់ | ០ នាក់ | ២ នាក់ |
| គ្រូបង្រៀន | ៧ នាក់ | ១២ នាក់ | ១៩ នាក់ |
| សិស្ស | ២៤ នាក់ | ៤៦ នាក់ | ៧០ នាក់ |
| សរុប | ៣៣ នាក់ | ៥៨ នាក់ | ៩១ នាក់ |

**តារាងទី២ ៖ កម្រិតវប្បធម៌ នាយក និងគ្រូបង្រៀន**

| **កម្រិតវប្បធម៌** | **នាយក** | | **គ្រូបង្រៀន** | | **សរុប** |
|---|---|---|---|---|---|
| | **ប្រុស** | **ស្រី** | **ប្រុស** | **ស្រី** | |
| មធ្យមសិក្សាបឋមភូមិ | ០ | ០ | ០ | ០ | ០ |
| មធ្យមសិក្សាទុតិយភូមិ | ០ | ០ | ២ | ៣ | ៥ |
| បរិញ្ញាបត្ររង | ០ | ០ | ១ | ០ | ១ |
| បរិញ្ញាបត្រ | ២ | ០ | ៤ | ៨ | ១៤ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ០ | ០ | ០ | ១ | ១ |
| ផ្សេងៗ | ០ | ០ | ០ | ០ | ០ |

**តាមតារាងទី២ ៖** នាយកសាលាដែលបានចូលរួមឆ្លើយសំណួរមានចំនួនសរុប (២នាក់) ក្នុងនេះនាយកសាលាមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រទាំងពីរនាក់។ ចំណែកឯគ្រូបង្រៀនវិញចូលរួម សុរបមានចំនួន ១៩ នាក់ ស្រី១២នាក់ ។ លោកគ្រូអ្នកគ្រូដែលមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រមានចំនួន ១២ នាក់ ស្រី ៨ នាក់ លោកគ្រូអ្នកគ្រូដែលមានកម្រិតសិក្សាត្រឹមបរិញ្ញាបត្ររងគឺមានចំនួន ១ នាក់ ស្រី ០ នាក់ និងលោកគ្រូអ្នកគ្រូដែលមានកម្រិតសិក្សាត្រឹមមធ្យមសិក្សាទុតិយភូមិមានចំនួន ៥ នាក់ ស្រី៣នាក់។ យើងសង្កេតឃើញថា ចំនួនគ្រូបង្រៀនដែលមានកម្រិតសញ្ញាបត្របរិញ្ញាបត្រមានចំនួនច្រើនជាងគ្រូដែលមានកម្រិតវប្បធម៌ទាបជាងបរិញ្ញាបត្រ ។

តាមការសម្ភាសន៍និងអង្កេតឃើញថាគុណវុឌ្ឍិរបស់លោកគ្រូអ្នកគ្រូ និងនាយកគឺសមស្រប និងសាលាជំនាន់ថ្មី និងកម្រិតថ្នាក់។

**តារាងទី៣ ៖ កម្រិតវិជ្ជាជីវៈ នាយក និងគ្រូបង្រៀន**

| កម្រិតវិជ្ជាជីវៈ | នាយក | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| បឋមសិក្សា | ០ | ០ | ០ | ០ | ០ |
| កម្រិតមូលដ្ឋាន | ០ | ០ | ៥ | ៨ | ១៣ |
| កម្រិតឧត្តម | ២ | ០ | ២ | ៤ | ៨ |

**តាមតារាងទី៣៖** នាយកវិទ្យាល័យទាំងអស់ សុទ្ធសឹងជាគ្រូបង្រៀនកម្រិតឧត្តម១០០% និងមិនមាននាយកណាម្នាក់ជាគ្រូកម្រិតមូលដ្ឋាន ឬបឋមសិក្សានោះទេ។ ចំពោះគ្រូបង្រៀនចំនួន 31.58% មានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តមសិក្សា ចំណែកឯគ្រូបង្រៀន 68.42% មានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតមូលដ្ឋាន។ នេះបញ្ជាក់បានថាគ្រូបង្រៀននៅកម្រិតមធ្យម សិក្សាបឋមភូមិមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្តី ពីធនធានមនុស្សក្នុងវិស័យអប់រំ (ឆ្នាំ២០១២) ។

**ដ្យាក្រាមទី១ ៖ អតីតភាពការងារមុខតំណែងរបស់ នាយក និងគ្រូបង្រៀន (%)**




**តាមដ្យាក្រាមទី១** បង្ហាញថាអ្នកដែលបានចូលរួមឆ្លើយសំណួរ មានគ្រូចំនួន ១០.៥៣% ស្មើ២នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនទាបជាង១ឆ្នាំ។ គ្រូចំនួន ២១.០៥% ស្មើ៤នាក់ មានអតីតាពការងារក្នុងមុខ តំណែងរបស់ខ្លួនចន្លោះពី១-៥ឆ្នាំ។ គ្រូចំនួន១០.៥៣ % ស្មើ២នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនចន្លោះពី៥-១០ឆ្នាំ។ គ្រូចំនួន៤១.១១% ស្មើ៨នាក់មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនចន្លោះពី១០-២០ឆ្នាំ។ នាយកសាលាចំនួន១០០.០០ % ស្មើ ២នាក់ គ្រូបង្រៀនចំនួន ១៥.៧៩% ស្មើ៣នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនលើសពី ២០ឆ្នាំ។ នេះបង្ហាញថានាយក និងគ្រូបង្រៀនដែលបានចូលរួមឆ្លើយសំណួរភាគច្រើន មានអតីតភាពការងារលើសពី១០ឆ្នាំ។ ទាំងនេះបញ្ជាក់ថាលោកគ្រូអ្នកគ្រូភាគច្រើនមានបទពិសោធន៍ក្នុងការបង្រៀនលើសពី៥ឆ្នាំ មានន័យថាពួកគាត់អាចមានវិធីសាស្ត្រច្រើនក្នុងការបង្ហាត់បង្រៀន និងការរៀបចំសម្ភារៈឧបទេសទាក់ទងនឹងមេរៀនបានច្រើន។

**ដ្យាក្រាមទី២ ៖ លោកគ្រូអ្នកគ្រូបង្រៀនត្រូវឯកទេស និងបង្រៀនខុសឯកទេស**



**តាមដ្យាក្រាមទី២** បង្ហាញថាមានលោកគ្រូអ្នកគ្រូចំនួន១៤នាក់បង្រៀនត្រូវឯកទេសត្រូវជា៧៣.៦៨ % និងលោកគ្រូអ្នកគ្រូចំនួន ៥នាក់ត្រូវជា២៦.៣២ %បង្រៀនខុសឯកទេស។ នេះបង្ហាញឱ្យឃើញថាការបែងចែកគ្រូបង្រៀននូវមិនទាន់សមស្របទៅនឹងគោលនយោបាយសាលាជំនាន់ថ្មីនៅឡើយទេដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស ឬការសិក្សារបស់សិស្សមិនសូវបានស៊ីជម្រៅ។

**ដ្យាក្រាមទី៣ ៖ ចំនួនសិស្សតាមកម្រិតថ្នាក់ (នាក់)**




**តាមដ្យាក្រាមទី៣** សិស្សដែលបានចូលរួមបំពេញកម្រងសំណួររួមមានថ្នាក់ទី៧ ចំនួន២៣នាក់ ស្រី១៥នាក់ ថ្នាក់ទី៨មាន ២៣នាក់ ស្រី ១៧នាក់ ថ្នាក់ទី៩មាន ៦នាក់ ស្រី ៥នាក់ ថ្នាក់ទី១០ចំនួន១១នាក់ ស្រី៧នាក់ និងថ្នាក់ទី១១ ចំនួន៧នាក់ ស្រី២នាក់។ យើងសង្កេតឃើញថា សិស្សថ្នាក់ទី៧ និងទី៨ ចូលរួមឆ្លើយកម្រងសំណួរមានចំនួនច្រើនជាងគេពីព្រោះនៅវិទ្យាល័យ ហ៊ុន សែន ពាងជីកងទើបតែមានត្រឹមថ្នាក់ទី៧និងទី៨ប៉ុណ្ណោះ ហើយនិងសិស្សស្រីដែលបានចូលរួមឆ្លើយកម្រងសំណួរមានចំនួនច្រើនជាងសិស្សប្រុស ពីព្រោះការជ្រើសរើសសិស្សឱ្យបំពេញកម្រងសំណួរត្រូវបានធ្វើឡើងដោយចៃដន្យ។

ដ្យាក្រាមទី៩៖ការធ្វើតេស្តសិស្សការប្រឡងប្រជែងជ្រើសរើសនាយកនិងលោកគ្រូអ្នកគ្រូ




**តាមដ្យាក្រាមទី៩** គឺថាទាំងនាយកសាលា និងលោកគ្រូ អ្នកគ្រូសុទ្ធតែបានឆ្លងកាត់ការប្រឡងប្រកួតប្រជែងដើម្បីចូលមកគ្រប់គ្រងនិងបង្រៀននៅសាលារៀននេះគឺ មានចំនួន ២១នាក់ ត្រូវជា១០០ % និងសិស្សានុសិស្សមានចំនួន៥៦នាក់ ត្រូវជា ៨០.០០% ឆ្លងកាត់ការប្រឡងដើម្បីចូលមករៀននៅសាលានេះ និងមានសិស្សានុសិស្សចំនួន១៤នាក់ ត្រូវជា ២០.០០ % ដែលកំពុងរៀននៅសាលានេះដោយមិនបានឆ្លងកាត់ការប្រឡងចូល។ ក៏ប៉ុន្តែតាមការសម្ភាសជាមួយនាយកសាលាវិទ្យាល័យ ហ៊ុន សែន អនុវត្ត លោក សឿង វ៉ាន់បានផ្តល់ព័ត៌មានថាចំនួនសិស្សដែលមិនបានឆ្លងកាត់ការធ្វើតេស្តជាមុន មុននឹងចូលរៀននៅសាលារៀននេះ ពីព្រោះពួកគេគឺបានសិក្សានៅសាលាបឋមសិក្សាជំនាន់ថ្មីទីនេះតែម្តង។ ដូច្នេះពួកគេមិនបាច់ឆ្លងកាត់ការធ្វើតេស្តទេ ពេលឡើងថ្នាក់ចូលមករៀននៅកម្រិតអនុវិទ្យាល័យរហូតដល់វិទ្យាល័យ។

តាមទិន្នន័យនៅក្នុងតារាងនេះគឺបង្ហាញថាការជ្រើសរើសនាយក គ្រូបង្រៀន និងសិស្សនៅសាលាជំនាន់ថ្មីនេះប្រព្រឹត្តិទៅតាមគោលការណ៍របស់សាលាជំនាន់ថ្មី។

## *៤.២- ករម្រងសំណួរសម្រាប់នាយក*

ដោយសារតែនៅក្នុងសំណួរនីមួយៗមានប្រាំជម្រើសគឺចាប់ពីលេខ១ដល់លេខ៥ នោះវាមាន៤ចន្លោះ ហើយពិន្ទុដែលធំជាងគេគឺ៥ ដូចនេះយើងបាន មួយចន្លោះខុសគ្នា 0.80

តាម Likert Scale

ដូចនេះចំពោះពិន្ទុនៃសំណួរនីមួយៗគិតតាមមធ្យមគឺ

❖ ពិន្ទុចាប់ពី ១-១.៨០ ខ្សោយ

❖ ពិន្ទុចាប់ពី ១.៨១-២.៦០ មធ្យម

❖ ពិន្ទុចាប់ពី ២.៦១-៣.៤០ ល្អបង្គួរ

❖ ពិន្ទុចាប់ពី ៣.៤១-៤.២០ ល្អ

❖ ពិន្ទុចាប់ពី ៤.២១-៥.00 ល្អណាស់

### ៤.២.១៖ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិតរបស់នាយក

**តារាងទី៤៖ សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត**

| | សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត | មធ្យម |
|---|---|---|
| ៦ | យល់ដឹងពីគោលនយោបាយអប់រំក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ | 3.50 |
| ៧ | ការដឹកនាំ គ្រប់គ្រង សម្របសម្រួល និងឆ្នៃប្រឌិត | 4.00 |
| ៨ | ការងារអធិការកិច្ច | 3.00 |
| ៩ | ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យា | 3.50 |
| ១០ | ជំនាញវិភាគ និងបកស្រាយព័ត៌មាន | 3.50 |
| ១១ | ចំណេះដឹងភាសាបរទេស(ភាសាអង់គ្លេស,.............) | 3.00 |
| ១២ | លើទឹកចិត្តសិស្ស គ្រូ និងបុគ្គលិកអប់រំ | 4.00 |

**តាមតារាងទី៤** គឺនាយកសាលារៀនទាំងពីរគឺមានជំនាញនិងគំនិតឆ្នៃប្រឌិតល្អភាគច្រើន ដូចជាការយល់ដឹងពីគោលនយោបាយអប់រំក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យា ជំនាញវិភាគនិងបកស្រាយព័ត៌មាន ហើយពិសេសជាងនេះទៅទៀតគឺ នាយកសាលាមានសមត្ថភាព និងការឆ្នៃប្រឌិតល្អចំពោះការដឹកនាំគ្រប់គ្រង សម្របសម្រួល និងការលើកទឹកចិត្តសិស្ស គ្រូនិងបុគ្គលិកអប់រំ ប៉ុន្តែចំពោះការងារអធិការកិច្ច និងចំណេះដឹងភាសាអង់គ្លេសគឺមានកម្រិតល្អបង្គួរនៅឡើយ ដូចនេះនាយកសាលាគួរតែព្យាយាមបង្កើនការធ្វើអធិការកិច្ច និងចំណេះដឹងភាសាអង់គ្លេសពីព្រោះនៅក្នុងវិទ្យាល័យជំនាន់ថ្មី ផ្តោតអារម្មណ៍សំខាន់ទៅលើការពង្រីកចំណេះដឹងព័ត៌មានវិទ្យា និងភាសាអង់គ្លេសបន្ថែម។ទាំងនេះបង្ហាញឱ្យឃើញថាសមត្ថភាពជំនាញ

និងគំនិតច្នៃប្រឌិតរបស់ពួកគាត់គឺមានលក្ខណៈល្អប្រសើរដែលសាកសមនឹងនាយកនៅសាលាជំនាន់ថ្មី។

### ៤.២.២៖ ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន

**តារាងទី៥៖ ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន**

| | ការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀន | មធ្យម |
|---|---|---|
| ១៣ | រៀបចំរចនាសម្ព័ន្ធនិងបំណែងចែកភារកិច្ច | 4.00 |
| ១៤ | គ្រប់គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ | 3.50 |
| ១៥ | រៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប | 4.00 |
| ១៦ | ការរៀបចំបរិស្ថានសាលាល្អ អនាម័យស្អាតឯកសណ្ឋានសិស្ស គ្រូ | 4.00 |
| ១៧ | ការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាក្នុងដំណើរការគ្រប់គ្រងសាលារៀន | 4.00 |
| ១៨ | ធានាសុវត្ថភាពគ្រូបង្រៀន និងសិស្ស | 4.00 |
| ១៩ | ការរៀបចំកិច្ចបញ្ជីកាគណនេយ្យហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ និងបញ្ជីគ្រប់គ្រងវត្តមានគ្រូ បុគ្គលិកបានត្រឹមត្រូវ | 4.00 |
| ២០ | គ្រូយល់ដឹងកម្មវិធីសិក្សាតាមកម្រិតថ្នាក់ | 3.50 |
| ២១ | គ្រូបង្រៀនមានសមត្ថភាពលើវិធីសាស្ត្រនិងបច្ចេកទេសបង្រៀន និងរៀនតាមមុខវិជ្ជាបានត្រឹមត្រូវ | 3.50 |
| ២២ | អត្រាសិស្សបោះបង់ការសិក្សាទាបជាងឬស្មើថ្នាក់ជាតិ | 3.50 |
| ២៣ | អត្រាសិស្សឡើងថ្នាក់ស្មើឬខ្ពស់ជាងថ្នាក់ជាតិ | 3.50 |
| ២៤ | សិស្សមានសមត្ថភាពសមនឹងកម្រិតថ្នាក់ | 4.00 |
| ២៥ | ផ្គត់ផ្គង់និងថែរក្សាសៀវភៅសិក្សាគោល | 4.00 |
| ២៦ | បិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាព | 4.00 |

**តាមតារាងទី៥** គឺថាការគ្រប់គ្រងគ្រូ សិស្ស និងសាលារៀនរបស់នាយកសាលាគឺពិតជាល្អ រួមមាន ការរៀបចំរចនាសម្ព័ន្ធនិងបំណែងចែកភារកិច្ច ការគ្រប់គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប ការរៀបចំបរិស្ថានសាលាល្អ អនាម័យស្អាត ឯកសណ្ឋានសិស្ស គ្រូ ការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យា

ក្នុងដំណើរការគ្រប់គ្រងសាលារៀន ការរៀបចំកិច្ចបញ្ជីកាគណនេយ្យហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ និងបញ្ជីគ្រប់គ្រងវត្តមានគ្រូ បុគ្គលិកបានត្រឹមត្រូវ គ្រូយល់ដឹងកម្មវិធីសិក្សាតាមកម្រិតថ្នាក់ គ្រូបង្រៀនមានសមត្ថភាពលើវិធីសាស្ត្រនិងបច្ចេកទេសបង្រៀននិងរៀនតាមមុខវិជ្ជាបានត្រឹមត្រូវ អត្រាសិស្សបោះបង់ការសិក្សាទាបជាងឬស្មើថ្នាក់ជាតិ អត្រាសិស្សឡើងថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិសិស្សមានសមត្ថភាពសមនឹងកម្រិតថ្នាក់ផ្គត់ផ្គង់ និងថែរក្សាសៀវភៅសិក្សាគោល និងបិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាព។

ជាពិសេសតាមការធ្វើសម្ភាសន៍នាយក និងសង្កេតគឺថាពួកគាត់មានចំណុចខ្លាំងក្នុងការគ្រប់គ្រងអវត្តមានគ្រូរាល់ម៉ោងបំពេញការងារ និងសិស្សរាល់ម៉ោងសិក្សាដែលជាហេតុធ្វើឱ្យការធ្វើឱ្យសិស្សមកសិក្សាទាន់ពេលវេលាទើប ញាំងឱ្យការគ្រប់គ្រងរបស់នាយកបានល្អ មានមនសិការវិជ្ជាជីវៈខ្ពស់ ស្មោះត្រង់ មានចំណេះដឹងផ្នែកបច្ចេកវិទ្យា និងភាសាដែលធ្វើឱ្យមានភាពងាយស្រួល ក្នុងការគ្រប់គ្រងជានាយកសាលាជំនាន់ថ្មីដែលជាសាលាសតវត្សទី២១ ជាពិសេសពួកគាត់មានទំនាក់ទំនងល្អជាមួយសហគមន៍ សិស្សគ្រូ និងចេះលើកទឹកចិត្តបុគ្គលិក។ ប៉ុន្តែក៏នៅមានបញ្ហាប្រឈមតិចតួចផងដែរចំពោះវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយនៅរដូវវស្សាគឺសិស្សនិងគ្រូមួយចំនួនមករៀននិងបង្រៀនមិនទាន់ម៉ោងដោយសារពិបាកក្នុងការធ្វើដំណើរ និងជាពិសេសទៅទៀតគឺលោកនាយកវិទ្យាល័យ ហ៊ុន សែន ពាមជីកង មានបទពិសោធន៍តិចតួចទាក់ទងនឹងសាលាជំនាន់ថ្មីនេះពីព្រោះទើបតែបានប្រហែលជា៣ខែប៉ុណ្ណោះ។

## *៤.២.៣៖ ការដឹកនាំការបង្រៀន និងរៀន*

**តារាងទី៦៖ ការដឹកនាំការរៀន និងបង្រៀន**

| | ការដឹកនាំការរៀន និងបង្រៀន | មធ្យម |
|---|---|---|
| ២៧ | ផ្តួចផ្តើមនិងការគាំទ្រការប្រជុំក្រុមបច្ចេកទេស | 4.00 |
| ២៨ | ត្រួតពិនិត្យនិងវាយតម្លៃការរៀននិងបង្រៀនជាប្រចាំ | 3.50 |
| ២៩ | បំប៉នវិធីសាស្ត្រ និងផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូបង្រៀន | 3.50 |

| | | |
|---|---|---|
| ៣០ | អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន | 4.00 |
| ៣១ | លើកទឹកចិត្តនិងចេះធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែក | 4.00 |
| ៣២ | ធានាឱ្យមានសម្ភារៈសិក្សា និងសម្ភារឧបទេស | 4.00 |

**តាមតារាងទី៦** គឺថាការដឹកនាំការរៀននិងបង្រៀនរបស់លោកគ្រូបានល្អ ការផ្តួចផ្តើមនិងការគាំទ្រការប្រជុំក្រុមបច្ចេកទេសបានល្អ ការត្រួតពិនិត្យនិងវាយតម្លៃការរៀននិងបង្រៀនជាប្រចាំបានល្អ ការបំប៉នវិធីសាស្ត្រ និងផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូបានល្អ ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនបានល្អ ការលើកទឹកចិត្តនិងចេះធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែកបានល្អ និងការធានាឱ្យមានសម្ភារៈសិក្សានិងសម្ភារឧបទេសបានល្អ។ លើសពីនេះទៅទៀត គឺលោកនាយកថាលោកគ្រូអ្នកគ្រូមានកិច្ចតែងការបង្រៀន មានសៀវភៅរដ្ឋបាលគ្រប់គ្រាន់ ជាពិសេសគឺនាយកធ្លាប់មានបទពិសោធន៍បណ្តុះបណ្តាលគ្រូ ធ្លាប់រៀបចំឯកសារបំប៉នគ្រូ និងស្រាវជ្រាវពីវិធីសាស្ត្របង្រៀនផ្សេងៗទាំងនេះហើយដែលជួយជំរុញឱ្យការដឹកនាំការបង្រៀន និងរៀនកាន់តែទទួលបានលទ្ធផលល្អ។ ឆ្លងតាមការសម្ភាសន៍និងសង្កេតគឺថាលោកនាយកមានការដឹកនាំការបង្រៀនបានល្អដូចជាការត្រួពិនិត្យនិងវាយតម្លៃជាប្រចាំ និងផ្តល់ការប្រឹក្សាបន្ថែមដល់លោកគ្រូអ្នកគ្រូ និងមានការផ្តល់ការលើកទឹកចិត្តដល់ពួកគាត់ផងដែរ។

### *៤.២.៤៖ បំណិនប្រាស្រ័យទាក់ទង*

**តារាងទី៧៖ បំណិនប្រាស្រ័យទាក់ទង**

| | **បំណិនប្រាស្រ័យទាក់ទង** | **មធ្យម** |
|---|---|---|
| ៣៣ | ទំនាក់ទំនងល្អជាមួយសិស្ស គ្រូ បុគ្គលិក មាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាច និងអ្នកពាក់ព័ន្ធ | 4.00 |
| ៣៤ | ផ្តល់ព័ត៌មានត្រឡប់ជាប្រព័ន្ធដល់មាតាបិតា សិស្ស គ្រូ និងសាលា | 4.00 |
| ៣៥ | បង្កើតនិងរក្សាស្នាដៃសិស្សដើម្បីជំរុញឪពុកម្តាយនិងសហគមន៍ឱ្យចូលរួមឧបត្ថម្ភ គាំទ្រ | 4.00 |

**តាមតារាងទី៧** គឺនាយកសាលាទាំងពីរមានបំណិនប្រាស្រ័យទាក់ទងល្អ ពោលគឺលោកនាយកមានទំនាក់ទំនងល្អជាមួយសិស្សានុសិស្ស គ្រូ បុគ្គលិកទីចាត់ការ មាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាច និងអ្នកពាក់ព័ន្ធផ្សេងទៀតបានល្អ។ តាមរយៈការសម្ភាសន៍និងសង្កេតឆ្លុះឱ្យឃើញថា លោកនាយកទាំងពីរពិតជាប៉ិនប្រសប់ក្នុងការទំនាក់ទំនងជាមួយសហគមន៍ មាតាបិតាសិស្ស រួសរាយរាក់ទាក់ជាមួយបុគ្គលិក សាធារណៈជន ពិសេសមានទំនាក់ទំនងល្អជាមួយដៃគូអភិវឌ្ឍ NGO និងមានសមត្ថភាពខ្ពស់ក្នុងការបញ្ចុះបញ្ចូលអ្នកពាក់ព័ន្ធដើម្បីស្វែងរកការគាំទ្រគម្រោង និងផែនការ។

## *៤.២.៥៖ ក្រមសីលធម៌វិជ្ជាជីវៈនាយក*

**តារាងទី៨៖ ក្រមសីលធមិវិជ្ជាជីវៈនាយក**

| | ក្រមសីលធមិវិជ្ជាជីវៈនាយក | មធ្យម |
|---|---|---|
| ៣៦ | ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ | 4.00 |
| ៣៧ | ពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ | 4.00 |
| ៣៨ | គោរពវិន័យការងារ | 4.00 |
| ៣៩ | សីលធមិរស់នៅល្អ គុណធមិ និងយុត្តិធមិ | 4.00 |

**តាមតារាងទី៨** គឺថានាយកសាលាមានក្រមសីលធមិវិជ្ជាជីវៈជានាយកបានល្អ ពោលគឺគាត់ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈបានល្អ ពង្រឹងសមគ្គីភាព និងការទទួលខុសត្រូវបានល្អ ការគោរពវិន័យបានល្អ និងសីលធមិរស់នៅល្អ មានគុណធមិ និងមានយុត្តិធមិចំពោះអង្គភាព។ជាពិសសេសនៅពេលដែលខ្ញុំបានចុះទៅដល់សាលានិងរៀបរាប់ពីអ្វីដែលចង់ឱ្យគាត់សហការគឺគាត់បានសហការយ៉ាងល្អ និងនិយាយមកកាន់ខ្ញុំប្រកបដោយការស្វាគមន៍និងរាក់ទាក់។

**តើកត្តាខាងក្រោមកំណត់ពីប្រសិទ្ធិភាពរបស់លោក/លោកស្រីក្នុងនាមជានាយកសាលានេះកម្រិតណា?**

**តារាងទី៩៖ កត្តាកំណត់ពីប្រសិទ្ធិភាពរបស់នាយកក្នុងការដឹកនាំ ដំណើរការរៀននិងបង្រៀន**

| | | អត់សោះ | តិចតួច | មធ្យម | ច្រើន |
|---|---|---|---|---|---|
| ក | ថវិកាដំណើរការសាលារៀន | | | ✓ | |

| | | | | | |
|---|---|---|---|---|---|
| ខ | គោលការណ៍អនុវត្តដោយឡែករបស់សាលាជំនាន់ថ្មី | | | | ✓ |
| គ | វត្តមានរបស់លោកគ្រូ អ្នកគ្រូ | | | | ✓ |
| ឃ | ការចូលរួមនិងគាំទ្រពីមាតាបិតាសិស្ស | | | | ✓ |
| ង | ប្រាក់បៀវត្សរបស់លោកគ្រូ អ្នកគ្រូ | | | ✓ | |
| ច | ឱកាសនិងការគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន | | | ✓ | |
| ឆ | បន្ទុកការងារ និងកម្រិតនៃការទទួលខុសត្រូវក្នុងការងារ | | | | ✓ |
| ជ | ភាពជាអ្នកដឹកនាំរួមគ្នាជាមួយសមាជិកបុគ្គលិកសាលារៀនផ្សេងទៀត | | | | ✓ |

**តាមតារាងទី៩** កត្តាដែលកំណត់ពីប្រសិទ្ធភាពរបស់នាយកសាលាច្រើនរួមមានគោលការណ៍អនុវត្តដោយឡែករបស់សាលាជំនាន់ថ្មី វត្តមានរបស់លោកគ្រូ អ្នកគ្រូ ការចូលរួមនិងគាំទ្រពីមាតាបិតាសិស្ស បន្ទុកការងារ និងកម្រិតនៃការទទួលខុសត្រូវក្នុងការងារ និងភាពជាអ្នកដឹកនាំរួមគ្នាជាមួយសមាជិកបុគ្គលិកសាលារៀនផ្សេងទៀត។ ហេតុនេះត្រូវទាមទារអ្នកដែលមានភាពអត់ធ្មត់ តស៊ូ ឆ្វៃប្រឌិត និងមានមនសិការវិជ្ជាជីវៈ។ ចំពោះថវិកាដំណើរការសាលារៀន ប្រាក់បៀវត្សរ៍របស់លោកគ្រូ អ្នកគ្រូ និងឱកាសនិងការគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួនកំណត់ពីប្រសិទ្ធភាពរបស់នាយកមធ្យមមានន័យថាវាមិនសូវប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់នាយកធ្ងន់ធ្ងរទេ។

## ៤.៣ គម្រូវសំណួរសម្រាប់គ្រូ

ដោយសារតែនៅក្នុងសំណួរនីមួយៗមានប្រាំជម្រើសគឺចាប់ពីលេខ១ដល់លេខ៥ នោះវាមាន៤ចន្លោះ ហើយពិន្ទុដែលធំជាងគេគឺ៥ ដូចនេះយើងបាន មួយចន្លោះខុសគ្នា 0.80 តាម Likert Scale

ដូចនេះចំពោះពិន្ទុនៃសំណួរនីមួយៗគិតតាមមធ្យមគឺ

- ❖ ពិន្ទុចាប់ពី **១-១.៨០** ខ្សោយ
- ❖ ពិន្ទុចាប់ពី **១.៨១-២.៦០** មធ្យម
- ❖ ពិន្ទុចាប់ពី **២.៦១-៣.៤០** ល្អបង្គួរ
- ❖ ពិន្ទុចាប់ពី **៣.៤១-៤.២០** ល្អ
- ❖ ពិន្ទុចាប់ពី **៤.២១-៥.០០** ល្អណាស់

### ៤.៣.១ សមត្ថភាពជំនាញ និងគំនិតឆ្នៃប្រឌិត

តារាងទី១០៖ សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត

| | សមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិត | មធ្យម |
|---|---|---|
| ៨ | យល់ដឹងពីគោលនយោបាយអប់រំ | 3.32 |
| ៩ | ការដឹកនាំ គ្រប់គ្រង សម្របសម្រួល និងឆ្នៃប្រឌិត | 3.53 |
| ១០ | សមត្ថភាពក្នុងការបង្រៀនតាមគរុកោសល្យ | 3.53 |
| ១១ | ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យា | 3.00 |
| ១២ | ចំណេះដឹងភាសាបរទេស (ភាសាអង់គ្លេស............................) | 2.63 |
| ១៣ | ការបង្រៀនថ្នាក់និទស្សន៍ | 2.89 |
| ១៤ | ស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនិងបច្ចេកទេសបង្រៀនថ្មីៗ | 3.26 |
| ១៥ | ផលិតសម្ភារឧបទេស | 3.26 |
| ១៦ | កិច្ចតែងការបង្រៀន | 3.95 |
| ១៧ | រៀបចំផែនទីគំនិតថ្មីៗក្នុងដំណើរការបង្រៀន | 3.21 |

**តាមតារាងទី១០** គឺថាលោកគ្រូ អ្នកគ្រូមានសមត្ថភាពជំនាញនិងគំនិតឆ្នៃប្រឌិតល្អចំពោះ ការដឹកនាំ គ្រប់គ្រង សម្របសម្រួល និងឆ្នៃប្រឌិត សមត្ថភាពក្នុងការបង្រៀនតាមគរុកោសល្យ និងការធ្វើកិច្ចតែងការបង្រៀន ហើយមានភាពជាអ្នកដឹកនាំនិងគ្រប់គ្រងបានល្អបង្គួរចំពោះការយល់ដឹងពីគោលនយោបាយអប់រំ ចំណេះដឹងផ្នែកព័ត៌មានវិទ្យា ចំណេះដឹងថ្នាក់ភាសាអង់គ្លេស ការបង្រៀនថ្នាក់និទស្សន៍ ស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រ និងបច្ចេកទេសបង្រៀនថ្មីៗ ការផលិតសម្ភារឧបទេស និងការរៀបចំផែនទីគំនិតក្នុងដំណើរការបង្រៀន។

តាមរយៈការបំពេញកម្រងសំណួរនិងសង្កេតបញ្ជាក់ថាចំណេះដឹងលោកគ្រូអ្នកគ្រូលើវិធីសាស្ត្របង្រៀនថ្មីដូចជាការបង្រៀនតាមបែបរិះរក ការបង្រៀនតាមបែបសហការ ការបង្រៀនតាមបែបផ្អែកលើគម្រោង ការបង្រៀនតាមបែបស្ពានា និងការបង្រៀនដោយប្រើវិធីសាស្ត្រវាយតម្លៃតាមបែបប្លូមដើម្បីកំណត់វត្ថុបំណងរបស់មេរៀនដែលចាំបាច់ត្រូវប្រើប្រាស់នៅក្នុងសាលាជំនាន់ថ្មីនៅមានកម្រិតនៅឡើយ។ កត្តាទាំងអស់នេះអាចជះឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្សផងដែរ។

### ៤.៣.២ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង

**តារាងទី១១៖ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង**

| | ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង | មធ្យម |
|---|---|---|
| ១៨ | ការវិនិច្ឆ័យបានត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ | 3.74 |
| ១៩ | ការដឹកនាំសិស្សជួយការងារសង្គមនិងសហគមន៍ | 3.53 |
| ២០ | ការរៀបចំសៀវភៅរដ្ឋបាលថ្នាក់រៀន | 3.89 |
| ២១ | ការតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 3.89 |
| ២២ | ការគ្រប់គ្រងសកម្មភាពរៀននិងបង្រៀន | 3.68 |
| ២៣ | ការផ្តល់ការទទួលខុសត្រូវកែលម្អ និងផ្តល់ឱកាសដល់សិស្ស | 3.63 |
| ២៤ | ការសម្របសម្រួល និងការជំរុញសកម្មភាពក្លឹបសិក្សា | 3.74 |
| ២៥ | ដឹកនាំសិស្សធ្វើការសិក្សាស្រាវជ្រាវ | 3.47 |
| ២៦ | ធ្វើឱ្យថ្នាក់រៀនមានសកម្មភាពរស់រវើក | 3.68 |

**តាមតារាងទី១១** គឺថាលោកគ្រូ អ្នកគ្រូមានការដឹកនាំ និងគ្រប់គ្រងបានល្អពោលគឺមានការវិនិច្ឆ័យបានត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ ការដឹកនាំសិស្សជួយការងារសង្គមនិងសហគមន៍បានល្អ ការរៀបចំសៀវភៅរដ្ឋបាលថ្នាក់រៀនបានល្អ ការតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានល្អ ការគ្រប់គ្រងសកម្មភាពរៀននិងបង្រៀនបានល្អ ការផ្តល់ការទទួលខុសត្រូវកែលម្អ និងផ្តល់ឱកាសដល់សិស្សបានល្អ ការសម្របសម្រួល និងការជំរុញសកម្មភាពក្លឹបសិក្សាបានល្អ ដឹកនាំសិស្សធ្វើការសិក្សាស្រាវជ្រាវបានល្អ និងធ្វើឱ្យថ្នាក់រៀនមានសកម្មភាពរស់រវើក។

ទាំងនេះបញ្ជាក់ថាការដឹកនាំនិងគ្រប់គ្រងរបស់លោកគ្រូ អ្នកគ្រូគឺបានល្អ និងតាមរយៈការសង្កេតឃើញថាសិស្សមានវិន័យល្អនៅក្នុងសាលា និងនៅក្នុងថ្នាក់រៀន។

### ៤.៣.៣ បំណិនប្រាស្រ័យទាក់ទង

**តារាងទី១២៖ បំណិនប្រាស្រ័យទាក់ទង**

| | បំណិនប្រាស្រ័យទាក់ទង | មធ្យម |
|---|---|---|
| ២៧ | ទំនាក់ទំនងល្អជាមួយសិស្ស គ្រូ គណៈគ្រប់គ្រងសាលា មាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាច និងអ្នកពាក់ព័ន្ធ | 3.89 |
| ២៨ | ផ្តល់ព័ត៌មានដល់មាតាបិតាសិស្សជាប្រចាំ | 3.37 |

| | | |
|---|---|---|
| ២៩ | ស្វែងយល់ពីអារម្មណ៍របស់សិស្សម្នាក់ | 3.47 |

**តាមតារាងទី១២** គឺថាលោកគ្រូអ្នកគ្រូមានបំណិនទំនាក់ទំនងល្អជាមួយសិស្ស គ្រូបង្រៀនដូចគ្នា គណៈគ្រប់គ្រង មាតាបិតាសិស្ស សហគមន៍ រដ្ឋអំណាច និងអ្នកពាក់ព័ន្ធ និងស្វែងយល់ពីអារម្មណ៍របស់សិស្សម្នាក់បានល្អ និងការផ្ដល់ព័ត៌មានដល់មាតាបិតាសិស្សជាប្រចាំមានលក្ខណៈល្អបង្គួរតែប៉ុណ្ណោះ។

### ៤.៣.៤ លទ្ធផលសិក្សារបស់សិស្ស

**តារាងទី១៣៖ លទ្ធផលសិក្សារបស់សិស្ស**

| | លទ្ធផលសិក្សារបស់សិស្ស | មធ្យម |
|---|---|---|
| ៣០ | សិស្សមានចំណេះដឹងសមស្របតាមកម្មវិធីសិក្សា | 3.68 |
| ៣១ | អត្រាសិស្សបោះបង់ការសិក្សាទាបជាងឬស្មើថ្នាក់ជាតិ | 3.58 |
| ៣២ | អត្រាសិស្សឡើងថ្នាក់ស្មើឬខ្ពស់ជាងថ្នាក់ជាតិ | 3.63 |
| ៣៣ | សិស្សមានគំនិតច្នៃប្រឌិត | 3.47 |
| ៣៤ | សិស្សពូកែថ្នាក់ស្រុក ជាតិ ខេត្ត | 3.11 |
| ៣៥ | មាននិយ័តភាពសិក្សា ចេះស្វ័យសិក្សា | 3.74 |

**តាមតារាងទី១៣** គឺថាលទ្ធផលសិក្សារបស់សិស្សមានលទ្ធផលល្អពោលគឺសិស្សមានចំណេះដឹងសមស្របតាមកម្មវិធីសិក្សា អត្រាសិស្សបោះបង់ការសិក្សាទាបឬស្មើថ្នាក់ជាតិ អត្រាសិស្សឡើងថ្នាក់ស្មើឬខ្ពស់ជាងថ្នាក់ជាតិ សិស្សមានគំនិតច្នៃប្រឌិត និងសិស្សមាននិយ័តភាពសិក្សា ចេះស្វ័យសិក្សា ចំណែកឯសិស្សពូកែថ្នាក់ស្រុក ជាតិ ខេត្តមានលទ្ធផលល្អបង្គួរគឺមានន័យថាការរំពឹងគិតរបស់លោកគ្រូ អ្នកគ្រូថាសិស្សអាចមានសមត្ថភាពប្រឡងសិស្សពូកែថ្នាក់ស្រុក ខេត្ត និងជាតិមានត្រឹមកម្រិតល្អបង្គួរតែប៉ុណ្ណោះពីព្រោះវាអាស្រ័យលើការខិតខំសិក្សា ស្រាវជ្រាវពីសំណាក់សិស្សផ្ទាល់ខ្លួនពួកគេដែរ។

### ៤.៣.៥ សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង

*តារាងទី១៤៖* **សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង**

| | សមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹង | មធ្យម |
|---|---|---|
| ៣៦ | ការលើកទឹកចិត្តសិស្ស និងសម្របសម្រួល | 3.89 |
| ៣៧ | អនុវត្តតាមកិច្ចតែងការបង្រៀន | 3.84 |

| | | |
|---|---|---|
| ៣៨ | ប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន | 3.47 |
| ៣៩ | ផ្លាស់ប្តូរវិធីសាស្ត្រ និងល្បិចបង្រៀន | 3.58 |
| ៤០ | រៀបចំសកម្មភាពសិស្ស (ការងារជាក្រុម បុគ្គល ដៃគូ..........) | 4.00 |
| ៤១ | ជួយសិស្សរៀនយឺត | 3.63 |
| ៤២ | បណ្តុះគំនិតច្នៃប្រឌិត ទម្លាប់គិត និងសមត្ថភាពដល់សិស្ស | 3.68 |
| ៤៣ | លទ្ធផលសិក្សារបស់សិស្សសម្រេចបានតាមវត្ថុបំណងមេរៀន | 3.63 |
| ៤៤ | ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃនិងមុខវិជ្ជាដទៃទៀត | 3.47 |
| ៤៥ | គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព | 3.58 |

**តាមតារាងទី១៤** គឺថាលោកគ្រូ អ្នកគ្រូមានសមត្ថភាពបង្រៀន និងផ្ទេរចំណេះដឹងបានល្អ ដោយមានការលើកទឹកចិត្តសិស្ស និងសម្របសម្រួលបានល្អ ការអនុវត្តតាមកិច្ចតែងការបង្រៀនបានល្អ ការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនបានល្អ មានផ្លាស់ប្តូរវិធីសាស្ត្រ និងល្បិចបង្រៀន មានការរៀបចំសកម្មភាពសិស្ស (ការងារជាក្រុម បុគ្គល ដៃគូ ..........)បានត្រឹមត្រូវ មានកម្មវិធីជួយសិស្សរៀនយឺត ជួយបណ្តុះគំនិតច្នៃប្រឌិត ទម្លាប់គិត និងសមត្ថភាពដល់សិស្សបានទៀងទាត់ ទទួលបានលទ្ធផលសិក្សារបស់សិស្សសម្រេចបានតាមវត្ថុបំណងមេរៀន បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃនិងមុខវិជ្ជាដទៃទៀត និងគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៅទៀតតាមរយៈការបំពេញកម្រងសំណួររបស់សិស្សបញ្ជាក់ថាសមត្ថភាពបង្រៀននិងផ្ទេរចំណេះដឹងរបស់លោកគ្រូអ្នកគ្រូគឺបានល្អ។

### ៤.៣.៦ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

***តារាងទី១៥៖*** ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

| | ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | មធ្យម |
|---|---|---|
| ៤៦ | ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន | 4.16 |
| ៤៧ | ពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ | 4.05 |
| ៤៨ | គោរពវិន័យការងារ និងរក្សាការសម្ងាត់វិជ្ជាជីវៈ | 4.05 |
| ៤៩ | ភក្តីភាពចំពោះអង្គភាព វិជ្ជាជីវៈ និងផ្តល់តម្លៃអ្នកសិក្សា | 4.32 |
| ៥០ | ការមិនរើសអើង និងមិនប្រើអំពើហឹង្សា | 4.26 |

| ៥១ | សីលធម៌រស់នៅល្អ គុណធម៌ និងយុត្តិធម៌ | 4.16 |
|---|---|---|

**តាមតារាងទី១៥** គឺថាលោកគ្រូ អ្នកគ្រូគោរពតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានល្អ តាមរយៈការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន ការពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ គោរពវិន័យការងារ និងរក្សាការសម្ងាត់វិជ្ជាជីវៈ មានភក្តីភាពចំពោះអង្គភាព វិជ្ជាជីវៈ និងផ្តល់តម្លៃអ្នកសិក្សា ការមិនរើសអើង និងមិនប្រើអំពើហិង្សា និងមានសីលធម៌រស់នៅល្អ គុណធម៌ និងយុត្តិធម៌។ ទាំងនេះបង្ហាញថាលោកគ្រូអ្នកគ្រូរស់នៅ និងប្រកបមុខរបរវិជ្ជាជីវៈដោយប្រកាន់ខ្ជាប់នូវមនសិការវិជ្ជាជីវៈនិងមានក្រមសីលធម៌ល្អ

## *៤.៤* ការសិក្សារបស់សិស្សានុសិស្ស

ចំពោះការវិភាគលើចម្លើយរបស់សិស្ស អ្នកសិក្សាស្រាវជ្រាវបានធ្វើការវិភាគដោប្រើប្រាស់ដ្យាក្រាមដោយគិតជាភាគរយទៅតាមកម្រិតនៃចម្លើយនីមួយៗ

**ដ្យាក្រាមទី៥៖ តើប្អូនៗចូលបណ្ណាល័យញឹកញាប់ទេ?**




**តាមដ្យាក្រាមទី៥** មានសិស្សចំនួន២០នាក់ ត្រូវជា ២៨.៥៧ % ចូលបណ្ណាល័យម្តងម្កាល សិស្សចំនួន ៤២ នាក់ ត្រូវជា ៦០.០០% ចូលបណ្ណាល័យញឹកញាប់ និងសិស្សចំនួន៨នាក់ ត្រូវជា ១១.៤២% ចូលបណ្ណាល័យរាល់ថ្ងៃ និងមិនមានសិស្សណាដែលមិនបានចូលបណ្ណាល័យសោះទេ។ នេះបង្ហាញឱ្យឃើញថាសិស្សានុសិស្សបានចូលបណ្ណាល័យដើម្បីសិក្សាស្រាវជ្រាវមានចំនួនច្រើន។ តែបើតាមការសម្ភាសន៍ជាមួយលោក សុខ សេងលី នាយករងនៅសាលាពាមជីកងបានលើកឡើងថា សាលារៀននេះទើបតែបង្កើតសាលាជំនាន់ថ្មីដូចនេះបណ្ណាល័យមិនទាន់មានលក្ខណៈជាបណ្ណាល័យស្តង់ដា នៅឡើយទេ និងបើតាមសំណូមពររបស់សិស្សមួយចំនួនបានស្នើឡើងថា សូមជួយបន្ថែមសៀវភៅ

ទាក់ទងនឹងសៀវភៅសិក្សាគោលនិងឯកសារផ្សេងៗឱ្យបានច្រើនដើម្បីផ្តល់ភាពងាយស្រួលដល់សិស្សក្នុងការសិក្សាស្រាវជ្រាវ និងស្វ័យសិក្សាបន្ថែម។

**ដ្យាក្រាមទី៦៖ តើប្អូនៗធ្វើពិសោធ៍ចំពោះមុខវិជ្ជាវិទ្យាសាស្រ្តញឹកញាប់ទេ?**




**តាមដ្យាក្រាមទី៦** សិស្សធ្វើពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្រ្តមានចំនួន 0 នាក់ ត្រូវជា 0,0% មិនដែលបានពិសោធន៍ និងធ្វើការពិសោធន៍រាល់ថ្ងៃ សិស្សចំនួន៦២នាក់ ត្រូវជា ៨៨.៥៧% បានធ្វើពិសោធន៍ម្តងម្កាល សិស្សចំនួន៨នាក់ ត្រូវជា ១១.៤២% បានធ្វើពិសោធន៍ញឹកញាប់ និងសិស្សចំនួន០នាក់ត្រូវជា០.០០%បានធ្វើពិសោធន៍រាល់ថ្ងៃ។

**ដ្យាក្រាមទី៧៖ តើប្អូនៗធ្វើពិសោធ៍ក្នុងថ្នាក់ ឬក្រៅថ្នាក់រៀន ឬនៅក្នុងបន្ទប់ពិសោធ៍?**



**តាមដ្យាក្រាមទី៧** សិស្សបានធ្វើពិសោធន៍នៅក្នុងថ្នាក់មានចំនួន ៤៧ នាក់ ត្រូវជា ៦៧.១៤% សិស្សធ្វើពិសោធន៍ក្រៅថ្នាក់មានចំនួន ៣ នាក់ ត្រូវជា ៤.២៩% និងសិស្សធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍មានចំនួន ២០នាក់ ត្រូវជា ២៨.៥៧%។

យើងឃើញថាការពិសោធន៍ភាគច្រើនគឺធ្វើនៅក្នុងថ្នាក់រៀនហើយចំណែកការធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍គឺមានលក្ខណៈមធ្យម និងបើតាមការបំពេញសំណួររបស់សិស្សានុសិស្សឃើញនៅក្នុងបន្ទប់ពិសោធន៍គឺ ខ្វះឧបករណ៍ពិសោធន៍ចំពោះមុខវិជ្ជាដែលត្រូវពិសោធន៍មួយចំនួន។

**ដ្យាក្រាមទី៨៖** ចំពោះមុខវិជ្ជា STEM តើមុខវិជ្ជាណាដែលប្អូនយល់ឃើញថាពិបាយល់?




**តាមដ្យាក្រាមទី៨** បង្ហាញថាសិស្សយល់ឃើញថាក្នុងមុខវិជ្ជាស្វែម ចំនួន ៣០នាក់ត្រូវជា ៤២.៨៦% យល់ឃើញថាមុខវិជ្ជាវិទ្យាសាស្ត្រពិបាកយល់ ចំនួន ៧នាក់ ត្រូវជា ១០.០០% យល់ឃើញថាមុខវិជ្ជាបច្ចេកវិទ្យាពិបាកយល់ ចំនួន ៩នាក់ ត្រូវជា ១២.៨៦% យល់ឃើញថាមុខវិជ្ជាវិស្វកម្មពិបាកយល់ និងចំនួន ២៤នាក់ត្រូវជា ៣៤.២៩% យល់ឃើញថាមុខវិទ្យាគណិតវិទ្យាពិបាកយល់។ តាមដ្យាក្រាម ការសម្ភាសន៍ និងសង្កេតឃើញថាសិស្សានុសិស្សភាគច្រើនមានការលំបាកចំពោះមុខវិជ្ជាវិទ្យាសាស្រ្ត ដូចជាគណិតវិទ្យា គីមីវិទ្យា រូបវិទ្យា។ ដូចនេះសិស្សភាគច្រើនមានចំណេះដឹងនូវមានកម្រិតនៅឡើយសម្រាប់សាលាជំនាន់ថ្មី។

**ដ្យាក្រាមទី៩៖ តើប្អូនយល់យ៉ាងណាដែរចំពោះមុខវិជ្ជា STEM?**




**តាមដ្យាក្រាមទី៩** បង្ហាញថាសិស្សយល់ឃើញថាក្នុងមុខវិជ្ជាស្ទែម ចំនួន ៣ នាក់ត្រូវជា ៤.២៩% យល់ឃើញថាពិបាក ចំនួន ៥៦ នាក់ ត្រូវជា ៨០.០០% យល់ឃើញថាពិបាកគួរសម ចំនួន ១១នាក់ ត្រូវជា ១៥.៧១% យល់ឃើញថាងាយស្រួល និងចំនួន ០០នាក់ត្រូវជា ០.០០% យល់ឃើញថាស្រួលណាស់។ តាមដ្យាក្រាម ការសួរសំណួរ និងសង្កេតឃើញថាសិស្សានុសិស្សភាគច្រើនយល់ឃើញថាមុខវិជ្ជាស្ទែមគឺពិបាកគួរសម។ ដូចនេះមានន័យថាសិស្សភាគច្រើនមានចំណេះដឹងនៅមានកម្រិតនៅឡើយចំពោះមុខវិជ្ជាស្ទែមនៅសាលាជំនាន់ថ្មីដែលចង់បណ្តុះបណ្តាលធនធានមនុស្សតម្រូវទៅតាមទីផ្សារការងារនៅសតវត្សរ៍ទី២១ ឬសម័យឌីជីថលនេះ។

**ដ្យាក្រាមទី១០៖ តើប្អូនប្រើប្រាស់កុំព្យូទ័រញឹកញាប់ទេ?**



**តាមដ្យាក្រាមទី១០** សិស្សមានចំនួន ០ នាក់ ត្រូវជា០.០០% មិនដែលប្រើប្រាស់កុំព្យូទ័រ សិស្សចំនួន ៤២ នាក់ ត្រូវជា៦០.០០% បានប្រើប្រាស់កុំព្យូទ័រម្តងម្កាល សិស្សចំនួន២៦ នាក់ ត្រូវជា ៣៧.១៥% បានប្រើប្រាស់កុំព្យូទ័រសិក្សាញឹកញាប់ និងសិស្សចំនួន២នាក់ត្រូវជា២.៨៥%បានប្រើប្រាស់កុំព្យូទ័ររាល់ថ្ងៃ។

**ដ្យាក្រាមទី១១៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការប្រើប្រាស់កុំព្យូទ័រចំពោះការសិក្សា?**




**តាមដ្យាក្រាមទី១១** បង្ហាញពីការយល់ឃើញរបស់សិស្សចំពោះការប្រើប្រាស់កុំព្យូទ័រចំពោះការសិក្សា មានសិស្សចំនួន ០ នាក់ត្រូវជា ០.០០% យល់ឃើញថាមិនចាំបាច់ និងមិនសូវសំខាន់ សិស្សចំនួន ៤១នាក់ត្រូវជា ៥៨.៥៧% យល់ឃើញថាសំខាន់ និងសិស្សចំនួន ២៩នាក់ត្រូវជា ៤១.៤៣% យល់ឃើញថាសំខាន់ណាស់។

**ដ្យាក្រាមទី១២៖ តើការសិក្សារបស់ប្អូនមានការរីកចំរើនច្រើនដែរឬទេបន្ទាប់ពីបានមករៀននៅទីនេះ?**



**តាមដ្យាក្រាមទី១២** ក្រោយពីការចូលរៀននៅសាលាជំនាន់ថ្មីនេះ សិស្សចំនួន ១នាក់ត្រូវជា ១.៤៣% អត់មានការរីកចំរើនចំពោះការសិក្សាទេ សិស្សចំនួន ១១ នាក់ត្រូវជា ១៥.៧១% មានការរីកចំរើនតិចតួច និងសិស្សចំនួន ៥៨ នាក់ត្រូវជា ៨២.៨៦% មានការរីកចំរើនច្រើន។

ចំណុចនេះបង្ហាញថាសិស្សភាគច្រើន ក្រោយពីចូលរៀននៅសាលាជំនាន់ថ្មីហើយមានការប្រែប្រួលនូវចំណេះដឹងមានថាការសិក្សារបស់ពួកគេមានការកើនឡើង និងបើតាមការបំពេញកម្រងសំណួរសិស្សខ្លះបានលើកឡើងថា ពួកគេមានសេចក្តីក្លាហានក្នុងការពិភាក្សាមេរៀនជាមួយមិត្តរួមថ្នាក់ និងការធ្វើបថបង្ហាញផ្សេងៗ។ តាមការបំពេញចម្លើយកម្រងសំណួរទាំងនេះបញ្ជាក់ថាសិស្សភាគគឺមានភាពក្លាហានក្នុងការបញ្ចេញមតិក្នុងម៉ោងសិក្សាតែភាគច្រើនបានតែចំពោះមុខវិជ្ជាសង្គមទេ។

**ដ្យាក្រាមទី១៣៖ តើប្អូនៗពេញចិត្តនឹងលទ្ធផលនៃការសិក្សាដែលប្អូនទទួលបាននៅសាលាកម្រិតណាដែរ?**




**តាមដ្យាក្រាមទី១៣** សិស្សពេញចិត្តទៅនឹងលទ្ធផលសិក្សារបស់ខ្លួននៅសាលាជំនាន់ថ្មីនេះ មានសិស្សចំនួន ២ នាក់ត្រូវជា២.៨៦% ពេញចិត្តតិចតួច សិស្សចំនួន ២៩ នាក់ត្រូវជា ៤១.៤៣% ពេញចិត្តល្មម និងសិស្សចំនួន ៣៩ នាក់ ត្រូវជា៥៥.៧១% ពេញចិត្តខ្លាំង។ សរុបមកឃើញថាមានសិស្សតែ ៥០% ជាងប៉ុណ្ណោះពេញចិត្តខ្លាំងចំពោះការលទ្ធផលសិក្សារបស់ខ្លួន និងក្រៅពីនេះមានការពេញចិត្តលម្មនិងតិចចំពោះលទ្ធផលសិក្សារបស់ខ្លួន។

**ដ្យាក្រាមទី១៤៖ តើប្អូនមានស្វ័យសិក្សាញឹកញាប់ដែរឬទេ?**




**តាមដ្យាក្រាមទី១៤** មានសិស្សចំនួន ២ នាក់ ត្រូវជា ២.៨៥% មិនដែលស្វ័យសិក្សាសោះ សិស្សចំនួន ២៧ នាក់ត្រូវជា ៣៨.៥៧% មានការស្វ័យសិក្សាម្តងម្កាល សិស្សចំនួន ៣០ នាក់ត្រូវជា ៤២.៨៥% មានការស្វ័យសិក្សាញឹកញាប់ និងសិស្សចំនួន ១១ នាក់ត្រូវជា ១៥.៧១% មានការស្វ័យសិក្សារាល់ថ្ងៃ។

យើងទាញបានថាមានសិស្សតែ ៥០% ជាងមានការស្វ័យសិក្សាញឹកញាប់ និងតិចជាង ៥០%ធ្វើការស្វ័យសិក្សាម្តងម្កាល ឬមិនដែលសោះ។ចំណុចនេះហើយដែលរួមចំណែកធ្វើឱ្យជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស។

**ដ្យាក្រាមទី១៥៖ តើប្អូនចូលរួមក្នុងក្លឹបសិក្សាញឹកញាប់ដែរឬទេ?**



**តាមដ្យាក្រាមទី១៥** មានសិស្សចំនួន៣ នាក់ត្រូវជា៤.២៨% មិនដែលបានចូលរួមក្នុងក្លឹបសិក្សាសោះ សិស្សចំនួន ៣០នាក់ត្រូវជា៤២.៨៥% បានចូលក្លឹបសិក្សាម្តងម្កាល សិស្សចំនួន ៣៥នាក់ត្រូវជា ៥០.០០% បានចូលរួមក្នុងក្លឹបសិក្សាញឹកញាប់ និងសិស្សចំនួន ២ នាក់ត្រូវជា ២.៨៥% បានចូលរួមក្នុងក្លឹបសិក្សារាល់ថ្ងៃ។
យើងទាញបានថាមានសិស្សតែ ៥០% ជាងបានចូលរួមក្លឹបសិក្សាញឹកញាប់ និងតិចជាង ៥០%បានចូលរួមក្លឹបសិក្សាម្តងម្កាល ឬមិនដែលសោះ។

**ដ្យាក្រាមទី១៦៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការបង្រៀនរបស់គ្រូមុខវិជ្ជានីមួយៗក្នុងសាលា?**




**តាមដ្យាក្រាមទី១៦** បង្ហាញពីការយល់ឃើញរបស់សិស្សចំពោះការបង្រៀនរបស់លោកគ្រូ អ្នកគ្រូចំពោះមុខវិជ្ជានីមួយៗនៅក្នុងសាលា មានសិស្សចំនួន ០ នាក់ត្រូវជា០.០០% យល់ឃើញថាការបង្រៀនរបស់លោកគ្រូអ្នកគ្រូគឺធម្មតា សិស្សចំនួន៦នាក់ត្រូវជា ៨.៥៧% យល់ឃើញថាការបង្រៀនរបស់លោកគ្រូអ្នកគ្រូគឺល្អបង្គួរ សិស្សចំនួន ៣៧នាក់ត្រូវជា ៥២.៨៦% យល់ឃើញថាការបង្រៀនរបស់លោកគ្រូអ្នកគ្រូបានល្អ និងសិស្សចំនួន ២៧ នាក់ត្រូវជា ៣៨.៥៧% យល់ឃើញថាការបង្ហាត់បង្រៀនរបស់លោកគ្រូអ្នកគ្រូបានល្អណាស់។

**ដ្យាក្រាមទី១៧៖ តើប្អូនយល់ឃើញយ៉ាងដូចម្ដេចចំពោះខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗនៅក្នុងសាលា?**




**តាមដ្យាក្រាមទី១៧** បង្ហាញពីការយល់ឃើញរបស់សិស្សចំពោះខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗនៅក្នុងសាលា មានសិស្សចំនួន ០ នាក់ត្រូវជា 0.00% យល់ឃើញថាខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗគឺធម្មតា សិស្សចំនួន ៧ នាក់ត្រូវជា១០.00% យល់ឃើញថាខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗគឺល្អបង្គួរ សិស្សចំនួន ៤០ នាក់ត្រូវជា៥៧.១៤% យល់ឃើញថាខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗល្អ និងសិស្សចំនួន ២៣ នាក់ត្រូវជា ៣២.៨៦% យល់ឃើញថាខ្លឹមសារមេរៀននៃមុខវិជ្ជានីមួយៗល្អណាស់។

**ដ្យាក្រាមទី១៨៖ តើប្អូនយល់ឃើញយ៉ាងណាដែរចំពោះការផ្ទេរចំណេះដឹងរបស់លោកគ្រូអ្នកគ្រូនៅសាលាជំនាន់ថ្មីនេះ?**



**តាមដ្យាក្រាមទី១៨** បង្ហាញពីការយល់ឃើញរបស់សិស្សចំពោះការផ្ទេរចំណេះដឹងរបស់លោកគ្រូអ្នកគ្រូនៅក្នុងសាលា មានសិស្សចំនួន ០នាក់ត្រូវជា០.០០% យល់ឃើញថាការផ្ទេរចំណេះដឹងរបស់លោកគ្រូអ្នកគ្រូគឺធម្មតា សិស្សចំនួន ៣នាក់ត្រូវជា ៤.២៩% យល់ឃើញថាការផ្ទេចំណេះដឹងរបស់លោកគ្រូអ្នកគ្រូគឺល្អបង្គួរ សិស្សចំនួន ៣៥ នាក់ត្រូវជា ៥០.០០% យល់ឃើញថាការផ្ទេចំណេះដឹងរបស់លោកគ្រូអ្នកគ្រូល្អ និងសិស្សចំនួន ៣២ នាក់ត្រូវជា ៤៥.៧១% យល់ឃើញថាការផ្ទេចំណេះដឹងរបស់លោកគ្រូអ្នកគ្រូល្អណាស់។

**ដ្យាក្រាមទី១៩៖ តើប្អូនៗពេញចិត្តនឹងលទ្ធផលនៃការសិក្សាដែលប្អូនទទួលបាននៅសាលានេះកម្រិតណាដែរ?**




**តាមដ្យាក្រាមទី១៩** បង្ហាញពីការពេញចិត្តនឹងលទ្ធផលសិក្សារបស់សិស្សនៅក្នុងសាលា មានសិស្សចំនួន ១នាក់ត្រូវជា១.៤៣% មានការពេញចិត្តនឹងលទ្ធផលសិក្សាធម្មតា សិស្សចំនួន ១៥នាក់ត្រូវជា២១.៤៣% មានការពេញចិត្តនឹងលទ្ធផលសិក្សាល្អបង្គួរ សិស្សចំនួន ៤២នាក់ត្រូវជា៦០.០០% មានការពេញចិត្តនឹងលទ្ធផលសិក្សាល្អ និងសិស្សចំនួន ១២នាក់ត្រូវជា ១៧.១៤% មានការពេញចិត្តនឹងលទ្ធផលសិក្សាល្អណាស់។ ដ្យាក្រាមបង្ហាញថាមានសិស្សចំនួនច្រើនជាង ៧០ % ពេញចិត្តខ្លាំងនឹងលទ្ធផលសិក្សារបស់ខ្លួន។

## *៤.៥* លទ្ធផលនៃការសិក្សារបស់សិស្សប្រចាំខែ និងប្រចាំឆមាសទី១

**ដ្យាក្រាមទី២០ លទ្ធផលការសិក្សាប្រចាំខែ និងប្រចាំឆមាសលើកទី១**




**តាមដ្យាក្រាមទី២០** ឃើញថាចំណាត់ថ្នាក់សិស្សជាប់ចាប់ពីខែធ្នូដល់ខែកុម្ភៈមានការកើនឡើងជាលំដាប់ និងចំនួនសិស្សធ្លាក់មានការថយចុះទោះបីជាមានភាគរយខ្ពស់ជាងថ្នាក់ជាតិបន្តិចក៏ដោយ នេះបង្ហាញថាការសិក្សារបស់សិស្សមានលក្ខណៈល្អប្រសើចំពោះការចាប់ផ្ដើមចូលរៀនដំបូង ពីព្រោះលោកគ្រូអ្នកគ្រូខិតខំយកចិត្តទុកដាក់ក្នុងបង្ហាត់បង្រៀនគ្រប់គ្រងសិស្ស នាយកមានការដឹកនាំការរៀននិងបង្រៀនបានល្អ ហើយសិស្សខ្លួនឯងមានការចូលបណ្ណាល័យញឹកញាប់។ ចំពោះបញ្ហាប្រឈមគឺថាភាគរយសិស្សប្រឡងជាប់មានការធ្លាក់ចុះនៅក្នុងឆមាសទី១និងប្រចាំឆមាសលើកទី១ និងភាគរយសិស្សធ្លាក់មានការកើនឡើង និងចំនួនសិស្សបោះបង់ការសិក្សាមានចំនួន២.០០%។

តើកត្តាអ្វីខ្លះដែលធ្វើឱ្យចំនួនសិស្សធ្លាក់មធ្យមភាគកើនឡើងនៅក្នុងឆមាសលើកទី១នៅសាលាជំនាន់ថ្មីនេះ?

ក្រោយពីការសិក្សាស្រាវជ្រាវ អ្នកស្រាវជ្រាវរកឃើថាបញ្ហាមួយចំនួនដូចជា

- លោកគ្រូអ្នកគ្រូបង្រៀនខុសឯកទេសមានចំនួន ២៦.៣២ %
- លោកគ្រូអ្នកគ្រូភាគច្រើនមានចំណេះដឹងផ្នែកភាសាអង់គ្លេសនិងបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិត
- សិស្សចំនួន ៨៨.៥៧% បានធ្វើពិសោធន៍តិចតួចចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ

- សិស្សចំនួន ៩១.៩២ % មានការស្ម័យសិក្សាម្តងម្កាល
- សិស្សចំនួន ៩៧.១៣ % ចូលរួមក្នុងក្លឹបសិក្សាម្តងម្កាល
- សិស្សចំនួន ៨៩.២៩% យល់ឃើញថាមុខវិជ្ជាស្ទែម (STEM) ពិបាក
- សិស្សចំនួន ៧៧.១៥% យល់ថាមុខវិទ្យាសាស្ត្រ និងគណិតវិទ្យាពិបាកយល់
- លទ្ធផលសិក្សាប្រចាំឆមាសទី១របស់សិស្សមានការធ្លាក់ចុះ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង

# សំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## *៥.១- សេចក្តីសន្និដ្ឋាន*

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ អង្កេត និងសួរសំណួរបន្ថែមនៅតាមសាលាវិទ្យាល័យគោលដៅចំនួន ០២ លើប្រធានបទ "**ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី**" ករណីសិក្សានៅក្នុងខេត្តកំពង់ចាម អ្នកសិក្សាស្រាវជ្រាវ បានប្រមូលព័ត៌មាននិងធ្វើការសន្និដ្ឋានរួមថា៖ ការអនុវត្តនៅសាលានេះមានភាពវិជ្ជមានច្រើនដូចជាការគ្រប់ និងដឹកនាំ ការបង្ហាត់បង្រៀន បរិស្ថានស្អាត និងឧបករណ៍ពិសោធន៍ទាក់ទងនឹងការសិក្សា។ ក្រៅពីចំណុចវិជ្ជមានទាំងនេះ ក៏មានចំណុចដែលជាបញ្ហាប្រឈមផងដែរដូចជាការសិក្សា និងលទ្ធផលសិក្សារបស់សិស្សគឺនៅមានកម្រិតនៅឡើយ(តាមដ្យាក្រាមទី២០) ពីព្រោះសិស្សភាគច្រើនមិនសូវចាប់បានចំពោះមុខវិជ្ជាវិទ្យាសាស្រ្ត និងមុខវិជ្ជាគណិតវិទ្យាក្នុងចំនោមមុខវិជ្ជាទាំងបួននៅក្នុងមុខវិជ្ជាស្ទែម (STEM) ដែលជាមុខវិជ្ជាជំនាញនិងជាមុខវិជ្ជាដែលសាលាជំនាន់ថ្មីយកចិត្តទុកដាក់ និងផ្តោតអារម្មណ៍លើ ជាពិសេសសិស្សមិនសូវបានធ្វើពិសោធន៍ចំពោះមុខវិជ្ជាពិសោធន៍ទេ(តាមដ្យាក្រាមទី៦) និងកម្មវិធីសិក្សាថ្មី។ទាំងនេះហើយដែលរួមចំណែកធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សនៅមានកម្រិត។ បន្ថែមពីនេះទៅទៀតសិស្សភាគច្រើនមានចំណេះដឹងផ្នែកភាសាអង់គ្លេស និងបច្ចេកវិទ្យាព័ត៌មាននៅមានកម្រិតនៅឡើយ។ ម្យ៉ាងវិញទៀត លោកគ្រូអ្នកគ្រូចំនួន ២៦.៣២ % បង្រៀនខុសឯកទេស (តាមដ្យាក្រាមទី២) និងលោកគ្រូអ្នកគ្រូមួយចំនួនមានចំណេះដឹងផ្នែកភាសាអង់គ្លេស និងជំនាញកុំព្យូទ័រនៅមានកម្រិតនៅឡើយ (តាមតារាងទី១០) និងវិធីសាស្រ្តបង្រៀនតាមបែបសតវត្សរ៍ទី២១ដូចជា ការបង្រៀនបែបគម្រោង(PBL) ការបង្រៀនបែបរិះរក (IBL) បែបសហការ (CL) និងការបង្រៀននិងរៀនដោយប្រើប្រាស់វិធីសាស្រ្តវាយតម្លៃតាមបែបប្លូម (Bloom's Taxonomy) ដើម្បីកំណត់វត្ថុបំណងនៃមេរៀននៅមានកម្រិតនិងចោទជាបញ្ហានៅឡើយ។ ចំណុចទាំងនេះហើយដែលបានរួមចំណែកធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតនៅឡើយ។

សុរបមកការសិក្សាស្រាវជ្រាវលើប្រធានបទ ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីក្នុងខេត្តកំពង់ចាម អនុវត្តបាននៅមានកម្រិតនៅឡើយចំពោះលទ្ធផលសិក្សារបស់សិស្សបើតាមអ្វីដែលអ្នកសិក្សាស្រាវជ្រាវបានស្វែងរកឃើញ។

## ៥.២- សំណូមពរ

យើងសង្កេតឃើញថាលទ្ធផលសិក្សារបស់សិស្សនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឬឯកជនពិតជាមានសារៈសំខាន់សម្រាប់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដើម្បីធ្វើជាដើមទុនសម្រាប់ឱ្យពួកគេអាចបន្តការសិក្សានៅថ្នាក់មហាវិទ្យាល័យ និងប្រកួតប្រជែងសម្រាប់ឱកាសទីផ្សារការងារនាសតវត្សរ៍ទី២១ទាំងនៅក្នុង និងក្រៅស្រុកខេត្ត និងប្រទេស ដូចនេះហើយចំពោះមុខវិជ្ជាភាសាអង់គ្លេស បច្ចេកវិទ្យាព័ត៌មាន និងមុខវិជ្ជាស្ទែម (STEM) គួរតែត្រូវបានយកចិត្តទុកដាក់បន្ថែម និងពង្រឹងឱ្យបានល្អប្រសើរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

សូមបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានបង្កើតកម្មវិធីសាលាជំនាន់ថ្មី ផ្តោតទៅលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា( STEM ) ដើម្បីជំរុញឲ្យមានអ្នកជំនាញខាងវិទ្យាសាស្ត្រ កាន់តែច្រើននៅកម្ពុជា។ កម្មវិធីនេះ ត្រូវបានក្រសួងអប់រំ ដាក់ឲ្យអនុវត្តន៍សាកល្បងនៅឆ្នាំ២០១៥។

ឆ្លងតាមរយៈការស្រាវជ្រាវបានរកឃើញពីបញ្ហាប្រឈមមួយចំនួនដូចដែរបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន បញ្ជាក់ថា៖ «ជាការពិតនៅតាមទីជនបទ យើងឃើញថាមានការខ្វះខាតបើប្រៀបធៀបជាមួយទីក្រុង។ ទាំងគ្រូក៏នៅមានកម្រិត ទាំងបន្ទប់ពិសោធន៍ក៏នៅមានកម្រិត។ ប៉ុន្តែក្រសួងនឹងបង្កើតសាលាគំរូជំនាន់ថ្មីប្រមាណជា២០០សាលា នៅគ្រប់ខេត្តក្រុង ផ្តោតលើ **STEM** ហ្នឹង(lotus-radio.com ,១៥ ខែមីនា ២០១៨)។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងជាសំណូមពរមួយចំនួនដូចខាងក្រោមចំពោះអ្នកដែលពាក់ព័ន្ធ និងដៃគូជំនួយដើម្បីជួយគ្នាធ្វើឱ្យការអនុវត្តនៅសាលាជំនាន់ថ្មីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តនៅសាលាជំនាន់ថ្មីនៅខេត្តកំពង់ចាម ក៏ដូចជានៅទូទាំងប្រទេសកម្ពុជានាពេលអនាគត។

- ពង្រឹងបន្ថែមចំពោះមុខវិជ្ជាវិទ្យាសាស្ត្រជាពិសេសមុខវិជ្ជាក្នុងស្ទែម (STEM) តាមរយៈការជម្រុញឱ្យមានការពិសោធន៍ឱ្យបានច្រើន ការប្រើប្រាស់សម្ភារៈឧបទេសក្នុងការបង្រៀនសិស្សឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ការស្វ័យសិក្សា ការចូលរួមក្នុងក្លឹបសិក្សា បន្ថែមម៉ោងបំប៉នក្រៅម៉ោងសិក្សា ការចូលអានសៀវភៅក្នុងបណ្ណាល័យ ឱ្យមានការស្រាវជ្រាវ ឬពិសោធន៍ត្រូវចុះទៅដល់កន្លែង(បើអាច)...។
- ពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនលើវិធីសាស្ត្របង្រៀនតាមបែបទំនើប តាមរយៈការលើកទឹកចិត្តចំពោះលោកគ្រូអ្នកគ្រូណាចង់ចូលរួមវគ្គសិក្សា ដាក់គ្រូបង្រៀនឱ្យត្រូវទៅតាមឯកទេស ផ្តល់ឱកាសនិងការលើកទឹកចិត្តឱ្យលោកគ្រូអ្នកគ្រូបានចូលរួមវគ្គសិក្សាខ្លី ឬសិក្ខាសាលាស្តីពីវិធីសាស្ត្ររៀនតាមបែបទំនើប បង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូនូវវិធីសាស្ត្របង្រៀនតាមបែបទំនើប ពង្រឹងមុខវិជ្ជាឯកទេសនិងគរុកោសល្យ...។
- ពង្រឹងបន្ថែមភាសាអង់គ្លេសទាំងគ្រូនិងសិស្ស និងជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាព័តិដល់លោកគ្រូអ្នកគ្រូបន្ថែម តាមរយៈការបន្ថយសិស្សមកត្រឹម២០ទៅ២៥នាក់មួយថ្នាក់(បើអាច) ទុកពេលឱ្យសិស្សអនុវត្តឱ្យបានច្រើន ដាក់កិច្ចការស្រាវជ្រាវដល់សិស្សជាប្រចាំ គួរចែកក្រដាស (hand-out)(បើអាច) និងបង្កើនម៉ោងបន្ថែម១ម៉ឬ២ម៉ ក្នុង១សប្តាហ៍។
- រៀបចំឱ្យសិស្សមានការចុះកម្មវិធីសិក្សាបន្ថែម (បើអាច យ៉ាងតិច២ដងក្នុង១ឆ្នាំ)

### *៥.៣- ការសិក្សាស្រាវជ្រាវបន្ត*

ដោយសារតែថវិកា ពេវេលា និងទីតាំងមានកំណត់ មិនអាចធ្វើឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទ "**ប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មី**" ឆ្លុះបញ្ចាំងពីទិដ្ឋភាពរួមនៃការអនុវត្តសាលាជំនាន់ថ្មីទាំង១១សាលាទូទាំងប្រទេសបានឡើយ។ ហេតុនេះហើយការសិក្សាស្រាវជ្រាវខាងលើនេះ ធ្វើឡើងតែនៅក្នុងបរិបទនៃខេត្តកំពង់ចាមដែលជ្រើសយកសាលាវិទ្យាតែ២ប៉ុណ្ណោះ។ ដូចនេះ សូមឱ្យអ្នកសិក្សាក្រោយៗបន្តពង្រីក

វិសាលភាពនៃការស្រាវជ្រាវខ្លួនលើប្រធានបទខាងលើ ឬប្រធានបទប្រហាក់ប្រហែលស្របតាមការរីកចម្រើននិងជឿនលឿនរបស់សង្គម ជាពិសេសអាចចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការអនុវត្តសាលាជំនាន់ថ្មីនៅទូទាំងប្រទេស។

# ឯកសារយោង

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ២០១៤-២០១៨, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ២០១៨-២០២៣, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៩, គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៦, គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៦, ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស(២០១៥-២០១៩), ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៥, បញ្ញាតិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅនៅប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៤, គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០, ប្រទេសកម្ពុជា។
- ក្រសួងអប់រំ យុវជន និងកីឡា,២០១៦, ការផ្តល់ប្រឹក្សាអាជីពនិងព័ត៌មានស្តីពីការសិក្សាជំនាញ, ប្រទេសកម្ពុជា។
- ហាង់ជួន ណារ៉ុន, ២០១៦, កំណែទម្រង់វិស័យអប់រំនៅកម្ពុជា: មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព, ADB, ភ្នំពេញ: ។
- ក្រសួងអប់រំ យុវជន និងកីឡា ២០០៧, ច្បាប់ស្តីពីការអប់រំ, ភ្នំពេញ។

- ក្រសួងអប់រំ យុវជន និងកីឡា ២០១៦, ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ
- រាជរដ្ឋាភិបាលកម្ពុជា ២០១៣, យុទ្ធសាស្ត្រចតុកោណៈ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៣, ភ្នំពេញ។
- រាជរដ្ឋាភិបាលកម្ពុជា ២០១៨, យុទ្ធសាស្ត្រចតុកោណៈ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដំណាក់កាលទី៤, ភ្នំពេញ។
- ក្រសួងអប់រំ យុវជន និងកីឡា, គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី, ខែកញ្ញា ២០១៦
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), សេចក្តីព្រាងចុងក្រោយ នៃការបង្កើតសាលាជំនាន់ថ្មី ខែតុលា ឆ្នាំ២០១៤
- គាន់ មុន្នីវិសាល វ៉ុល១ លេខទី៣ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩,បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម ៤.0)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣)
- យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជននិងកីឡា (២០១៨-២០២៣) ឆ្នាំ ២០១៨
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០០៩
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១០
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១១
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១២
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១៣

- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១៤
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១៥
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា(KAPE), របាយការណ៍ប្រចាំ ២០១៦
- NEP. (២០១៥). វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុងអ៊ីនឈុន និង ក្របខណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និង ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា. អ៊ីនឈុន: NGO Education Partnership.
- សៀវភៅគោលនយោបាយសាលាជំនាន់ថ្មី,....................................................
- សេចក្តីព្រាងចុងក្រោយនៃការបង្កើតសាលាជំនាន់ថ្មី........................................
- RGC. (2014-2018). NSDP. Phnom Penh: Royal Government of Cambodia.
- TTD. (2015). Teacher Policy Action Plan. Phnom Penh: MOEYS.
- Ministry of Education, Youth and Sport (January 2015). Teacher Policy Action Plan. Phnom Penh: Teacher Training Department.
- EFA GMR 2005, Education For All-The Quality Imperative
- New Generation School National Survey (NGSNS), September 2016
- Scientific and Cultural Organisation United Nations Educationa, (2017). *Sustainable Development Goals .* Paris, France : UNESCO .
- Scientific and Cultural Organisation United Nations Educational. (2000-2015). *Educational for All: Achievements and Challenges .* Paris, France : UNESCO.
- Status of data for children in the SDGs, UNICEF
- Teacher of 21st century: Characteristics and Development, research paper on 9, 2017
- ឡារ៉ែន,ថ្ងៃទី១៩/មេសា/២០១៩http://www.lareine.com.kh/news/education/41615/

- ភ្នំពេញប៉ុស្តិ៍, ១០ តុលា ២០១៧: https://www.postkhmer.com/post-plus/កំណែទម្រង់ថ្មី-តាមរយៈសាលារៀនជំនាន់ថ្មី
- វិទ្យុផ្កាឈូក, ១៥ មិនា ២០១៨: http://lotus-radio.com/2018-ministry-plan-to-create-schools-to-promote-stem/
- ថ្មីៗ, ២៩ មេសា ២០១៨: https://www.thmeythmey.com/?page=detail&id=64235

# ឧបសម្ព័ន

## ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ [illegible] អយក.វិក

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមគ្គេយ្យមជ្ឈិម**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមគ្គេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ:......១១៩......វជអ. ភក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ រ៉ាឡុង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត រ៉ាវុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៉ា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៤៤ គេហទំព័រ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ គុណា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | ក៏ សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ុយ វង្សស៊ុ | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណូ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ទ្រាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ុំ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ុម សិរីរដ្ឋ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន ✓ | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខន្ថា

**កន្លែងទទួល៖**

- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារវិទ្យាស្ថានជាតិអប់រំ

## ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ចាម**
**មន្ទីរអប់រំ យុវជន និងកីឡា**
លេខៈ ...៧៧៥/១៩... ឧទន.រប

# លិខិតឧទ្ទេសនាម

**យោង ៖** លិខិតលេខ១៨៨៥.អយក.វជអ.ចុះថ្ងៃព្រហស្បតិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦។

និស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ដែលនឹងប្រព្រឹត្តទៅចាប់ពី ថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ នៅ ក្រុងកំពង់ចាម- ស្រុកជើងព្រៃ- ស្រុកចំការលើ- ស្រុកកងមាស- ស្រុកបាធាយ និងស្រុកព្រៃឈរ ៖

| | | | |
|---|---|---|---|
| ១ | - លោក | **សាម សុនិត** | និស្សិត |
| ២ | - លោក | **លុន ហ៊ាប** | និស្សិត |
| ៣ | - លោក | **លី កុសល** | និស្សិត |
| ៤ | - លោក | **អៀង គីមឈាន** | និស្សិត |
| ៥ | - លោក | **ឡុង ចំណាន** | និស្សិត |
| ៦ | - លោក | **ទុយ សុវណ្ណារិទ្ធ** | និស្សិត |

ថ្ងៃអង្គារ...១០...រោច... ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កំពង់ចាម ថ្ងៃទី...២៨... ខែឧសភា ឆ្នាំ២០១៩
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
**អនុប្រធាន**

**ជុង-សុផាត**

**កន្លែងទទួល ៖**
